សៀវភៅណែនាំសម្រាប់ភ្នាក់ងារអនុវត្តនៅមូលដ្ឋាន

# អនុវត្តការវាយតម្លៃការកាត់បន្ថយ ភាពងាយរងគ្រោះ

- ការចេញផ្សាយលើកទី២ -



SWEDEN

Australian Aid

gef

The GEF Small Grants Programme

UNDP

Empowered lives. Resilient nations.

## សម្រាប់ការធ្វើសេចក្តីយោង៖

UNDP Cambodia,2014. Practitioner’s Handbook: Implementing the Vulnerability Reduction Assessment. 2nd Edition. Phnom Penh, Cambodia.

---

## ការអះអាង

ទស្សនៈ ឬ យោបល់ដែលសំដែងនៅក្នុងឯកសារនេះ មិនសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅកម្ពុជា(**UNDP**) ដៃគូនានា ឬ ម្ចាស់ជំនួយ ឡើយ។

---

រក្សាសិទ្ធិគ្រប់យ៉ាងដោយអង្គការ **UNDP** នៅកម្ពុជា ឆ្នាំ ២០១៥

## សេចក្តីថ្លែងអំណរគុណ

ការចេញផ្សាយនេះធ្វើទៅបាន តាមរយៈការគាំទ្រដ៏សប្បុរសពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ **(SIDA)** និងទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ **(AusAID)** តាមរយៈការណែនាំជាយុទ្ធសាស្រ្តពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ កម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក **(GEF SGP)** និងយោបល់មកពីក្រុមការងារនៃកម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅសហគមន៍ (CCBAP) ស្ថាប័នទទួលជំនួយពី **CCBAP** តំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា និងអ្នកទទួលផលនៅកម្រិតសហគមន៍។ យើងក៏សូមថ្លែងអំណរគុណផងដែរចំពោះ **Cecilia Aipira, Liam Fee** និង លោកស្រី ងិន ណារីរៈ ដែលបានរួមចំណែកនៅក្នុងការចេញផ្សាយលើកទី១ និងចំពោះ **Robert W. Solar** និង លោក ឆន ប៉ូល នៅក្នុងការចេញផ្សាយលើកទី២នេះ។

*សៀវភៅណែនាំសម្រាប់ភ្នាក់ងារអនុវត្តនៅមូលដ្ឋាន*

# អនុវត្តការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ

- ការចេញផ្សាយលើកទី២ -

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ កម្មវិធីជំនួយខ្នាតតូចនៅកម្ពុជា
ភ្នំពេញ ឆ្នាំ ២០១៥

# មាតិកាអត្ថបទ

ការសង្ខេបនៃការណែនាំសម្រាប់អ្នកប្រើប្រាស់សៀវភៅ VRA 6
ពាក្យបំព្រួញសំខាន់ៗដែលប្រើប្រាស់ 8
ការប្រែប្រួលអាកាសធាតុ សហគមន៍ និងការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ 9
ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ និងការចូលរួម 11
**ជំពូក ១៖ដំណើរការចាប់ផ្តើម** 14
បង្កើតក្រុមអ្នកសម្របសម្រួលVRA 15
ភាសាដែលប្រើប្រាស់ជាទូទៅនៅក្នុង VRA 17
ការស្វែងយល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះ និងវត្តមាននៃកត្តាទាំងនេះ 21
**ជំពូក ២៖ ការត្រៀមខ្លួន និងការរៀបចំផែនការសម្រាប់VRA** 25
ការត្រៀមខ្លួនរបស់អ្នកសម្របសម្រួល 26
ពន្យល់សហគមន៍អំពីការប្រែប្រួលអាកាសធាតុដោយសង្ខេប 28
ក្រុមពិភាក្សា VRA របស់អ្នក 29
ការត្រៀមខ្លួនសម្រាប់ VRA 31
**ជំពូក ៣៖ អនុវត្ត VRA** 32
សេចក្តីពន្យល់អំពីការអនុវត្ត 33
ផ្នែកទី ១. ផ្តោតលើការប្រែប្រួល 35
ផ្នែកទី ២. ការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ 38
ផ្នែកទី ៣. ដំណើរការឧបករណ៍ទម្រង់ H 42
ផ្នែកទី ៤. ការបូកសរុប VRA 56
**ជំពូក ៤៖ ការវិភាគលទ្ធផលពី VRA** 57
ឧបករណ៍វិភាគ 58
គោលការណ៍គ្រឹះនៃការវិភាគ 62
**ជំពូក ៥៖ សរសេររបាយការណ៍ VRA** 70
ឧបសម្ព័ន្ធ ១ វាក្យស័ព្ទ និងលំហាត់ពិនិត្យសញ្ញាណនានាសម្រាប់ក្រុមអ្នកសម្របសម្រួលVRA 81
ឧបសម្ព័ន្ធ ២ ក្រាហ្វិកខ្សែនិន្នាការ និងក្រាហ្វិកដំបង អំពីកម្រិតញឹកញាប់នៃចម្លើយ ក្នុង MICROSOFT EXCEL 85

# ការសង្ខេបនៃការណែនាំសម្រាប់អ្នកប្រើប្រាស់សៀវភៅ VRA

សៀវភៅណែនាំសម្រាប់វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (សៀវភៅ VRA) នេះ មានតួនាទីជាការណែនាំដល់ភ្នាក់ងារអនុវត្តការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុ ស្ថាប័នផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន ស្ថាប័នរដ្ឋាភិបាលនិងអ្នកផ្តល់សេវាកម្មផ្នែកអភិវឌ្ឍន៍ ដើម្បីគាំទ្រភ្នាក់ងារ និងស្ថាប័នទាំងនោះ នៅក្នុងការអនុវត្តវិធីសាស្ត្រវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ និងការរៀបចំគម្រោងកាត់បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ ដែលឆ្លុះបញ្ចាំងពីតម្រូវការរបស់សហមន៍។ ឯកសារនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ឲ្យអ្នកប្រើប្រាស់នូវការណែនាំងាយៗនៅក្នុងការត្រៀមខ្លួន និងដំណើរការជាជំហានៗ ដែលបង្ហាញពីការយល់ដឹង ផលប៉ះពាល់ សមត្ថភាពបន្សាំ និងឧបសគ្គនានាចំពោះការអភិវឌ្ឍសមត្ថភាពបន្សាំ នៅក្នុងបរិបទនៃការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ ទោះបីជំហានចុងក្រោយនៃសៀវភៅនេះ អាចជាផ្នែកមួយស្មុគស្មាញជាងគេនៃ VRA ក៏ដោយ ការយល់ដឹងអំពីលទ្ធផលនៃការវាយតម្លៃបែបនេះ គឺជាគន្លឹះនៅក្នុងការរៀបចំកំណត់សកម្មភាពនានាដែលនឹងដោះស្រាយដោយផ្ទាល់ នូវភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុនៅតាមទីកន្លែងណាមួយក្នុងមូលដ្ឋាន ។

ឯកសារនេះសន្មតថា ភ្នាក់ងារអនុវត្តនៅមូលដ្ឋានពុំមានចំណេះដឹងអំពីវិធីសាស្ត្រ VRA ឡើយ និងមានត្រឹមចំណេះដឹងតិចតួចអំពីវិធីសាស្ត្រតាមបែបការចូលរួម ការប្រែប្រួលអាកាសធាតុ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ សមត្ថភាពបន្សាំ និងភាពងាយរងគ្រោះតែប៉ុណ្ណោះ។ ទោះបីឯកសារនេះបង្ហាញពីវិធី-សាស្ត្រជាជំហានៗក៏ដោយ គេមិនត្រូវចាត់ទុកឯកសារនេះថាជាការណែនាំដែលត្រូវអនុវត្តតាមទាំងស្រុងនោះទេ ប៉ុន្តែត្រឹមតែជារបៀបមួយដែលអាចអនុវត្តតាម ដើម្បីទទួលបានលទ្ធផលដែលជាទីគាប់ចិត្តសម្រាប់បំពេញតម្រូវការក្នុងមូលដ្ឋានតែប៉ុណ្ណោះ។

ជំពូកនានាក្នុងឯកសារនេះ ត្រូវបានរៀបចំឡើងដើម្បីបង្កើនចំណេះដឹងជាលក្ខណៈប្រព័ន្ធអំពី VRA ក្នុងចំណោមភ្នាក់ងារអនុវត្ត ផ្តល់ការណែនាំអំពីការត្រៀមខ្លួនសម្រាប់អនុវត្ត VRA ការអនុវត្ត VRA ដោយផ្ទាល់ ការវិភាគនិងការធ្វើរបាយការណ៍អំពីរបកគំហើញនានា។ ឯកសារនេះត្រូវបានរៀបចំឡើងតាមរបៀបមួយដែលជួយអ្នកអនុវត្ត VRA ដែលគ្មានបទពិសោធន៍ពីមុនមក នៅតែអាចយកទៅប្រើប្រាស់នៅក្នុងអំឡុងពេលអនុវត្ត VRA ផងដែរ ដោយផ្តល់ជាសំណួរគោលដើម្បីប្រើប្រាស់ឧបករណ៍ VRA និងគន្លឹះអំពីការចាត់-ចែង និងការសម្របសម្រួលនៅក្នុងដំណើរការអនុវត្ត VRA នៅក្នុងដំណាក់កាលខុសៗគ្នា។

សៀវភៅណែនាំនេះក៏មានជំពូកស្តីពីការវិភាគទិន្នន័យ VRA ផងដែរ។ នៅទីនោះ អ្នកប្រើប្រាស់នឹងឃើញមានការណែនាំអំពីដំណើរការសម្រាប់វិភាគទិន្នន័យ VRA ផងដែរ ដែលបានកំណត់“លក្ខខណ្ឌអប្បបរមា” សម្រាប់បង្កើតទស្សនទានដែលមានប្រយោជន៍ អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះ និងតម្រូវការកសាងសមត្ថភាពបន្សាំ។ ជំពូកចុងក្រោយ “ការធ្វើរបាយការណ៍អំពី VRA” មានគំរូទម្រង់របាយការណ៍សម្រាប់ណែនាំអំពីរបៀបចំរបាយការណ៍ VRA ខ្លីៗ ដែលមានប្រយោជន៍។ សូមអានរូបទី ១ អំពីទិដ្ឋភាពរួមនៃជំពូកនានាក្នុងសៀវភៅ VRA នេះ។

## លំដាប់លំដោយនៃជំពូកនានាក្នុងសៀវភៅ VRA សម្រាប់ភ្នាក់ងារអនុវត្តនៅមូលដ្ឋាន




រូបទី ១៖ ទិដ្ឋភាពរួមនៃជំពូក និងលំដាប់លំដោយនៃ"សៀវភៅ VRA សម្រាប់ភ្នាក់ងារអនុវត្តនៅមូលដ្ឋាន"

# ពាក្យបំព្រួញសំខាន់ៗដែលប្រើប្រាស់

| | | |
|---|---|---|
| CBA | Community Based Adaptation | ការបន្សាំរបស់សហគមន៍ |
| CBO | Community Based Organization | អង្គការសហគមន៍មូលដ្ឋាន |
| CCBAP | Cambodia Community Based Adaptation Programme | កម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុ**នៅ**សហគមន៍ |
| CDP | Commune Development Plan | ផែនការអភិវឌ្ឍន៍ឃុំ |
| CIP | Commune Investment Programme | កម្មវិធីវិនិយោគឃុំ |
| FGD | Focus Group Discussion | ការពិភាក្សាក្រុមគោលដៅ |
| NGO | Non Government Organization | អង្គការមិនមែនរដ្ឋាភិបាល |
| Q1 | H-Form Question 1 | សំណួរ ១ ក្នុងទម្រង់ H |
| Q2 | H-Form Question 2 | សំណួរ ២ ក្នុងទម្រង់ H |
| Q3 | H-Form Question 1 | សំណួរ ៣ ក្នុងទម្រង់ H |
| Q4 | H-Form Question 1 | សំណួរ ៤ ក្នុងទម្រង់ H |
| VRA | Vulnerability Reduction Assessment | ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ |

# ការប្រែប្រួលអាកាសធាតុ សហគមន៍ និងការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ

សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកភាគច្រើនលើកសិកម្ម ដោយបីភាគបួននៃចំនួនប្រជាពលរដ្ឋសរុបរស់នៅតាមទីជនបទ ហើយអ្នកទាំងនោះភាគច្រើនធ្វើកសិកម្មដោយពឹងផ្អែកលើទឹកភ្លៀង ដែលតាមធម្មតាទទួលផលស្រូវបានតែម្តងក្នុងមួយឆ្នាំ។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើកម្ពុជា ជាពិសេស កសិកម្ម និងដំណាំស្រូវ ត្រូវបានទស្សន៍ទាយថា នឹងមានឥទ្ធិពលអវិជ្ជមានមកលើផលិតកម្មស្បៀង និងសន្តិសុខស្បៀងនៅតាមជនបទ។ ការថយចុះនៃកសិផលអាចនាំឲ្យមានភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ដែលបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានមកលើស្ថានភាពសេដ្ឋកិច្ចជារួមរបស់កម្ពុជា និងបង្អាក់សមិទ្ធផលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

បច្ចុប្បន្ននេះ ការប្រែប្រួលអាកាសធាតុកំពុងគំរាមកំហែងដែលអាចធ្វើឲ្យខូចសមិទ្ធផលនៃការអភិវឌ្ឍន៍ដែលកម្ពុជាសម្រេចបានកន្លងមក។ ភាពអយុត្តិធម៌នៃការប្រែប្រួលអាកាសធាតុបង្កជាផលប៉ះពាល់មកលើសហគមន៍ក្រីក្រក្នុងកម្រិតវិសមាមាត្រ ដែលមានធនធានក្នុងកម្រិតកំណត់ ដើម្បីពុះពារចំពោះផលវិបាកអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ កសិករនៅតាមមូលដ្ឋានទូទាំងប្រទេសកម្ពុជា បានកត់សំគាល់ឃើញថា អាកាសធាតុមានការប្រែប្រួលច្រើន។ ពួកគេរាយការណ៍ថា ក្នុងរយៈពេល ៤០ឆ្នាំកន្លងមកនេះ ពួកគេកាន់តែងាយរងគ្រោះខ្លាំងឡើងៗ ប្រឈមមុខនឹងទឹកជំនន់ គ្រោះរាំងស្ងួត ការប្រែប្រួលរដូវកាល និងសីតុណ្ហភាពមិនប្រក្រតី។ ក្នុងចំណោមការប្រែប្រួលទាំងនេះ កសិករមានការព្រួយបារម្ភខ្លាំងអំពីផលប៉ះពាល់នៃគ្រោះរាំងស្ងួត ដែលកើតមានកាន់តែញឹកញាប់ និងអូសបន្លាយពេលកាន់តែវែង ព្រមទាំងការបំផ្លាញដោយទឹកជំនន់កាន់តែខ្លាំងជាមុន។ មុខសញ្ញាគ្រោះថ្នាក់នៃអាកាសធាតុទាំងនេះបន្តធ្វើឲ្យគ្រួសារ និងសហគមន៍នានាបាត់បង់ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ជាសារវន្តសម្រាប់ការរស់រានមានជីវិត និងសមត្ថភាពរបស់ពួកគេសម្រាប់បន្សាំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ កសិករជាច្រើនមើលឃើញថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាដែលមិនអាចបញ្ឈប់បាន ដែលនឹងរុញច្រានពួកគេឲ្យធ្លាក់ក្នុងភាពក្រីក្រ។

នៅក្នុងសេណារីយ៉ូដ៏ប្រឈមបំផុតនេះ ស្ត្រី មនុស្សចាស់ និងជនជាតិដើមភាគតិច ត្រូវគេរំពឹងថានឹងរ៉ាប់រងបន្ទុកធំធេងនៃ″ការប្រែប្រួលអាកាសធាតុ″ ដោយសារស្ថានភាពសង្គមរបស់ពួកគេ។ ជាការឆ្លើយតប សហគមន៍មូលដ្ឋានពឹងផ្អែកលើក្រុមមនុស្សក្នុងសង្គម ដូចជា ក្រុមជួយខ្លួនឯង និងក្រុមសន្សំ ដើម្បីទទួលបានកម្ចីខ្នាតតូច សម្រាប់ផ្តួចផ្តើមសកម្មភាពសេដ្ឋកិច្ចដែលជាការបំពេញបន្ថែម ឬ ធ្វើឲ្យការចិញ្ចឹមជីវិតរបស់ពួកគេមានស្ថិរភាពនៅចំពោះមុខផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋក្រីក្រភាគច្រើនបំផុតនៅតាមជនបទពឹងផ្អែកលើធនធានធម្មជាតិ ជាមធ្យោបាយសម្រាប់ដោះស្រាយបញ្ហានឹងការប្រែប្រួលអាកាសធាតុ ប៉ុន្តែធនធានទាំងនេះក៏ងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុផងដែរ និងស្ថិតក្រោមការគំរាមកំហែងបន្ថែមទៀតពីទម្លាប់នៃការប្រើប្រាស់ដីនិងការគ្រប់គ្រងដីបច្ចុប្បន្ន។

នៅក្នុងការដោះស្រាយស្ថានភាពប្រឈមដែលបានកត់សំគាល់ខាងលើ កម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅសហគមន៍(CCBAP) ត្រូវបានប្រកាសដាក់ឲ្យដំណើរការ ក្នុងបំណងកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនសមត្ថភាពបន្សាំរបស់សហគមន៍គោលដៅ ដើម្បីគ្រប់គ្រងហានិភ័យបន្ថែមនៃការប្រែ-ប្រួលអាកាសធាតុ។ កម្មវិធី CCBAP មានគោលដៅកាត់បន្ថយភាពងាយរងគ្រោះនៅក្នុងវិស័យកសិកម្មនៅកម្ពុជា ដែលបណ្តាលពីការប្រែប្រួលបង្កដោយអាកាសធាតុមកលើធនធានទឹក។ កម្មវិធីនេះក៏មានគោលបំណងពង្រឹងសមត្ថភាពរបស់សហគមន៍គោលដៅ នៅក្នុងការកសាងភាពធន់ ការបញ្ជ្រាបវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ ព្រមទាំងចងក្រងទម្លាប់ល្អនៅក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុផងដែរ។

មេរៀននានាដែលទទួលបានពីការអនុវត្តគម្រោងចំនួន ៧១ នៅក្នុងខេត្តទាំង ២១ នៅទូទាំងប្រទេសកម្ពុជាបច្ចុប្បន្ននេះ កំពុងត្រូវបានផ្សព្វផ្សាយ ដើម្បីជម្រុញឲ្យមានការចម្លងយកគំរូអនុវត្តតាមដោយជោគជ័យរបស់សហគមន៍ និងការរួមបញ្ចូលមេរៀនទាំងនេះ ទៅក្នុងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ដំណើរការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) គឺជាផ្នែកមួយនៃដំណើរការអនុវត្តកម្មវិធី CCBAP ដែលត្រូវបានបង្កើតឡើង ដើម្បីជួយសហគមន៍នានាក្នុងការពង្រឹងការយល់ដឹងរបស់ពួកគេអំពីភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ និងសមត្ថភាពរបស់ពួកគេក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ VRA ក៏ត្រូវបានបង្កើតឡើងដើម្បីវាស់ស្ទង់ឥទ្ធិពលនៃគម្រោងបន្សាំរបស់សហគមន៍នៅមូលដ្ឋានផងដែរ(CBA)។ VRA បានផ្អែកលើសំណួរសំខាន់ៗចំនួន ៤ ដែលជាសូចនាករ រៀបចំឡើងក្នុងគោលដៅស្រង់យកបញ្ហាដែលពាក់ព័ន្ធនៅមូលដ្ឋាន ដែលជាស្នូលនៃការយល់ដឹងអំពីភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ។ គ្រប់ចម្លើយចំពោះសំណួរទាំងនេះ ត្រូវបានធ្វើឡើងនៅក្នុងដំណើរការនៃការវិភាគ ដែលនាំទៅរកការផ្តល់អនុសាសន៍ជាអាទិភាព សម្រាប់កសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងគោលដៅកាត់បន្ថយភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុនៅតាមមូលដ្ឋាន។ នៅទីបំផុតព័ត៌មាន និងអនុសាសន៍ពី VRA នឹងត្រូវយកទៅបញ្ចូល និងអនុវត្តនៅក្នុងក្របខ័ណ្ឌនៃផែនការអភិវឌ្ឍន៍ឃុំ (CDPs) និងកម្មវិធីវិនិយោគឃុំ (CIPs)។

# ការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ និងការចូលរួម

## តើការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) ជាអ្វី?

និយមន័យ VRA: **VRA** គឺជាឧបករណ៍ប្រមូលព័ត៌មានដែលផ្អែកលើទស្សនៈផ្ទាល់ខ្លួន ដែលអាចប្រើប្រាស់ដើម្បីបង្កើតទិន្នន័យគោលនៃភាពងាយរងគ្រោះ និងប្រើប្រាស់សម្រាប់តាមដាន និងវាយតម្លៃសកម្មភាពបន្សាំរបស់សហគមន៍ និងវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបានសមិទ្ធផលនានារបស់គម្រោង។

**VRA** គឺជាវិធីសាស្ត្រមួយដែលអាចបត់បែន និងត្រូវបានរៀបចំឡើង ដើម្បីស្វែងយល់ និងបង្កើត ទិន្នន័យគោលដែលទាក់ទងនឹងភាពងាយរងគ្រោះ និងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ អា-ស្រ័យលើរបៀបអនុវត្ត និងវិភាគVRA វិធីនេះអាចផ្តល់សេចក្តីពិស្តារជាច្រើន អំពីភាពខុសគ្នានៃភាពងាយ រងគ្រោះរវាងស្ត្រី បុរស កសិករ មនុស្សចាស់ និងក្រុមប្រជាសាស្ត្រដទៃទៀត។ VRA ក៏មានអត្ថប្រយោជន៍ផងដែរនៅទូទាំងវដ្តនៃគម្រោង។ នៅក្នុងដំណាក់កាលរៀបចំគម្រោង VRAផ្តល់ណែនាំដល់ភ្នាក់ងារប្រតិបត្តិ ក្នុងការកំណត់ និងដាក់បញ្ចូលសកម្មភាពកាត់បន្ថយភាពងាយរងគ្រោះនានា និងភាពរីកចម្រើនឆ្ពោះទៅសម្រេចបានគោលដៅរបស់គម្រោង។ ក្នុងន័យនេះ VRA មានប្រយោជន៍ជាពិសេសសម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការសហគមន៍មូលដ្ឋាន ដែលមានការងារទាក់ទងដោយផ្ទាល់ជាមួយសហគមន៍គោលដៅរបស់ខ្លួន នៅមុន ឬក្នុងដំណាក់កាលរៀបចំគម្រោងសំណើ។ ប្រសិនបើគ្មានការប្រើប្រាស់ដំណើរការ VRA នៅមុនពេលលើកស្នើសកម្មភាព ឬ លទ្ធផលរំពឹងទុកទេនោះ គេអាចប្រើប្រាស់ដំណើរការនេះនៅក្នុងដំណាក់កាលចាប់ផ្តើមអនុវត្តគម្រោង ដើម្បីរៀបចំ និងបង្កើតសូចនាករបឋម ដែលជាវិធីមួយសម្រាប់ពិនិត្យប្រសិទ្ធភាព និងដើម្បីផ្តោតលើសកម្មភាព និងលទ្ធផលរំពឹងទុក។ ក្នុងន័យនេះ ដំណើរការនេះមានប្រយោជន៍ជាពិសេសសម្រាប់ស្ថាប័ននានានៃរដ្ឋាភិបាលនៅថ្នាក់ជាតិ និងស្ថាប័នម្ចាស់ជំនួយធំៗ ដែលមិនទំនងជាបង្កើតគម្រោងដោយខ្លួនឯងដែលអាចទាក់ទងផ្ទាល់ជាមួយសហគមន៍ឡើយ។

គេអាចប្រើប្រាស់ VRA ជាឧបករណ៍តាមដាន និងវាយតម្លៃដោយផ្អែកលើទស្សនៈផ្ទាល់ខ្លួន ដើម្បីកំណត់អំពីជោគជ័យនៃសកម្មភាពនានា និងវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបានលទ្ធផលនានារបស់គម្រោង។ សហគមន៍មូលដ្ឋាន ជាពិសេស គណៈកម្មាធិការរៀបចំផែនការអភិវឌ្ឍន៍ឃុំក៏អាចប្រើប្រាស់VRA ដើម្បីគាំទ្រដល់ដំណើរការនៃការអង្កេត និងការរៀនសូត្ររបស់ខ្លួនផងដែរ។ លទ្ធផលនានា នឹងអាចប្រើ-ប្រាស់សម្រាប់គ្រោងសកម្មភាពរួមគ្នាស្តីពីការបន្សាំ ឬ ដោយការធានាថា រាល់អន្តរាគមន៍អភិវឌ្ឍន៍ឃុំនានាបានរួមចំណែកកសាងភាពធន់នៅមូលដ្ឋាន ជាជាងបង្កើនផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

## ហេតុអ្វីបានជាចូលរួមនៅក្នុង VRA ?

ការយល់ដឹងអំពីរបៀបអនុវត្ត VRA ឬវិធីសាស្ត្រតាមបែបផែននៃការចូលរួមដទៃទៀត មានប្រយោជន៍ជាពិសេស សម្រាប់ភ្នាក់ងារអនុវត្តតាមមូលដ្ឋានដែលត្រូវដឹងថា តើវិធីនៃការចូលរួមគឺជាអ្វី ហេតុអ្វីប្រើប្រាស់វិធីនេះ អត្ថប្រយោជន៍ដែលវិធីនេះនាំមក និងតើអាចមានជម្រើសផ្សេងអ្វីខ្លះ។ វិធីនៃការចូលរួមបានកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ជាការឆ្លើយតបមួយទៅនឹងវិធាន"ពីលើមកក្រោម" ដែលនៅពេលនោះត្រូវបានប្រើប្រាស់យ៉ាងច្រើននៅក្នុងការរៀបចំ និងការអនុវត្តគម្រោងអភិវឌ្ឍន៍។ វិធានទាំងនេះទំនងជាពាក់ព័ន្ធជាមួយអ្នកជំនាញការពីស្ថាប័នខាងក្រៅ ដែលចំណាយពេលខ្លីនៅតាមមូលដ្ឋាន ដើម្បីសំភាសន៍អ្នកទទួលផល និងបន្ទាប់មករៀបចំប្លង់គម្រោងដោយផ្អែកលើជំនាញរបស់ពួកគេ។ ទោះបីវិធីនេះនាំមកនូវជោគជ័យនៅតាមទីកន្លែងខ្លះៗក៏ដោយ វាបាននាំទៅរកវិធាន "គំរូមួយសម្រាប់គ្រប់ករណី" សម្រាប់ការងារអភិវឌ្ឍន៍ ដែលក្នុងនោះ ចំណេះដឹង ប្រពៃណី និងជំនាញនៅមូលដ្ឋាន ត្រូវបានគេមើលរំលង។ ប្រការនេះក៏មានន័យផងដែរថា សហគមន៍មូលដ្ឋានមានឥទ្ធិពលតិចតួចមកលើគម្រោងនានាដែលពួកគេ គឺជាគោលដៅនៃការទទួលប្រយោជន៍។ ជាលទ្ធផល ពួកគេមានភាពម្ចាស់ការ ឬ ការលើកទឹកចិត្តតិចតួចក្នុងការបន្តនិរន្តរភាពគម្រោង នៅក្រោយពេលដែលអន្តរាគមន៍នោះបានបញ្ចប់ទៅ។

តើ VRA មានលក្ខណៈពិសេសអ្វីខ្លះ?

*ផ្តោតលើការប្រែប្រួលអាកាសធាតុ៖* VRA ផ្តោតលើការយល់ដឹងអំពីថា តើការប្រែប្រួលអាកាសធាតុជាអ្វី និងថាតើវាមានឥទ្ធិពលបែបណាមកលើការរស់នៅ និងការចិញ្ចឹមជីវិតរបស់សហគមន៍គោលដៅ។ វិធីនេះពិនិត្យមើលមុខសញ្ញាគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ ភាពងាយរងគ្រោះ និងសមត្ថភាពបន្សាំ ក្នុងបំណងកសាងភាពធន់សម្រាប់ទៅអនាគត។

*សង្កត់ធ្ងន់លើការរៀនសូត្ររួមគ្នា៖* វិធីសាស្ត្រ VRA ត្រូវបានរៀបចំឡើង ដើម្បីធ្វើឲ្យរបៀបវារៈនៃការស្រាវជ្រាវរបស់ខ្លួន មានតុល្យភាពជាមួយគោលបំណងនៃការរៀនសូត្រ តាមរយៈការសន្ទនាក្នុងចំណោមសហគមន៍។ វិធីនេះក៏ប្រើប្រាស់ដំណើរការរៀនសូត្រផងដែរ ដើម្បីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធខុសៗគ្នាផងដែរ។

*ពិនិត្យមើលបរិយាកាសអំណោយផល៖* អាជ្ញាធរមូលដ្ឋាន និងគណៈកម្មាធិការអភិវឌ្ឍន៍ ដើរតួនាទីសំខាន់មួយនៅក្នុងការកំណត់សមត្ថភាពរបស់ប្រជាពលរដ្ឋនៅក្នុងការបន្សាំ។ ដំណើរការ VRA ផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធទាំងអស់ដែលត្រូវប្រមូលផ្តុំកិច្ចប្រឹងប្រែងអភិវឌ្ឍន៍របស់ខ្លួន ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៅមូលដ្ឋាន។

ការចូលរួមនៅក្នុងដំណើរការ VRA តំណាងឲ្យការផ្ទេរអំណាច និងការធ្វើសេចក្តីសម្រេច ពីភ្នាក់ងារអនុវត្តការងារអភិវឌ្ឍន៍ មកឲ្យសហគមន៍។ វិធីសាស្ត្រតាមបែបចូលរួម មានដូចជា VRA ត្រូវបានរៀបចំ

ឡើងដើម្បីជួយសហគមន៍ឲ្យប្រើប្រាស់ចំណេះដឹងរបស់ភ្នាក់ងារអនុវត្តមកពីស្ថាប័នខាងក្រៅនៅក្នុងកិច្ចប្រឹងប្រែងធ្វើសេចក្តីសម្រេចរបស់ពួកគេ ជាជាងផ្តល់ជាមូលដ្ឋានសម្រាប់ការធ្វើអន្តរាគមន៍។ ជាជំនួសមកវិញ ភ្នាក់ងារអនុវត្តនៅតាមមូលដ្ឋាន ដើរតួជាអ្នកសម្របសម្រួលការពិភាក្សាជាក្រុម ដែលមានគោលដៅវិភាគបញ្ហារួមគ្នានៅក្នុងសហគមន៍។ ជាលទ្ធផល សហគមន៍យល់អំពីប្រភេទនៃបញ្ហា ហើយភ្នាក់ងារអភិវឌ្ឍន៍ក៏យល់ដឹងពីកម្រិតចំណេះដឹងនៅក្នុងសហគមន៍ផងដែរ និងរបៀបប្រើប្រាស់ចំណេះដឹងទាំងនេះ ដើម្បីសម្រេចលទ្ធផលគម្រោងផងដែរ។ ជាលទ្ធផល សហគមន៍បានពង្រឹងភាពអង់អាចដោយសារពួកគេមានឥទ្ធិពលដោយផ្ទាល់មកលើការអនុវត្តគម្រោង ដែលម្ចាស់ជំនួយផ្តល់មូលនិធិមកដែលពួកគេ គឺជាអ្នកទទួលផលនៅក្នុងមូលដ្ឋាន។

### ទម្លាប់ល្អនៅក្នុងការចូលរួម[1]

ទោះបីជាគ្មានក្រឹត្យក្រមសម្រាប់ការអនុវត្តតាមបែបផែននៃការចូលរួមក៏ដោយ គេមានគោលការណ៍ដែលគួរតែផ្តល់ជាការណែនាំសមស្របដល់ភ្នាក់ងារអនុវត្តនៅមូលដ្ឋានដើម្បី៖

- ✓ ដឹងអំពីវិធីសាស្ត្រនានា ដូចជា ការពិភាក្សាក្រុមគោលដៅ (FGDs) និងប្រព័ន្ធនៃការរៀនសូត្រ ព្រមទាំងទំនាក់ទំនងគ្នាទៅវិញទៅមក តាមរយៈការពិភាក្សាដែលដឹកនាំដោយអ្នកសម្របសម្រួល
- ✓ សង្កត់ធ្ងន់លើគោលគំនិត និងទស្សនៈរបស់អ្នកចូលរួម និងធានាអះអាងឡើងវិញថា គំនិតនិងទស្សនៈទាំងនោះ សុទ្ធតែត្រឹមត្រូវ និងមានប្រយោជន៍
- ✓ ការរៀនសូត្រជាក្រុម បង្កើតឲ្យមានបរិយាកាសអំណោយផលសម្រាប់ទំនាក់ទំនងរវាងសមាជិកសហគមន៍ ភ្នាក់ងារអនុវត្តការងារអភិវឌ្ឍន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវាអភិវឌ្ឍន៍
- ✓ ធានាឲ្យមានភាពបត់បែនបាននៃវិធីនានាដែលប្រើប្រាស់ ដើម្បីឲ្យត្រូវគ្នាជាមួយតម្រូវការរបស់សហគមន៍ និងបរិបទរបស់ពួកគេ
- ✓ របៀបវារៈសម្រាប់ការអនុវត្ត VRA ត្រូវសម្របសម្រួលដោយភ្នាក់ងារអនុវត្តការងារអភិវឌ្ឍន៍ ដោយផ្អែកលើតម្រូវការរបស់សហគមន៍
- ✓ ការជជែកវែកញែក ការពិភាក្សា និងវិភាគបញ្ហានានា ដែលនាំទៅរកការព្រមព្រៀង និងសកម្មភាពដែលមាននិរន្តរភាព
- ✓ ការកសាងសមត្ថភាពរបស់សហគមន៍មូលដ្ឋានដើម្បីលើកទឹកចិត្តពួកគេ និងពង្រឹងការទទួលខុសត្រូវដើម្បីឲ្យគិតពីប្រយោជន៍រួម។

---

[1] ស្រង់ចេញពី៖ Bradley, D and Schneider, H (2004) Participatory Approaches: A Facilitator's Guide, London, Voluntary Service Overseas.

# ជំពូក ១
# ដំណើរការចាប់ផ្តើម

**សេចក្តីសង្ខេប**

ជំពូកនេះផ្តល់ចំណេះដឹងសំខាន់ៗដល់អ្នកសម្របសម្រួល VRA ដែលនឹងជួយកែលម្អការអនុវត្តន៍ និងគុណភាពនៃទិន្នន័យ VRA ដែលទទួលបាន។ ជំពូកនេះរៀបរាប់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមអ្នកសម្របសម្រួល VRA និងពង្រឹងចំណេះដឹងរបស់ពួកគេ អំពីសញ្ញាណទូទៅនៃការប្រែប្រួលអាកាសធាតុ និងវាក្យស័ព្ទដែលប្រើប្រាស់នៅក្នុងពេលអនុវត្តVRA។ ជំពូកនេះក៏មានគោលដៅផ្តល់ឲ្យអ្នកសម្រប-សម្រួល VRA ដែលមានមូលដ្ឋានចំណេះដឹងរួចមកហើយផងដែរ អំពីថាតើវិស័យខុសៗគ្នារងការប៉ះពាល់បែបណាពីការប្រែប្រួលអាកាសធាតុ។ នេះជាប្រការសំខាន់មួយសម្រាប់ការយល់ដឹងអំពីបរិបទរបស់អ្នកចូលរួមក្នុង VRA ទិន្នន័យដែលទទួលបាន និងដើម្បីវិភាគទិន្នន័យនេះ។

ជំពូកនេះក៏រួមបញ្ចូលលំហាត់សម្រាប់ក្រុមការងារវីអរអេផងដែរ ដើម្បីពិនិត្យមើលការយល់ដឹងរបស់ពួកគេ អំពីសញ្ញាណនៃការប្រែប្រួលអាកាសធាតុ ដែលជាលក្ខខណ្ឌចាំបាច់ មុននឹងបន្តទៅជំពូកបន្ទាប់។

គោលបំណងនានាក្នុងជំពូកនេះ៖

- ✓ អធិប្បាយអំពីតួនាទី និងការទទួលខុសត្រូវខុសៗគ្នារបស់អ្នកសម្របសម្រួល VRA ដែលចាំបាច់នៅក្នុងការចាត់ចែងរៀបចំការអនុវត្ត VRA
- ✓ បង្កើនចំណេះដឹងរបស់ភ្នាក់ងារអនុវត្ត VRA អំពីសញ្ញាណនៃការប្រែប្រួលអាកាសធាតុ និងវាក្យស័ព្ទដែលមានប្រើប្រាស់ជាទូទៅនៅក្នុងការបង្កើតការយល់ដឹងអំពី VRA ដំណើរការសម្របសម្រួល និងការធ្វើរបាយការណ៍
- ✓ ផ្តល់ប្រវត្តិអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងភាពងាយរងគ្រោះ ដែលអាចបង្ហាញឲ្យឃើញនៅថ្នាក់មូលដ្ឋាន ដើម្បីកែលម្អការសម្របសម្រួល VRA និងការរៀបចំព័ត៌មានពេញលេញជាងនេះអំពីស្ថានភាព VRA ។

# បង្កើតក្រុមអ្នកសម្របសម្រួល VRA

លំហាត់ VRA ទាមទារឲ្យមានយ៉ាងហោចណាស់អ្នកសម្របសម្រួលចំនួន ២នាក់ សម្រាប់ក្រុមគោលដៅនីមួយៗ ក្នុងនោះម្នាក់លើកសំណួរ និងលើកទឹកចិត្តឲ្យមានការពិភាក្សា និងម្នាក់ទៀតកត់ត្រាចម្លើយ។ ដូច្នេះ អ្នកសម្របសម្រួលទាំងពីររូបត្រូវតែយល់ពីសញ្ញាណសំខាន់ៗនៃការប្រែប្រួលអាកាសធាតុ វាក្យស័ព្ទដែលពាក់ព័ន្ធ តើសញ្ញាណទាំងនោះមានការពាក់ព័ន្ធបែបណាទៅនឹងផលប៉ះពាល់មកលើការចិញ្ចឹមជីវិតនៅជនបទ និងសុខុមាលភាពរបស់សហគមន៍ និងត្រូវយល់ដឹងពេញលេញអំពីដំណើរការVRA។ ប្រការសំខាន់គឺថា អ្នកសម្របសម្រួលទាំងពីររូបត្រូវតែអាចចូលរួម និងធានាថា ព័ត៌មានដែលទទួលបានសុទ្ធតែពាក់ព័ន្ធទៅនឹងសំណួរដែលបានលើកឡើង ហើយអ្នកចូលរួមទាំងអស់នៅក្នុងលំហាត់ជាក្រុម និងការពិភាក្សាក្រុមគោលដៅបានឮ និងមានចំណាប់អារម្មណ៍ថា ពួកគេអាចចូលរួមយ៉ាងមានខ្លឹមសារ។ ខាងក្រោមនេះគឺជាបញ្ជីត្រួតពិនិត្យការងារខ្លី ដែលក្រុម VRA របស់អ្នកគួរប្រើប្រាស់សម្រាប់ផ្ទៀងផ្ទាត់ ដើម្បីត្រៀមខ្លួនរួចជាមុន។ ចូរកត់សំគាល់ថា អ្នកសម្របសម្រួលគួរបែងចែកតួនាទី និងការទទួលខុសត្រូវរួមគ្នា។

**ចំណេះដឹងរបស់ក្រុម**

- ✓ មានចំណេះដឹងអំពីទីកន្លែងគោលដៅ និងអ្នកចូលរួមក្នុង VRA ដូចជា ប្រជាសាស្ត្រ ប្រភពចំបងៗនៃការចិញ្ចឹមជីវិត កិច្ចផ្តួចផ្តើមអភិវឌ្ឍន៍នានា ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ
- ✓ ក្រុម VRA បានបញ្ចប់លំហាត់ស្តីពីវាក្យស័ព្ទ និងសញ្ញាណសំខាន់ៗ
- ✓ បានពិគ្រោះយោបល់ជាមួយសហគមន៍គោលដៅ និងបានពន្យល់ដោយសង្ខេបដល់សហគមន៍គោលដៅ អំពីដំណើរការ VRA និងគោលបំណងនៃដំណើរការនេះ

តួនាទីរបស់ប្រធានក្រុមអ្នកសម្របសម្រួល

- ✓ ធានាថាអ្នកសម្របសម្រួលទាំងអស់យល់ពីបំណងនៃឧបករណ៍ VRA នីមួយៗ ព័ត៌មានដែលត្រូវប្រមូលយក និងថាតើព័ត៌មានទាំងនោះនឹងត្រូវប្រើប្រាស់ដោយរបៀបណា
- ✓ ធានាថា អ្នកសម្របសម្រួលម្នាក់ៗ អាចកំណត់អត្តសញ្ញាណក្រុមរបស់ពួកគេបានច្បាស់លាស់
- ✓ ធានាថា ព័ត៌មានដែលប្រមូលបាន សុទ្ធតែពាក់ព័ន្ធនឹងសំណួរដែលបានសួរ
- ✓ ផ្តល់ការត្រួតពិនិត្យ ការកំណត់ពេល និងជួយដល់អ្នកសម្របសម្រួលផ្សេងទៀតនៃក្រុម VRA នៅពេលចាំបាច់

## តួនាទីរបស់អ្នកសម្របសម្រួលក្នុងក្រុម

- ✓ ពិនិត្យមើលឧបករណ៍ VRA នីមួយៗជាមួយអ្នកចូលរួម ដូចជា គោលបំណងនៃឧបករណ៍ VRA នីមួយៗ ព័ត៌មានដែលត្រូវប្រមូលយក និងតើព័ត៌មាននេះនឹងត្រូវប្រើប្រាស់ដោយរបៀបណា
- ✓ ជួយអ្នកចូលរួមធ្វើការវាយតម្លៃទិន្នន័យ និងរៀបចំជាសំណួរចាំបាច់ទូទាំងដំណើរការ VRA នេះ
- ✓ ធានាឲ្យមានការចូលរួមប្រកបដោយខ្លឹមសារ និងពិភាក្សាជាមួយអ្នកចូលរួមទាំងអស់ស្របតាមកិច្ចការ/សំណួរ/ទិន្នន័យដែលត្រូវប្រមូលយក
- ✓ ធានាថាព័ត៌មានដែលបានប្រមូលយក សុទ្ធតែពាក់ព័ន្ធទៅនឹងសំណួរដែលបានសួរ
- ✓ បញ្ចប់សកម្មភាពនៃក្រុម VRA នីមួយៗ ជាមួយការកត់សំគាល់វិជ្ជមាន។

## តួនាទីរបស់អ្នកកត់ត្រា

- ✓ ធានាថារាល់សម្ភារៈ ក្រាហ្វិក និងទម្រង់ឯកសារ ត្រូវបានចាត់ចែង និងត្រៀមជាស្រេចសម្រាប់ប្រើប្រាស់
- ✓ ធានាថាព័ត៌មានដែលប្រមូលបានសុទ្ធតែពាក់ព័ន្ធ ទៅនឹងសំណួរដែលបានសួរ និងបានកត់ត្រាច្បាស់លាស់
- ✓ សុំការបំភ្លឺពីអ្នកចូលរួមនៅចុងសកម្មភាពនីមួយៗ

# ភាសាដែលប្រើប្រាស់ជាទូទៅនៅក្នុង VRA[2]

ខាងក្រោមនេះជាការបង្ហាញជូននូវវាក្យស័ព្ទ និងសញ្ញាណសំខាន់ៗដែលមានប្រើប្រាស់នៅក្នុងការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ការយល់ដឹងអំពីភាសាងាយៗទាំងនេះ នឹងជួយអ្នកសម្របសម្រួល VRA ក្នុងការធានាថា ការពិភាក្សាក្នុងក្រុមគោលដៅផ្តោតចំ ប្រធានបទ ហើយការវិភាគ VRA បង្កើតចេញជាវិធានដែលផ្តោតលើការកាត់បន្ថយភាពងាយរងគ្រោះ។

## ការប្រែប្រួលអាកាសធាតុ

នៅពេលគិតអំពី"ការប្រែប្រួលអាកាសធាតុ" ត្រូវចាត់ទុកវាថាជាការប្រែប្រួលរយៈពេលវែងនៃរបបធាតុអាកាស ដែលកើតឡើងនៅក្នុងរយៈពេលវែង ដូចជា ច្រើនទសវត្សរ៍ រហូតដល់ជាច្រើនលានឆ្នាំ។ វាអាចជាការប្រែប្រួលលក្ខខណ្ឌមធ្យមនៃធាតុអាកាស ឬរបាយធាតុអាកាស ដែលទាក់ទងនឹងព្រឹត្តិការណ៍នានា ដូចជា ព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីកាន់តែច្រើន ឬតិច។ ការប្រែប្រួលអាកាសធាតុក៏អាចកំណត់ត្រឹមតំបន់ណាមួយជាក់លាក់ ឬអាចកើតឡើងនៅទូទាំងផែនដីទាំងមូលផងដែរ។ ប្រការសំខាន់គឺត្រូវដឹងថា ការប្រែប្រួលអាកាសធាតុ ឆ្លុះបញ្ចាំងពីការប្រែប្រួលតុល្យភាពនៃប្រព័ន្ធអាកាសធាតុនៃផែនដី។

## ធាតុអាកាស និងអាកាសធាតុ

ព្រឹត្តិការណ៍ធាតុអាកាស គឺជាការប្រែប្រួលក្នុងរយៈពេលខ្លី(ច្រើននាទីដល់ច្រើនខែ)នៅក្នុងបរិយាកាសដូចជា សីតុណ្ហភាព ទឹកភ្លៀង ពពក រហូតដល់ខ្យល់។ល។ អាកាសធាតុ គឺជាកម្រិតមធ្យមនៃធាតុអាកាសនៅក្នុងរយៈពេលវែង និងមានវិសាលភាពធំពោលគឺ អាកាសធាតុ គឺជាអ្វីដែលអ្នករំពឹងទុក ធាតុអាកាស គឺជាអ្វីដែលអ្នកបានឃើញ។

## ការកើនឡើងកំដៅផែនដី/ការកើនឡើងកម្តៅសកល[3]

ការកើនឡើងកំដៅផែនដី គឺជាពាក្យមួយដែល ពិពណ៌នាអំពីការកើនឡើងនៃសីតុណ្ហភាពមធ្យមនៅក្នុងបរិយាកាសនៃផែនដី និងមហាសមុទ្រ។ ចាប់តាំងពីដើមសតវត្សរ៍ទី២០មក សីតុណ្ហភាពមធ្យមលើផែនដីបានកើនឡើងប្រមាណ ០,៨°C ក្នុងនោះប្រមាណពីរភាគបីនៃកំណើននេះបានកើតឡើងចាប់ពីឆ្នាំ ១៩៨០មក។ អ្នកវិទ្យាសាស្ត្រមានការជឿជាក់ច្រើនជាង៩០%ថា ការឡើងកំដៅផែនដីបានបង្កដោយ

---

[2] ស្រង់ចេញពី៖ Solar, R. 2014. Building Climate Resilience: A Training Manual for Community Based Climate Change Adaptation. Regional Climate Change Adaptation Knowledge Platform for Asia, Partner Report Series No. 14. Regional Resource Centre for Asia and the Pacific (RRC.AP), Asian Institute of Technology, Thailand.

[3] http://en.wikipedia.org/wiki/Global_warming

កំណើនកំហាប់ឧស្ម័នផ្ទះកញ្ចក់ ដែលកើតចេញពីសកម្មភាពរបស់មនុស្ស ដូចជា ចំហេះឥន្ធនៈផូស៊ីល និងការបាត់បង់ព្រៃឈើ។

**ផលផ្ទះកញ្ចក់ និងឧស្ម័នផ្ទះកញ្ចក់**

ផែនដីទទួលថាមពលពីព្រះអាទិត្យក្នុងរូបភាពជាកាំរស្មីព្រះអាទិត្យ។ ជាលទ្ធផល ផ្ទៃផែនដីស្រូបយកថាមពលទាំងនេះខ្លះៗ និងឡើងកំដៅ។ ផែនដីចុះត្រជាក់មកវិញ ដោយបញ្ចេញថាមពលតាមទម្រង់ខុសៗគ្នា។ ប៉ុន្តែមុននឹងថាមពលទាំងអស់នេះអាចគេចចេញទៅក្នុងលំហខាងក្រៅ ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសស្រូបយក និងចាំងផ្លាតថាមពលនេះខ្លះត្រឡប់មកផែនដីវិញ ដែលធ្វើឲ្យបរិយាកាស និងផែនដីឡើងកម្ដៅ។ ដំណើរការនេះត្រូវបានឲ្យឈ្មោះថា ផលផ្ទះកញ្ចក់។ ចំហាយទឹក ($H_2O$), ឧស្ម័នកាបូនិក ($CO_2$), ឌីអាសូតម៉ូណូអុកស៊ីត ($N_2O$), មេតាន($CH_4$), និងអូហ្សូន ($O_3$) គឺជាឧស្ម័នផ្ទះកញ្ចក់ចំបងៗនៅក្នុងបរិយាកាសនៃផែនដី។

**ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ**

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គឺជាលទ្ធផលនៃការកើនឡើងកម្ដៅផែនដី ដែលទាក់ទងនឹងការប្រែប្រួល។ ការវាយតម្លៃផលប៉ះពាល់/ការប្រែប្រួលនេះ រាប់បញ្ចូល ការប្រើប្រាស់ទិន្នន័យអាកាស-ធាតុ ដូចជា សីតុណ្ហភាព កំពស់ទឹកភ្លៀង និងកម្រិតញឹកញាប់នៃព្រឹត្តិការណ៍មិនប្រក្រតី ព្រមទាំង ទិន្នន័យដែលមិនទាក់ទងនឹងអាកាសធាតុ ដូចជា ស្ថានភាពបច្ចុប្បន្ននៅក្នុងមូលដ្ឋានសម្រាប់វិស័យខុសៗគ្នា ដែលរួមទាំង ប្រភពទឹក កសិកម្ម និងសន្តិសុខស្បៀង រហូតដល់សុខភាពមនុស្ស និងសុវត្ថិភាពមនុស្ស បណ្ដាលពីការប្រែប្រួល។

**ព្រឹត្តិការណ៍មុខសញ្ញាគ្រោះថ្នាក់**

ទាក់ទងនឹង"ការប្រែប្រួលអាកាសធាតុ" ព្រឹត្តិការណ៍មុខសញ្ញាគ្រោះថ្នាក់ គឺជាព្រឹត្តិការណ៍ដែលអាចកើតឡើងបណ្ដាលពីលក្ខខណ្ឌអាកាសធាតុដែលនាំឲ្យបាត់បង់ជីវិត ឬ ខូចខាតទ្រព្យសម្បត្តិ បរិស្ថាន ការចិញ្ចឹមជីវិត និង/ឬ ភាពថ្លៃថ្នូររបស់មនុស្ស។ មុខសញ្ញាគ្រោះថ្នាក់ដែលកើតមានញឹកញាប់ជាងគេទាក់ទងនឹងអាកាសធាតុ រួមមាន ការប្រែប្រួលរបបទឹកភ្លៀង ដែលកើតចេញពីព្រឹត្តិការណ៍គ្រោះរាំងស្ងួត និងទឹកជំនន់ ធាតុអាកាសមិនប្រក្រតី ដែលទាក់ទងនឹងខ្យល់ព្យុះនាំឲ្យបាត់បង់ទ្រព្យសម្បត្តិ ឬ ដំណាំ រហូតដល់ការប្រែប្រួលជីវៈចម្រុះនៅក្នុងប្រព័ន្ធអេកូឡូស៊ីណាមួយ ដូចជា ការបាត់បង់ប្រភេទសត្វ ឬ ការរាតត្បាតនៃកត្តាចង្រៃ ដែលនាំឲ្យបាត់បង់សេវាកម្មប្រព័ន្ធអេកូឡូស៊ី។

**ភាពងាយរងគ្រោះនៃអាកាសធាតុ**

ភាពងាយរងគ្រោះត្រូវបានចាត់ទុកថាជាកម្រិតដែលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មនុស្ស ឬធម្មជាតិ និងសម្បត្តិក្នុងសេដ្ឋកិច្ច ប្រឈមនឹងការបាត់បង់ មានរបួស ឬ ខូចខាត បណ្ដាលពីផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់។ ប្រការនេះប្រហែលគ្នានឹង"ភាពងាយរងគ្រោះនៃអាកាសធាតុ"ផងដែរ ប៉ុន្តែត្រូវបានចែកចេញជាបីផ្នែក ដែលទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់៖

- កម្រិតនៃ*ភាពប្រឈម* នឹងសញ្ញាគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ (ដូចជា តើញឹកញាប់កម្រិតណា តើរយៈពេលវែងកម្រិតណា)
- កម្រិតនៃ*ភាពផុយស្រួយ* ដោយសារមុខសញ្ញាគ្រោះថ្នាក់នោះផ្ទាល់(ដូចជា តំបន់នានាដែលមិនសូវមានមនុស្សរស់នៅ នឹងមិនរងការខូចខាតច្រើន ធៀបនឹងតំបន់នានាដែលមានមនុស្សរស់នៅកុះករ នៅក្នុងលក្ខខណ្ឌនៃភាពប្រឈមដូចគ្នា)
- កម្រិតនៃ*សមត្ថភាព* ដែលមានសម្រាប់ទប់ទល់នឹងមុខសញ្ញាគ្រោះថ្នាក់បែបនេះ(ដូចជា ចំណេះដឹងដែលមានក្នុងកម្រិតកំណត់អំពី"តើធ្វើបែបណា" ឬ ប្រាក់សន្សំសម្រាប់ស្តារ/ទប់ស្កាត់ការបាត់បង់បណ្តាលពីការប្រឈមនៃមុខសញ្ញាគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ។

## ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ

ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយគឺជាទស្សនៈ និងជាការអនុវត្តន៍ នៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតាមរយៈកិច្ចខិតខំប្រឹងប្រែងវិភាគ និងកាត់បន្ថយកត្តានានាដែលជាឫសគល់នៃគ្រោះមហន្តរាយ។ ការកាត់បន្ថយកម្រិតប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ ការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិ ការគ្រប់គ្រងដី និងបរិស្ថានដោយប៉ិនប្រសព្វ និងការត្រៀមបង្ការបានប្រសើរជាងមុនសម្រាប់ព្រឹត្តិការណ៍អវិជ្ជមាននានា សុទ្ធសឹងជាឧទាហរណ៍អំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ គឺជាក្របខ័ណ្ឌមួយដែលមានធាតុផ្សំជាច្រើនជាអាទិ៍ លទ្ធភាពក្នុងការកាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យនៃគ្រោះមហន្តរាយ តាមរយៈការធ្វើសកម្មភាពនានា ដើម្បីបញ្ចៀស/ទប់ស្កាត់លក្ខខណ្ឌប្រកបដោយគ្រោះថ្នាក់ ឬ កម្រិតនៃផលប៉ះពាល់អវិជ្ជមាននៃមុខសញ្ញាគ្រោះថ្នាក់ណាមួយ តាមរយៈការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ឬ សកម្មភាពត្រៀមបង្ការជាមុន។

## ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ

ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានយល់ថាជាអ្វីដែលយើងត្រូវធ្វើ គ្រោងទុក ឬ មិនបានគ្រោងទុក(ស្វ័យភាព)ដែលនាំឲ្យមានការសម្របខ្លួនឲ្យស្របតាមមុខសញ្ញាគ្រោះថ្នាក់ ដែលទាក់ទងនឹងអាកាសធាតុ។ ការបន្សុាំត្រូវបានចាត់ទុកថាជាការសម្របខ្លួននៅក្នុងប្រព័ន្ធធម្មជាតិ ឬប្រព័ន្ធនៃការឆ្លើយតបនឹងកត្តាប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន ឬទៅអនាគត។ ការសម្របខ្លួន/ការធ្វើសកម្មភាពទាំងនេះមានគោលដៅកាត់បន្ថយគ្រោះថ្នាក់ដែលបង្កដោយកត្តាទាំងនេះ ឬក្នុងការទាញយកប្រយោជន៍ពីឱកាសដែលបានមកពីការប្រែប្រួលអាកាសធាតុ ដែលអាចផ្តល់ឲ្យ ដូចជា មូលនិធិបន្សុាំ។

## សមត្ថភាពបន្សុាំ

សមត្ថភាពបន្សុាំសំដៅលើភាពខ្លាំងជាលក្ខណៈបុគ្គល ឬ រួមគ្នា និងធនធានដែលអាចប្រើប្រាស់បានដើម្បីអាចឲ្យបុគ្គល ឬ សហគមន៍កាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេ ចំពោះផលប៉ះពាល់នៃមុខសញ្ញា

គ្រោះថ្នាក់។ សមត្ថភាពទាំងនេះអាចទប់ស្កាត់ ឬ កាត់បន្ថយផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ណាមួយ ឬ អាចឲ្យសហគមន៍ត្រៀមខ្លួន ដើម្បីចាត់វិធានការបានកាន់តែប្រសើរ សម្រាប់ឆ្លើយតបនឹងផលប៉ះពាល់ (ការត្រៀមខ្លួន)។

**ភាពធន់**

ភាពធន់ សំដៅលើសមត្ថភាពរបស់សហគមន៍ ឬ សង្គមណាមួយដែលមានលក្ខណៈជាប្រព័ន្ធ ដែលប្រឈមទៅនឹងសញ្ញាគ្រោះថ្នាក់នានា ដើម្បីធ្វើការបន្សាំតាមរយៈការទប់ទល់ ឬ កែប្រែដើម្បីឈានដល់ ឬ រក្សាមុខងារ ឬ រចនាសម្ព័ន្ធ ក្នុងកម្រិតដែលអាចទទួលយកបាន។ ជាញឹកញាប់ ភាពធន់ត្រូវបានកំណត់ដោយកម្រិតដែលប្រព័ន្ធសង្គមមានលទ្ធភាពក្នុងការចាត់ចែងខ្លួនឯង ដើម្បីបង្កើនសមត្ថភាពរបស់ខ្លួនសម្រាប់ការរៀនសូត្រពីគ្រោះមហន្តរាយកន្លងមក ដើម្បីកែលម្អវិធានការកាត់បន្ថយហានិភ័យ។

**ការបន្សុាំ និងការកសាងភាពធន់**

វិធីងាយស្រួលបំផុតដើម្បីស្វែងយល់ពីភាពខុសគ្នារវាងការបន្សុាំ និងការកសាងភាពធន់ គឺពិនិត្យមើល "ការបន្សុាំ" ជា "អ្វីដែលត្រូវធ្វើ" ដើម្បីកាត់បន្ថយភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ ដូចជាការបង្កើតសមត្ថភាពរក្សាទឹកទុកនៅតាមគ្រួសារ។ ការកសាងភាពធន់ អាចចាត់ទុកថាជា "របៀប" បង្កើតរចនាបទ(ប្លង់) ឬ របៀបអនុវត្តវិធានការឆ្លើយតបនៅក្នុងការបន្សុាំ ដើម្បីលើកកំពស់គុណតម្លៃនៃការអភិវឌ្ឍន៍ នៅក្នុងបរិបទនៃប្រព័ន្ធនានា សហគមន៍ ឬ សង្គម។ មានសំណុំលក្ខណៈចំនួនប្រាំមួយដែលត្រូវពិចារណានៅពេលគិតដល់"របៀប"ធ្វើការ៖១) មាត្រដ្ឋាន ២) ភាពរឹងមាំ ៣) ភាពរហ័ស ៤) ភាពសំបូរបែប ៥) ភាពបត់បែនបាន និង ៦) ការចាត់ចែងខ្លួនឯង។

## ដើម្បីសិក្សាបន្ថែម

ដើម្បីសិក្សាបន្ថែមអំពីវាក្យស័ព្ទដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ សូមភ្ជាប់ទៅវេបសាយវាក្យស័ព្ទរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ តាមរយៈ https://www.ipcc.ch/home_languages_main.shtml.

# ការស្វែងយល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះ និងវត្តមាននៃកត្តាទាំងនេះ

## ផលប៉ះពាល់

ការប្រែប្រួលអាកាសធាតុគំរាមកំហែង និងអាចធ្វើឲ្យកាត់បន្ថយភាពរីកចម្រើននានាដែលសម្រេចបានកន្លងមកនៅក្នុងការអភិវឌ្ឍកម្ពុជា។ ភាពអយុត្តិធម៌នៃការប្រែប្រួលអាកាសធាតុគឺថា វាបង្កការប៉ះពាល់អវិជ្ជមានក្នុងកម្រិតមិនស្មើភាពគ្នាមកលើសហគមន៍ក្រីក្រ ដែលមានធនធានក្នុងកម្រិតកំណត់ ក្នុងការពុះពារទល់នឹងផលវិបាកនានានៃការប្រែប្រួលអាកាសធាតុ។ សហគមន៍មូលដ្ឋានបានកត់សំគាល់អំពីការប្រែប្រួលយ៉ាងច្បាស់នៃអាកាសធាតុនៅកម្ពុជា ដែលរាប់ចាប់ពីការប្រែប្រួលរបបទឹកជំនន់ រហូតដល់គ្រោះរាំងស្ងួតកាន់តែខ្លាំងក្លា និងអូសបន្លាយរយៈពេលកាន់តែវែង ការជ្រាបចូលនៃទឹកប្រៃនៅតាមបណ្តោយឆ្នេរសមុទ្រ និងរហូតដល់រលកកំដៅមិនប្រក្រតី និងការប្រែប្រួលនៃរបបទឹកភ្លៀង។ ការប្រែប្រួលអាកាសធាតុទាំងនេះ បង្កជាការប្រឈមបន្ថែមទៀតចំពោះសហគមន៍ជនបទដែលងាយរងគ្រោះរួចមកហើយ ដោយសារតែការចិញ្ចឹមជីវិតភាគច្រើនរបស់ពួកគាត់ពឹងផ្អែកយ៉ាងខ្លាំងលើលក្ខខណ្ឌនៃទឹក ដី អាកាសធាតុ និងធាតុអាកាស។ ទោះជាយ៉ាងណាក៏ដោយ មិនមែនសហគមន៍តាមជនបទទាំងអស់សុទ្ធតែរងការប៉ះពាល់ដូចៗគ្នាពីការប្រែប្រួលអាកាសធាតុនោះឡើយ ហើយក៏មិនមែនបុគ្គលគ្រប់រូបក្នុងសហគមន៍ទាំងនេះរងការប៉ះពាល់ដូចៗគ្នានោះដែរ។

ការប្រែប្រួលអាកាសធាតុ ត្រូវគេរំពឹងថានឹងបង្កការប៉ះពាល់ដល់ទិន្នផលកសិកម្មជាច្រើននៅកម្ពុជាតាមរូបភាពជាច្រើន។ ឧទាហរណ៍ ប្រព័ន្ធស្រោចស្រព និងតំបន់កសិកម្មដែលពឹងផ្អែកលើទឹកភ្លៀង នឹងរងការប៉ះពាល់ដោយសារការប្រែប្រួលរបបទឹកភ្លៀង និងរបបទឹកហូរ ព្រមទាំងគុណភាព និងការផ្គត់ផ្គង់ទឹក។ ការសិក្សាជាទូទៅអំពីអាកាសធាតុ បង្ហាញពីកំណើនការធ្លាក់ភ្លៀងជារួម នៅតាមកន្លែងភាគច្រើនក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាមួយការប្រែប្រួល និងភាពមិនប្រាកដប្រជាសម្រាប់កម្ពុជា។ ក្រៅពីកំណើនការធ្លាក់ភ្លៀង កំណើនសីតុណ្ហភាព អាចបង្កការគំរាមកំហែងផងដែរមកលើផលិតភាពកសិកម្ម ដែលរងផលប៉ះពាល់ខ្លាំងមកលើដំណាំ និងកាត់បន្ថយទិន្នផល។ ការថយចុះទិន្នផលស្រូវ នឹងធ្វើឲ្យមានឥទ្ធិពលជាខ្លាំងមកលើប្រជាជន នៅតាមជនបទដែលមានប្រាក់ចំណូលទាប និងដែលពួកគាត់ធ្វើកសិកម្មតាមបែបប្រពៃណី ឬ លើផ្ទៃដីដែលមានទំហំតូច។

ការរក្សាធនធានទឹកនៅកម្ពុជា គឺជាអាទិភាពគន្លឹះមួយសម្រាប់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ។ តំបន់ជាច្រើននៅកម្ពុជា ប្រឈមនឹងភាពខ្វះខាតទឹកជាបន្តបន្ទាប់ ហើយកន្លែងជាច្រើន ពឹងផ្អែកយ៉ាងខ្លាំងលើធនធានទឹកក្រោមដីដែលមានក្នុងកម្រិតកំណត់ និងការត្រងយកទឹកភ្លៀងទុកប្រើប្រាស់។ ការប្រែប្រួលអាកាសធាតុ នឹងធ្វើឲ្យស្ថានភាពខ្វះខាតទឹកកាន់តែធ្ងន់ធ្ងរ តាមរយៈព្រឹត្តិការណ៍មិនប្រក្រតីនានា ដូចជាគ្រោះរាំងស្ងួតដែលធ្វើឲ្យបាត់បង់សន្តិសុខស្បៀង ឬ ការធ្លាក់ភ្លៀងមិនទៀងទាត់ ដែលបង្កើនហានិភ័យនៃការជន់លិច។ ការប្រឈមចំពោះការគ្រប់គ្រងធនធានទឹកនឹងកាន់តែធ្ងន់ធ្ងរដោយសារកំណើនកំពស់ទឹក

សមុទ្រ ដែលនឹងរួមចំណែកធ្វើឲ្យមានការជ្រាបចូលនៃទឹកប្រៃមកលាយឡំជាមួយធនធានទឹកសាបដែលមានបច្ចុប្បន្ន។ ការប្រែប្រួល និងការប្រឈមដែលបានកត់សំគាល់ទាំងនេះ បង្ហាញថា ប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា នឹងជួបប្រទះស្ថានភាពលំបាក និងកែប្រែលក្ខខណ្ឌដោយខ្លួនឯង។ នេះជាកង្វល់មួយដោយសារប្រព័ន្ធអេកូឡូស៊ី គឺជាសម្បត្តិធម្មជាតិដ៏សំខាន់មួយសម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ព្រោះសម្បត្តិទាំងនេះ ផ្តល់ចំណីអាហារ និងទឹកសម្រាប់ទ្រទ្រង់ជីវិតមនុស្ស ធនធានធម្មជាតិ ដែលទ្រទ្រង់សហគ្រាសពាណិជ្ជកម្ម ដូចជា ការនេសាទ និងព្រៃឈើ។ លើសពីនេះ ការបាត់បង់មុខងារប្រព័ន្ធអេកូឡូស៊ីទាំងនេះ ក៏អាចបង្កជាការគំរាមកំហែងដល់អត្តសញ្ញាណសង្គម និងវប្បធម៌របស់កម្ពុជាផងដែរ។

## ភាពងាយរងគ្រោះ

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ច្រើនតែត្រូវបានអធិប្បាយនៅក្នុងបរិបទនៃភាពងាយរងគ្រោះចំពោះមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះស៊ីក្លូន និងកត្តាខុសគ្នាទៅតាមរដូវ រហូតដល់បាតុភូតអាកាសធាតុកំណាច ក៏ដូចជា អ្នកដែលរងផលប៉ះពាល់ផងដែរ។ កម្រិតនៃផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុមកលើប្រព័ន្ធអេកូឡូស៊ី ឬ សហគមន៍ណាមួយ។ល។ មានការទាក់ទងនឹងកម្រិតនៃការប្រឈមនឹងមុខសញ្ញាគ្រោះថ្នាក់ ភាពផុយស្រួយដោយសារមុខសញ្ញាគ្រោះថ្នាក់នោះ និងកម្រិតសមត្ថភាពបន្សាំដែលមាននៅនឹងកន្លែង សម្រាប់ទប់ទល់នឹងមុខសញ្ញាគ្រោះថ្នាក់នោះ។

សេណារីយ៉ូនៃភាពងាយរងគ្រោះ

នៅពេលដែលសហគមន៍មួយ ឬ ព្រៃឈើមួយកន្លែង ដែលមិនអាចទប់ទល់នឹងផលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុបាន ក្នុងករណីនោះគេចាត់ទុកថា មានភាពងាយរងគ្រោះ ចំពោះការប្រែប្រួលអាកាសធាតុ មានកម្រិតខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ជាការល្អ គេត្រូវយល់ពីភាពងាយរងគ្រោះនេះដែលទាក់ទង នឹងភាពប្រឈម ភាពផុយស្រួយ និងសមត្ថភាពបន្សាំ។

*ភាពប្រឈម(Exposure)*៖ គេអាចគិតពីប្រការនេះតាមវិធីខុសគ្នាពីរ។ ឧទាហរណ៍៖ ១) តើខ្ញុំប្រឈមទាំងស្រុងនឹងមុខសញ្ញាគ្រោះថ្នាក់ ឬគ្រាន់តែមួយផ្នែកនៃឥទ្ធិពលរបស់វា? និង ២) តើខ្ញុំប្រឈមនឹងឥទ្ធិពលនេះញឹកញាប់កម្រិតណា?។

*ភាពផុយស្រួយ(Sensitivity)*៖ ចំណុចនេះពាក់ព័ន្ធជាច្រើនទៅនឹងលក្ខខណ្ឌនៃបរិស្ថាន និងជុំវិញទីតាំងដែលមានលក្ខខណ្ឌគ្រោះថ្នាក់។ ឧទាហរណ៍៖ ប្រសិនបើកន្លែងមួយមានប្រជាពលរដ្ឋរស់នៅកុះករ និងខ្សត់ធនធានធម្មជាតិ សហគមន៍នឹងងាយរងគ្រោះដោយសារតែកត្តាប្រែប្រួលអាកាសធាតុ ដូចជា រដូវប្រាំងដែលអូសបន្លាយរយៈពេលពីរសប្តាហ៍បន្ថែមទៀត។ ផ្ទុយទៅវិញ នៅកន្លែងដដែលនេះ បើមានប្រជាពលរដ្ឋរស់នៅតិចតួច នឹងមិននាំឲ្យមានលទ្ធផលដូចគ្នាចំពោះសហគមន៍ឡើយ។

*សមត្ថភាពបន្សាំ(Adaptive Capacity)*៖ ចំណុចនេះអាចចាត់ទុកថាជាទម្រង់ ឬ បរិមាណធនធានដែលអាចកៀរគរដើម្បីកាត់បន្ថយផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ។ ប្រការនេះអាចជាចំណេះដឹង ធនធានមនុស្ស និងហិរញ្ញវត្ថុ ការគ្រប់គ្រងព្រៃឈើបានប្រសើរជាងមុន រហូតដល់ការបង្កើតមធ្យោបាយសម្រាប់រក្សាទឹកទុក។

## ភាពងាយរងគ្រោះសម្រាប់ប្រភេទមនុស្សខុសៗគ្នានៅក្នុងសង្គម

បុរស ស្ត្រី កុមារ ក្រុមជនភាគតិច និងក្រុមជនជាតិដើម មិនរងការប៉ះពាល់ដូចគ្នាពីការប្រែប្រួលអាកាសធាតុឡើយ។ នេះដោយសារក្រុមនីមួយៗមានកម្រិតខុសគ្នានៃភាពងាយរងគ្រោះ ដោយសារតែសមត្ថភាពបន្សាំខុសគ្នារបស់ពួកគេ។ សមត្ថភាពនេះ គឺជាការរួមបញ្ចូលនៃស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់ពួកគេ លទ្ធភាពរបស់ពួកគេក្នុងការទទួលបានធនធានធម្មជាតិ និងបច្ចេកវិទ្យា រហូតដល់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មអភិវឌ្ឍន៍ រួមផ្សំនិងកត្តាដទៃផ្សេងទៀត។ ដូច្នេះ ប្រការសំខាន់ គឺត្រូវដឹងឲ្យបានច្រើនអំពីភាពងាយរងគ្រោះរបស់បុគ្គល និងក្រុមនានា ដើម្បីរៀបចំផែនការ និងគាំទ្រដល់តម្រូវការបន្សាំផ្សេងៗ។

### ស្ត្រី

នៅលើពិភពលោក ស្ត្រីភាគច្រើនគឺជាអ្នកក្រីក្រ ដែលទំនងជារងការប៉ះពាល់ពីការប្រែប្រួលអាកាសធាតុក្នុងកម្រិតមិនដូចគ្នាទេ។ កុមារី និងស្ត្រីចំណាស់ ច្រើនតែងាយរងគ្រោះបំផុត ជាពិសេសនៅពេលដែលមានភាពតានតឹងកើតឡើង។ ភាពងាយរងគ្រោះត្រូវបានកំណត់ឲ្យឃើញថាទាក់ទងនឹង ១) ការទទួលបានសេវាថែទាំសុខភាព ២) ការពឹងផ្អែកលើកសិកម្មជាមធ្យោបាយសម្រាប់ចិញ្ចឹមជីវិត ឬជាប្រភពនៃការចិញ្ចឹមជីវិត ៣)ការទទួលបានទឹក ៤) លទ្ធភាពចូលធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ នៅក្នុងពេលដែលមានគ្រោះមហន្តរាយកើតឡើងដែលទាក់ទងនឹងអាកាសធាតុ និង ៥) ការផ្លាស់ប្តូរទីលំនៅ និងការកើតមានជម្លោះ។

### កុមារ

កុមារងាយរងគ្រោះជាពិសេសចំពោះផលប៉ះពាល់មកលើសុខភាព ដែលទាក់ទងនឹង គ្រោះមហន្តរាយ បណ្តាលពីការប្រែប្រួលអាកាសធាតុ ដែលរួមទាំងការកើតឡើងកាន់តែញឹកញាប់នៃករណីជំងឺគ្រុនចាញ់ រាករូស និងកង្វះអាហារូបត្ថម្ភ។ ប្រការសំខាន់គួរកត់សំគាល់គឺថា កុមារមានតួនាទីសំខាន់ទៅអនាគត និងចូលរួមយ៉ាងសកម្មនៅក្នុងការបង្កើតឲ្យមានការប្រែប្រួលជាវិជ្ជមាន។ ដូច្នេះ នៅក្នុងកិច្ចខិតខំប្រឹងប្រែង CBA គេចាំបាច់ត្រូវពិចារណាអំពីភាពងាយរងគ្រោះរបស់កុមារ ក៏ដូចជា ត្រូវដោះស្រាយភាពងាយរងគ្រោះទាំងនេះ តាមរយៈគោលនយោបាយផ្សេងៗផងដែរ ដែលធានាថាកុមារមានតួនាទីមួយនៅក្នុងការសម្រេចនានាដែលជះឥទ្ធិពលមកលើពួកគេ។

### ជនជាតិភាគតិច និងជនជាតិដើម[4]

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុចំពោះជនជាតិភាគតិច និងជនជាតិដើម កម្រត្រូវបាន

[4] ជនជាតិភាគតិច ត្រូវបានឲ្យនិយមន័យថា ជាក្រុមនានាដែលមានចំនួនតិចជាងគេនៅក្នុងក្រុមប្រជាពលរដ្ឋសរុបក្នុងកន្លែងណាមួយ និងដែលជាអ្នកមានអត្តសញ្ញាណសាសនា ជាតិពន្ធុ ឬ ភាសារួមគ្នា។ "ជនជាតិដើម" សំដៅលើក្រុមនានាដែលត្រូវបានចាត់ទុកថាជា "ប្រជាពលរដ្ឋដំបូង" ដែលបានមកតាំងទីលំនៅក្នុងដែនដីណាមួយ និងដែលមានទំនាក់ទំនងពិសេសជាមួយបរិស្ថានធម្មជាតិ។

កត់សំគាល់ឃើញណាស់។ អ្វីដែលបានឃើញច្បាស់លាស់នោះគឺថា ជនជាតិដើម និងជនជាតិភាគតិចខ្លះ ច្រើនតែមានទំនាក់ទំនងជិតស្និទ្ធជាមួយបរិស្ថានធម្មជាតិរបស់ពួកគេសម្រាប់សន្តិសុខស្បៀង ការចិញ្ចឹមជីវិត ឬ ជំនឿសាសនា។ ប្រការនេះធ្វើឲ្យពួកគេងាយប្រែប្រួល អាស្រ័យតាមការប្រែប្រួលអាកាសធាតុ ក្នុងកម្រិតផ្សេងៗគ្នាជាច្រើន។ ក្រុមទាំងនេះក៏ទំនងជារស់នៅក្នុងភាពក្រីក្រផងដែរ ដែលបង្កើនកម្រិតនៃភាពងាយរងគ្រោះរបស់ពួកគេ។ ការផាត់ចេញពីក្នុងសង្គម និងការរើសអើង ក៏ជាផ្នែកមួយនៃភាពងាយរងគ្រោះរបស់ពួកគេផងដែរ ដោយមានកត្តានានាដែលបានកត់សំគាល់ខាងលើ ធ្វើឲ្យពួកគេកាន់តែលំបាកក្នុងការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ឬ ក្នុងការមានឥទ្ធិពលមកលើរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការគាំទ្រដល់ការបន្សាំ។

## ការពិនិត្យវាក្យស័ព្ទ និងសញ្ញាណ

សូមអានលំហាត់ពិនិត្យវាក្យស័ព្ទ និងសញ្ញាណសម្រាប់ក្រុមអ្នកសម្របសម្រួលVRAនៅក្នុងឧបសម្ព័ន្ធទី ១។

# ជំពូក ២
# ការត្រៀមខ្លួន និងការរៀបចំផែនការសម្រាប់ VRA

## សេចក្តីសង្ខេប

ជំពូកនេះចែងអំពីសកម្មភាពត្រៀមខ្លួន ដើម្បីរៀបចំអនុវត្តVRAមួយឲ្យបានជោគជ័យ។ អ្នកសម្របសម្រួលត្រូវតែត្រៀមខ្លួន ដើម្បីធ្វើការឲ្យមានប្រសិទ្ធភាព ដែលរួមទាំងអនុវត្តតាមគន្លឹះមួយចំនួនដែលចែងនៅក្នុងជំពូកនេះ នៅពេលចាត់ចែងធ្វើឲ្យអ្នកពាក់ព័ន្ធនានាចូលរួមក្នុង VRA។ ជំពូកនេះក៏ផ្តល់ជាប្រភពព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ដោយផ្តោតលើសហគមន៍ផងដែរ ដែលចាំបាច់ដើម្បីផ្តល់ការយល់ដឹងអំពីមូលដ្ឋានគ្រឹះថា តើអ្វីទៅជាការប្រែប្រួលអាកាសធាតុ មុននឹងចាត់ចែងអនុវត្ត VRA។

ការអនុវត្ត VRA ភាគច្រើនប្រើប្រាស់ការពិភាក្សាជាមួយក្រុមគោលដៅ ដែលជាវិធីសាស្ត្រចូលរួមយ៉ាងសំខាន់មួយ ដើម្បីប្រមូលព័ត៌មាន និងផ្តល់ការយល់ដឹងនៅមូលដ្ឋាន។ ដូច្នេះ ជំពូកនេះផ្តល់ការណែនាំអំពីអត្ថប្រយោជន៍ និងដែនកំណត់នៃការពិភាក្សាជាមួយប្រភេទមនុស្សខុសៗគ្នាដែលបានចូលរួមនៅក្នុងដំណើរការ VRA។ បញ្ជីត្រួតពិនិត្យសម្រាប់ការរៀបចំដំណើរការ VRA ធៀបនឹង"លក្ខខណ្ឌអប្បបរមា" ក៏មានផ្តល់ជូនជាការណែនាំផងដែរ ដើម្បីធានាថាអ្នកសម្របសម្រួល VRA សហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀតត្រៀមខ្លួនជាស្រេចសម្រាប់សិក្ខាសាលានេះ។

## គោលបំណងនៃជំពូកនេះ

- ✓ ផ្តល់ព័ត៌មាន និងការណែនាំដល់អ្នកសម្របសម្រួលសម្រាប់អនុវត្ត VRA ឲ្យបានជោគជ័យ
- ✓ ធានាថា ក្រុមអ្នកអនុវត្ត VRA បានពិចារណាជំហានងាយៗ ដែលសំខាន់បំផុតនៅក្នុងការត្រៀមខ្លួនដើម្បីចាត់ចែង និងរៀបចំអនុវត្ត VRA ។

# ការត្រៀមខ្លួនរបស់អ្នកសម្របសម្រួល

មុននឹងរៀបចំសិក្ខាសាលា VRA ប្រការសំខាន់គឺក្រុមការងារ VRA ត្រូវត្រៀមខ្លួនឲ្យបានពេញលេញ ដូចជា ចំណេះដឹងអំពីទស្សនៈទាននៃការប្រែប្រួលអាកាសធាតុ និងវាក្យស័ព្ទនានា ការយល់ដឹងច្បាស់លាស់អំពីដំណើរការ VRA ការរៀបចំសម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុង VRA និងសំខាន់ជាងនេះទៀតគឺ ត្រូវធ្វើខ្លួនឲ្យទៅជាអ្នកសម្របសម្រួលដ៏ប៉ិនប្រសប់ម្នាក់។ ជំនាញសម្របសម្រួលមិនត្រឹមតែពាក់ព័ន្ធនឹងការប្រមូលយកព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែក៏រាប់បញ្ចូលលទ្ធភាពក្នុងការទទួលស្គាល់ និងការឆ្លើយតបចំពោះព័ត៌មានដែលមិនច្បាស់លាស់ ដែលអាចនាំឲ្យមានការបកស្រាយពុំបានត្រឹមត្រូវ ពោលគឺ ធ្វើឲ្យចម្លើយនីមួយៗមានភាពច្បាស់លាស់សម្រាប់មនុស្សគ្រប់គ្នា។ លើសពីនេះ ការបន្តពិនិត្យមើលការឆ្លើយតបដែលបានមកពីការពិភាក្សាក្នុងក្រុមគោលដៅនៃ VRA អាចផ្តល់ទស្សនៈវិស័យអំពីទំនាក់ទំនងរវាងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងកត្តាសេដ្ឋកិច្ច-សង្គមផងដែរ និងថាតើកត្តាទាំងនេះមានអំពើទៅវិញទៅមកបែបណា ដែលអាចកាត់បន្ថយ ឬ គាំទ្រដល់ការកៀរគរសមត្ថភាពបន្សាំ។

ការបណ្តុះបណ្តាលអ្នកសម្របសម្រួល VRA គឺជាតម្រូវការចាំបាច់សម្រាប់ទាំងអស់គ្នា។ នៅក្នុងដំណើរការនេះ អ្នកសម្របសម្រួលត្រូវតែចាត់ទុកខ្លួនឯងដូចជាអ្នកភូមិ និងចូលរួមនៅក្នុងការសំដែងតួ ដើម្បីធ្វើឲ្យពួកគេបានដឹងចម្លើយ និងសំណួរដែលអាចមានការភ័ន្តច្រឡំ ដែលទំនងជានឹងកើតមាននៅក្នុងពេលអនុវត្ត VRA ជាក់ស្តែង។ ការអនុវត្តសាកល្បង គួរតែធ្វើ ដោយរួមទាំងរបៀបបញ្ចូលទិន្នន័យ ការវិភាគទិន្នន័យ និងការបកស្រាយទិន្នន័យផងដែរ។ ការយល់ដឹងអំពីរបៀបវិភាគទិន្នន័យតាមរូបមន្តស្ថិតិ ក៏មានសារៈសំខាន់ផងដែរ។

នៅក្នុងរយៈពេលប៉ុន្មានថ្ងៃមុនអនុវត្ត VRA អ្នកសម្របសម្រួលដែលបានទទួលការបណ្តុះបណ្តាល ត្រូវត្រៀមខ្លួនសម្រាប់អនុវត្ត VRA ជាក់ស្តែង ដែលត្រូវអនុវត្តនៅតាមមូលដ្ឋាន។ ការត្រៀមខ្លួននេះគួរស្វែងយល់ជាមុន ថាតើពួកគេនឹងសម្របសម្រួលក្រុមបែបណា អ្នកណាជាអ្នកដឹកនាំការសម្របសម្រួល អ្នកណាជាអ្នកកត់ត្រា និងការទទួលខុសត្រូវខុសៗគ្នាជាមួយតួនាទីទាំងនោះ។ ដោយសារអាចនឹងមានអ្នកសម្របសម្រួល និងអ្នកកត់ត្រាច្រើនជាងម្នាក់ សម្រាប់ការអនុវត្តV RA នីមួយៗ សមាជិកទាំងអស់នៃក្រុម VRA គួរតែយល់ផងដែរអំពីតួនាទី និងការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ។

### គន្លឹះដើម្បីក្លាយជាអ្នកសម្របសម្រួលដ៏ប៉ិនប្រសប់

អ្នកសម្របសម្រួលមានតួនាទីសំខាន់បំផុត ហើយអាចប្រឈមនឹងបញ្ហាក្នុងការធ្វើលំហាត់ VRA។ អ្នកសម្របសម្រួលត្រូវចាប់ផ្តើមការពិភាក្សា រក្សាសកម្មភាពនេះជាបន្ត ធានាថា សិក្ខាកាមទាំងអស់មានឱកាសដូចគ្នា ដើម្បីចូលរួម និងបូកសរុបការពិភាក្សានៅចុងវគ្គនីមួយៗ។

គន្លឹះដើម្បីក្លាយជាអ្នកសម្របសម្រួលដ៏ប៉ិនប្រសប់

- ✓ ត្រូវយកចិត្តទុកដាក់ និងការចូលរួម ផ្តល់គំនិតរបស់សមាជិកសហគមន៍
- ✓ ដឹងពីពេលត្រូវនិយាយ និងពេលដែលត្រូវស្តាប់
- ✓ យល់សំណួរដែលកំពុងសួរ និងសំណួរដែលកំពុងរៀបចំឲ្យបានពេញលេញ នៅមុនបន្តដំណើរការទៅមុខទៀត
- ✓ យល់របៀបនៃការវិភាគព័ត៌មានដែលប្រមូលបាន ព្រោះអ្នកសម្របសម្រួលមានតួនាទីចាំបាច់ក្នុងការរកឲ្យបានព័ត៌មានសំខាន់ៗសម្រាប់ដំណើការ VRA ទាំងមូល
- ✓ ធានាថា បានទទួលចម្លើយពីអ្នកចូលរួមគ្រប់រូប និងបានស្តាប់ឮគ្រប់កង្វល់ទាំងអស់
- ✓ បង្កើតឱកាសសម្រាប់អ្នកចូលរួម ក្នុងការពិភាក្សាសំណួរ និងចម្លើយក្នុងចំណោមពួកគេ
- ✓ អាចកំណត់អត្តសញ្ញាណជាមួយក្រុមដែលអ្នកកំពុងសម្របសម្រួល ដូច្នេះត្រូវជ្រើសយកអ្នកសម្របសម្រួល ដោយគិតគូរអំពីអ្នកចូលរួម និងបរិបទនោះផងដែរ។ ឧទាហរណ៍៖
    - ជ្រើសរើសយកអ្នកសម្របសម្រួល VRA ជានារី ដើម្បីឲ្យធ្វើការជាមួយក្រុមយុវតី
    - ជ្រើសរើសយកអ្នកសម្របសម្រួលជាបុរសចំណាស់ ឲ្យធ្វើការជាមួយក្រុមមនុស្សចាស់។

## គន្លឹះដើម្បីក្លាយជាអ្នកប៉ិនប្រសប់ខាងកត់ត្រា

មិនថាអ្នកសម្របសម្រួល VRA មានជំនាញសម្របសម្រួលពូកែប៉ុណ្ណានោះទេ ទិន្នន័យដែលប្រមូលបាន អាចជាទិន្នន័យល្អ នៅពេលដែលកត់ត្រាបានល្អតែប៉ុណ្ណោះ ដូចជា ការឆ្លើយតបរបស់អ្នកចូលរួម និងព័ត៌មានស្របតាមបរិបទនៃចម្លើយតបទាំងនោះ។ កិច្ចការនេះត្រូវតែធ្វើឡើងសម្រាប់ការឆ្លើយតបនីមួយៗ និងសម្រាប់ចម្លើយតបជាក្រុម ដើម្បីធានាថាអាចពន្យល់បានអំពីទិន្នន័យដែលប្រមូលបាន។

**គន្លឹះសម្រាប់អ្នកកត់ត្រា**

- ✓ ត្រូវធានាថា ព័ត៌មានដែលប្រមូលបាន មានការពាក់ព័ន្ធទៅនឹងសំណួរដែលបានសួរ
- ✓ នៅពេលកត់ត្រាចម្លើយរបស់អ្នកចូលរួម ត្រូវឲ្យប្រាកដថា មានការសួររកព័ត៌មានទៅតាមបរិបទសមស្រប និងនៅពេលចាំបាច់ដើម្បីឲ្យមានភាពច្បាស់លាស់
- ✓ ត្រូវពិនិត្យឡើងវិញនូវគ្រប់ចម្លើយ ជាមួយអ្នកចូលរួម ឬក្រុមអ្នកចូលរួម នៅក្រោយលំហាត់នេះ។ ចូរលើកសំណួរ ហេតុអ្វី? កន្លែងណា? អ្វីខ្លះ? ពេលណា? របៀបណា? ដើម្បីបន្ថែមការយល់ដឹងអំពីចម្លើយទាំងនេះ។

# ពន្យល់សហគមន៍អំពីការប្រែប្រួលអាកាសធាតុដោយសង្ខេប

នៅពេលបុគ្គលិកបានទទួលការបណ្តុះបណ្តាលអំពីទស្សនៈទាននៃការប្រែប្រួលអាកាសធាតុ និងបានធ្វើលំហាត់គ្រាប់អំពីរបៀបចាត់ចែងអនុវត្ត VRA រួចហើយ អង្គការដែលចាត់ចែងអនុវត្ត VRA គួរពន្យល់ត្រួសៗដល់តំណាងដែលជាគោលដៅនៅតាមភូមិ ឃុំ និងខេត្ត អំពីការប្រែប្រួលអាកាសធាតុ។ ការជ្រើសរើសយកឃុំគោលដៅ គួរតែបានផ្អែកលើភស្តុតាងវិទ្យាសាស្ត្រសមស្រប ដែលទាក់ទងនឹងសហគមន៍ ដែលងាយរងគ្រោះបំផុតទៅនឹងការប្រែប្រួលអាកាសធាតុ។ នៅប្រទេសកម្ពុជាមានយុទ្ធសាស្ត្រជាតិជាច្រើន ដូចជា ផែនការសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) និងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ ២០១៤-២០២៣ អាចផ្តល់ជាការណែនាំដល់អង្គការនានានៅថ្នាក់មូលដ្ឋាន នៅក្នុងការកំណត់ថាតើខេត្តណាខ្លះដែលងាយរងគ្រោះជាងគេ។

ចំណេះដឹងងាយៗអំពីការប្រែប្រួលអាកាសធាតុ មានសារៈសំខាន់ណាស់សម្រាប់ចាត់ចែងអនុវត្ត VRA ឲ្យដំណើរការដោយរលូន។ ភ្នាក់ងារអនុវត្តនៅតាមមូលដ្ឋានត្រូវតែប្រាកដថា សហគមន៍បានដឹងអំពីទស្សនៈទាននៃការប្រែប្រួលអាកាសធាតុ ភាពងាយរងគ្រោះ និងការបន្សាំ។ ចំណុចនេះ អាចមានន័យថា ភ្នាក់ងារអនុវត្តនៅតាមមូលដ្ឋាន ត្រូវធ្វើទស្សនកិច្ចនៅតាមសហគមន៍ទាំងនោះមុនរៀបចំសិក្ខាសាលា VRA ដើម្បីផ្សព្វផ្សាយព័ត៌មាន ឬ ផ្តល់ការបណ្តុះបណ្តាល។ អត្ថប្រយោជន៍ពីការពន្យល់ត្រួសៗជាមុនដល់សហ-គមន៍គឺ ត្រូវចំណាយពេលឲ្យបានច្រើនជាមួយសហគមន៍ ដើម្បីបង្ហាញពីទស្សនៈទាន និងវាក្យស័ព្ទអំពីការប្រែប្រួលអាកាសធាតុ ដែលអាចឲ្យពួកគេបានយល់ច្បាស់។ ក្នុងករណីដែលមិនអាចធ្វើបាន គេអាចផ្តល់ការណែនាំឲ្យបានច្រើននៅក្នុងពេលចាប់ផ្តើមអនុវត្ត VRA ។ ការធ្វើវិធីបែបនេះ អាចកាន់តែសមស្រប ប្រសិនបើសហគមន៍មានចំណេះដឹងខ្លះៗជាមុន អំពីការប្រែប្រួលអាកាសធាតុ។

ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ - វីដេអូឯកសារជាភាសាខ្មែរ ស្តីពីការប្រែប្រួលអាកាសធាតុ

| | |
|---|---|
| វីដេអូជាច្រើន៖ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃក្រសួងបរិស្ថានកម្ពុជា | www.camclimate.org.kh |
| វីដេអូជាច្រើន៖ គណៈកម្មការទន្លេមេគង្គ | www.mrcmekong.org |
| វីដេអូជាច្រើន៖ យន្តការរៀនសូត្រអំពីការបន្សាំ (ALM) | http://undp-alm.org/videos |

# ក្រុមពិភាក្សា VRA របស់អ្នក

ក្រុមពិភាក្សាមួយ គឺជាការពិភាក្សាក្នុងក្រុមតូចមួយ ដែលណែនាំដោយអ្នកសម្របសម្រួល។ ដើម្បីអនុវត្តVRA ជាការល្អ ត្រូវបំបែកអ្នកចូលរួមជាក្រុមផ្សេងៗគ្នា ដែលមានភាពងាយរងគ្រោះប្រហែលគ្នាទៅនឹងការប្រែប្រួលអាកាសធាតុ ដូចជា បុរស ស្ត្រី កុមារ មនុស្សចាស់ ក្រុមភាគតិច និងជនជាតិដើម រហូតដល់ក្រុមអ្នកផ្តល់សេវាកម្មអភិវឌ្ឍន៍ ដូចជា តំណាងរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍មូលដ្ឋានផងដែរ។ ដូច្នេះ គេត្រូវដឹងអំពីសមាសភាពនៃអ្នកចូលរួមក្នុង VRA ដែលអាចជួយឲ្យអ្នកសម្របសម្រួល VRA ដឹងជាមុនអំពីអ្នកណាខ្លះដែលគួរអញ្ជើញចូលរួមក្នុង VRA តើគួរបែងចែកជាក្រុមដោយរបៀបណា និងរបៀបរាយការណ៍លទ្ធផលពី VRA ។

ជម្រើសរបស់អ្នកសម្រាប់ការអនុវត្ត VRA

*ក្រុមទាំងមូល(ក្រុមធំ)*

+ អនុញ្ញាតឲ្យមានការពិភាក្សាជាទ្រង់ទ្រាយធំ និងរស់រវើក អ្នកសម្របសម្រួលពុំចាំបាច់ដើរតួសកម្មឡើយ ការរៀបចំខ្លួនតិចតួច និងការវិភាគងាយៗ។

− អាចមានន័យថា ក្រុមខ្លះ (ដូចជា យុវតី) ពុំមានអារម្មណ៍ថាបានចូលរួម ពុំផ្តល់ទិន្នន័យសំបូរបែប និងពុំអនុញ្ញាតឲ្យមានការវិភាគបានពិស្តារឡើយ។

នេះជាវិធីល្អសម្រាប់អនុវត្តVRA "ដោយឆាប់រហ័ស" ប៉ុន្តែសម្រាប់តែការស្វែងយល់ប៉ុណ្ណោះ។ សម្រាប់គោលបំណងនៃការរៀបចំផែនការគម្រោង គេត្រូវការទិន្នន័យញែកដាច់គ្នាអំពីភាពងាយរងគ្រោះ ដើម្បីធានាថា អ្នកដែលប្រឈមហានិភ័យ/ងាយរងគ្រោះខ្លាំងបំផុតចំពោះការប្រែប្រួលអាកាសធាតុ អាចបង្ហាញពីតម្រូវការក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់ខ្លួនដែរ។

*ក្រុមពិភាក្សា*

+ អនុញ្ញាតឲ្យបំបែកអ្នកចូលរួមជាក្រុមទៅតាមស្ថានភាពប្រជាសាស្ត្រ ឬ "ប្រភេទនៃភាពងាយរងគ្រោះចំពោះអាកាសធាតុ" ផ្តល់ទិន្នន័យបានល្អ ដោយពុំមានភាពស្មុគស្មាញដែលលំបាកវិភាគឡើយ និងផ្តល់ឲ្យក្រុមអ្នកងាយរងគ្រោះ និងទន់ខ្សោយ នូវឱកាសដើម្បីបញ្ចេញយោបល់។

− ត្រូវការទីធ្លាធំ និងអ្នកសម្របសម្រួលច្រើន (យ៉ាងហោចណាស់ម្នាក់ សម្រាប់ក្រុមគោលដៅនីមួយៗ) និងត្រូវការទិន្នន័យប្រៀបធៀប និងការវិភាគ សម្រាប់រាយការណ៍។

ជាញឹកញាប់ ប្រជាពលរដ្ឋក្រីក្រ ឬ អ្នកគ្មានអំណាច យល់ថា ការចូលរួមនៅក្នុងក្រុមនានាដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ផ្តល់នូវអារម្មណ៍កក់ក្តៅ និងកម្លាំងចិត្ត។ ការធ្វើបែបនេះអាចប្រមូលបានទិន្នន័យសំបូរបែប តាមរយៈការពិភាក្សាជាចំហ ដូច្នេះអាចឲ្យមានការវិភាគស៊ីជម្រៅអំពីភាពងាយរងគ្រោះ ក៏ដូចជា ការរៀបចំផែនការសម្រាប់ឆ្លើយតបដែលផ្តោតលើការកាត់បន្ថយភាពងាយរងគ្រោះផងដែរ។

*បុគ្គល*

| + | − |
|---|---|
| អនុញ្ញាតឲ្យមានការវិភាគឲ្យបានស៊ីជម្រៅ និង ធានាថាអាចវាយតម្លៃពីអារម្មណ៍របស់បុគ្គលម្នាក់ៗដែលតាមធម្មតា មិនអាចបញ្ចេញយោបល់បានឡើយនៅក្នុងក្រុមពិភាក្សា។ | បង្កើតព័ត៌មានយ៉ាងច្រើន ដែលបន្ថែមភាពស្មុគស្មាញទៅក្នុងការវិភាគ មិនអាចមានការមូលមតិគ្នាឡើយ អ្នកសម្របសម្រួលអាចមានឥទ្ធិពលលើចម្លើយរបស់អ្នកចូលរួម។ |

ទម្រង់នៃការប្រមូលទិន្នន័យបែបនេះ ច្រើនតែប្រើប្រាស់ដោយអ្នកស្រាវជ្រាវតាមសកលវិទ្យាល័យ ដែលគោលបំណងគឺប្រមូល និងរាយការណ៍ទិន្នន័យយ៉ាងច្រើនសម្រាប់គោលដៅវិភាគតាមរូបមន្តស្ថិតិ។

ការផ្តោតជាពិសេសលើភាពងាយរងគ្រោះ

បើប្រើប្រាស់ VRA ដើម្បីផ្តោតលើការបន្ស៊ីសកម្មភាពកាត់បន្ថយភាពងាយរងគ្រោះសម្រាប់ក្រុមគោលដៅជាក់លាក់ ឧទាហរណ៍ដូចជា កុមារ នៅក្នុងបណ្តាក្រុមគោលដៅ គឺត្រូវតែមានមួយក្រុមដែលជាក្រុមកុមារ។ ទម្រង់ដូចគ្នានេះ ក៏ត្រូវមានផងដែរសម្រាប់មនុស្សចាស់ ស្ត្រី និងក្រុមជនជាតិដើម។ល។

**ការអញ្ជើញចូលរួមក្នុង VRA**

**!** នៅក្នុងសិក្ខាសាលាដែលគ្មានការកំណត់សមាសភាពអ្នកចូលរួមឲ្យបានជាក់លាក់ជាមុន ច្រើនតែមានន័យថា មានតែអ្នកក្លាហាន និងអ្នកមិនសូវរងគ្រោះដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុប៉ុណ្ណោះដែលជាមនុស្សភាគច្រើននៅក្នុងសិក្ខាសាលានោះ ហើយអនុសាសន៍អាចមិនផ្តោតលើក្រុមអ្នកងាយរងគ្រោះបំផុតឡើយ។

**!** គេតែងតែត្រូវការពេលច្រើន ដើម្បីអញ្ជើញក្រុមពលរដ្ឋជាក់លាក់ ដែលជាតំណាងនៃកន្លែងណាមួយជាគោលដៅ។ ក្នុងកម្រិតអប្បបរមា យ៉ាងហោចណាស់ត្រូវមាន ១០% នៃគ្រួសារដែលរស់នៅក្នុងតំបន់គោលដៅ ដែលត្រូវមានវត្តមាននៅក្នុងដំណើរការនោះ។

# ការត្រៀមខ្លួនសម្រាប់ VRA

ដោយសារ VRA ពាក់ព័ន្ធនឹងក្រុមមនុស្សខុសៗគ្នាជាច្រើនដែលមានតួនាទីខុសគ្នា និងមានកិច្ចការខុសពីគ្នាដែលត្រូវអនុវត្តក្នុងរយៈពេលជាច្រើនម៉ោងនៅក្នុងថ្ងៃតែមួយ ជាការល្អត្រូវរៀបចំផែនការជាមុន។ ខាងក្រោមនេះជាបញ្ជីត្រួតពិនិត្យ ដើម្បីធានាថា ក្រុមអ្នកអនុវត្ត VRA សហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀតអាចត្រៀមខ្លួនជាមុន។

ការត្រៀមលក្ខណៈរបស់ក្រុមអ្នកសម្របសម្រួល VRA

- ✓ សមាជិកក្រុមនីមួយៗបានបញ្ចប់លំហាត់វាក្យស័ព្ទនៃ VRA និងទស្សនៈទាន ក្នុងជំពូកទី១រួចហើយ
- ✓ ក្រុមនេះយល់ពីតួនាទី និងការទទួលខុសត្រូវដែលបានកំណត់សម្រាប់ពួកគេរៀងៗខ្លួន សម្រាប់គ្រប់ជំហាននៃ VRA
- ✓ សមាជិកក្រុមនីមួយៗយល់ពីរបៀបសម្របសម្រួលឧបករណ៍ VRA និងព័ត៌មានដែលត្រូវប្រមូលយកតាមរយៈឧបករណ៍នីមួយៗ
- ✓ ក្រុមនីមួយៗបានរៀបចំតារាងH នៅលើក្រដាសផ្ទាំងធំ(មួយឈុតសម្រាប់ក្រុមគោលដៅនីមួយៗ) ឬ បោះពុម្ពតារាង H នេះសម្រាប់អ្នកឆ្លើយម្នាក់ៗ។

## ការត្រៀមខ្លួនរបស់សហគមន៍

- ✓ អ្នកទាំងអស់ដែលចូលរួមនៅក្នុងការអនុវត្ត VRA យល់ពីបំណងនៃ VRA នេះ និងមូលហេតុនៃការចូលរួមរបស់ពួកគេ និងអំពីរបៀបប្រើប្រាស់ព័ត៌មានដែលប្រមូលបាននេះ
- ✓ អ្នកដែលចូលរួមនៅក្នុងការអនុវត្ត VRA មានសមាសភាពខុសគ្នា និងត្រូវតែមានតុល្យភាព ដូចជាបុរស ស្ត្រី កុមារ យុវជន អ្នកផ្តល់សេវាកម្មអភិវឌ្ឍន៍។ល។
- ✓ អ្នកចូលរួមត្រូវបានជ្រើសរើស និងអញ្ជើញចូលរួមនៅក្នុងការអនុវត្ត VRA
- ✓ អ្នកចូលរួមទាំងអស់ដឹងថាអនុវត្ត VRA នេះ នឹងធ្វើឡើងនៅទីណា ពេលណា និងថាតើដំណើរការនេះនឹងចំណាយពេលប៉ុន្មាន។(គួរតែមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាអំពីចំណុចនេះ នៅមុនដំណើរការនៃការអញ្ជើញ)។

# ជំពូក ៣
# អនុវត្ត VRA

## សេចក្តីសង្ខេប

ជំពូកនេះផ្តល់ការណែនាំជាជំហានៗ អំពីការចាត់ចែងអនុវត្តវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) តាមរយៈការប្រើប្រាស់ឧបករណ៍ទម្រង់អក្សរ H។ ដំណើរការនេះចាប់ផ្តើមជាមួយការចាក់បញ្ចាំងវីដេអូមួយ ដើម្បីជួយអ្នកចូលរួមឲ្យយល់ពីការប្រែប្រួលអាកាសធាតុ និងលំហាត់បែបចូលរួម ដែលមានគោលដៅបង្ហាញទំនាក់ទំនង និងវិភាគផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុជាមួយការប្រែប្រួលដែលកើតមានកន្លងមកនៅក្នុងសហគមន៍របស់ពួកគេ (ឬកន្លែងជាគោលដៅដែលត្រូវអនុវត្ត VRA)។ បន្ទាប់មក ត្រូវបែងចែកអ្នកចូលរួមជាក្រុមទៅតាមប្រធានបទ អនុលោមតាមលក្ខណៈស្របគ្នា ឬ ភាពខុសគ្នានៃភាពងាយរងគ្រោះនានា ដូចជា បុរស ស្ត្រី មនុស្សចាស់ អ្នកផ្តល់សេវាកម្មអភិវឌ្ឍន៍ ដើម្បីអនុវត្តឧបករណ៍ទម្រង់H។ ការបែងចែកជាក្រុម ត្រូវធ្វើឡើងដើម្បីប្រមូលព័ត៌មានជាក់លាក់អំពីក្រុមងាយរងគ្រោះនានា ដើម្បីសម្រួលដល់ការបង្កើតវិធានការឆ្លើយតប ក្នុងការកាត់បន្ថយភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុដែលជាគោលដៅ។

ឧបករណ៍ទម្រង់ H ដែលមានបួន(៤)ប្រភេទខុសគ្នា (ទម្រង់H សំណួរ ១ (Q1), ទម្រង់ H សំណួរ ២ (Q2), ទម្រង់ H សំណួរ ៣ (Q3), និងទម្រង់ H សំណួរ ៤ (Q4) ដោយផ្អែកលើសំណួរគន្លឹះ ត្រូវបានប្រើប្រាស់ដើម្បីស្រង់យកព័ត៌មានអំពីទិដ្ឋភាពខុសៗគ្នានៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ការវិភាគអំពីហានិភ័យ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបច្ចុប្បន្ន និងទៅអនាគត ធនធាន និងយុទ្ធសាស្ត្រនានាដែលប្រើប្រាស់ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ឧបសគ្គចំពោះការបន្សុំ និងការគាំទ្រដល់ការកសាងសមត្ថភាពបន្សុំដែលចាំបាច់ សម្រាប់កាត់បន្ថយភាពងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុ។

## គោលបំណងនៃជំពូកនេះ

- ✓ ផ្តល់ការណែនាំអំពីក្រមសីលធម៌នៅក្នុងការពន្យល់ដែលធ្វើឡើងនៅថ្នាក់មូលដ្ឋាន
- ✓ ផ្តល់ព័ត៌មានដល់អ្នកសម្របសម្រួល VRA អំពីវិសាលភាពនៃព័ត៌មានដែលត្រូវប្រមូលយក
- ✓ ផ្តល់ការណែនាំជាជំហានៗដល់អ្នកសម្របសម្រួលសម្រាប់ការអនុវត្តទម្រង់ H សម្រាប់VRA

រយៈពេលសម្រាប់ការសម្របសម្រួលសរុបនៅតាមមូលដ្ឋាន៖ ៦ ម៉ោង[5]

[5] ៦ ម៉ោង ជារយៈពេលដែលស្នើសម្រាប់ការសម្របសម្រួល។ រយៈពេលនេះអាចខុសគ្នា អាស្រ័យលើបទពិសោធន៍របស់អ្នកសម្របសម្រួល ឬ ការចូលរួមរបស់សមាជិកនៅក្នុងដំណើរការ VRA

# សេចក្តីពន្យល់អំពីការអនុវត្តន៍

ឥឡូវនេះ អ្នកបានត្រៀមខ្លួនជាស្រេចសម្រាប់ការអនុវត្តន៍ដំណើរការសិក្ខាសាលា VRA ។ រូបទី ២ បង្ហាញពីដំណើរការ VRA និងឧបករណ៍នានាដែលប្រើប្រាស់នៅក្នុងជំហាននីមួយៗ។

**ផ្នែកទី ១. ផ្តោតលើការប្រែប្រួល**

បង្ហាញជូននូវប្រធានបទអំពីការប្រែប្រួលអាកាសធាតុ ដែលទាក់ទងនឹងការប្រែប្រួលនានានៅក្នុងមជ្ឈដ្ឋានជុំវិញ

៦០នាទីសម្រាប់សកម្មភាពក្រុមទាំងមូល

**ផ្នែកទី ២. ការវិភាគនិន្នាការ**

បង្កើតរូបភាពមួយនៃព្រឹត្តិការណ៍គ្រោះថ្នាក់ទៅតាមពេលវេលា និងការជួយសហគមន៍ឲ្យបានយល់អំពីការប្រែប្រួលអាកាសធាតុដោយខ្លួនឯង

១,៥ម៉ោងសម្រាប់សកម្មភាពតាមក្រុមខុសៗគ្នា

**ផ្នែកទី ៣. ទម្រង់ H**

ស្រង់យកទស្សនៈអំពីភាពងាយរងគ្រោះចំពោះមុខការប្រែប្រួលអាកាសធាតុ សមត្ថភាពពុះពារ និងសមត្ថភាពបន្សាំ ការប្រឈម និងរបៀបកសាងសមត្ថភាពបន្សាំដើម្បីកាត់បន្ថយភាពងាយរងគ្រោះ

៣ ម៉ោង សម្រាប់សកម្មភាពតាមក្រុមខុសៗគ្នា

**ផ្នែកទី ៤. ការបូកសរុប VRA**

ជានាថា អ្នកចូលរួមដឹងអំពីសារៈសំខាន់នៃកិច្ចប្រឹងប្រែងរបស់ពួកគេ របៀបប្រើប្រាស់ទិន្នន័យដែលបានពី VRA និងអំពីសកម្មភាពជាបន្ត

៣០ នាទីសម្រាប់សកម្មភាពក្រុមទាំងមូល

រូបទី ២. ដំណើរការអនុវត្ត VRA និងខ្លឹមសារសង្ខេបនៅក្នុងជំហាននីមួយៗ

## ការពន្យល់ពីក្រមសីលធម៌

អ្នកចូលរួមភាគច្រើន ប៉ុន្តែមិនមែនទាំងអស់គ្នានោះទេ នឹងបានយល់ដឹងអំពីមូលហេតុដែលនាំឲ្យមានការរៀបចំអនុវត្ត VRA នេះ។ ដូច្នេះគួរចាប់ផ្តើមអនុវត្ត VRA ជាមួយ"ការពន្យល់ពីក្រមសីលធម៌"។ តារាងត្រួតពិនិត្យលំដាប់លំដោយ មានផ្តល់ជូនដូចខាងក្រោម៖

- ✓ ក្រុមVRA ណែនាំខ្លួន ដែលរួមទាំងអំពី តួនាទី និងការទទួលខុសត្រូវសំខាន់ៗរបស់ពួកគេនៅក្នុងការអនុវត្ត VRA នេះ
- ✓ ពិនិត្យគោលបំណងនៃការអនុវត្ត VRA នេះ និងព័ត៌មានបែបណាខ្លះដែលអ្នកកំពុងស្វែងរក តើទិន្នន័យទាំងនេះនឹងយកទៅប្រើប្រាស់បែបណា? និងតើអ្នកណាខ្លះនឹងឃើញទិន្នន័យទាំងនេះ?
- ✓ សង្កត់ធ្ងន់ទៅលើ ថាតើទិន្នន័យដែលទទួលបាន នឹងត្រូវរក្សាទុកជាការណ៍សម្ងាត់
- ✓ ផ្តល់ឲ្យអ្នកចូលរួមនូវការពន្យល់អំពីទិដ្ឋភាពរួមនៃដំណើរការ VRA (សូមអានរូបទី២ ដើម្បីផ្តល់ជាគំនិត) ដែលរួមទាំងការបង្ហាញគំរូនានានៃឧបករណ៍ដែលត្រូវប្រើប្រាស់ផងដែរ
- ✓ ជម្រាបអ្នកចូលរួមថា ពួកគេអាចចាកចេញពីសិក្ខាសាលានេះនៅពេលណាក៏បាន ប្រសិនបើពួកគេចង់ចាកចេញ
- ✓ ចូរពន្យល់អ្នកចូលរួមថា នៅពេលដែលបានដឹងលទ្ធផលពី VRA នេះ អ្នកនឹងវិលត្រឡប់មកវិញដើម្បីផ្តល់ឱកាសដល់ពួកគេដើម្បីពិនិត្យឡើងវិញ និងផ្ទៀងផ្ទាត់ព័ត៌មាននោះ
- ✓ សំគាល់៖ ប្រសិនបើនៅពុំទាន់មានការអះអាងអំពីការផ្តល់មូលនិធិដល់គម្រោងនៅឡើយទេ សូមជូនដំណឹងដល់អ្នកចូលរួមអំពីស្ថានភាពនេះ ដើម្បីជៀសវាងការសង្ឃឹមដោយមិនប្រាកដប្រជា

## ការដាក់ពិន្ទុ និងការចាត់ថ្នាក់

ទម្រង់ H តម្រូវឲ្យអ្នកចូលរួមចាត់ថ្នាក់អំពីភាពងាយរងគ្រោះរបស់ពួកគេ នៅក្នុងបរិបទខុសៗគ្នា។ ជាការល្អត្រូវប្រើប្រាស់វិធីចាត់ថ្នាក់ងាយៗសម្រាប់ការចាត់ថ្នាក់ពី ១ ដល់ ៥ សម្រាប់ទម្រង់ H សំណួរ ១, ២ និង ៣ ដូចខាងក្រោម៖

១. មិនរងគ្រោះទាល់តែសោះ

២. រងគ្រោះតិចតួច

៣. រងគ្រោះមធ្យម

៤. រងគ្រោះខ្លាំង

៥. រងគ្រោះខ្លាំងណាស់

# ផ្នែកទី ១. ផ្តោតលើការប្រែប្រួល

## ការពន្យល់អំពីឧបករណ៍[6]

ឧបករណ៍ផ្តោតលើការផ្លាស់ប្តូរ គឺជាការពិភាក្សាក្នុងក្រុមគោលដៅ(FGD) ដែលប្រើប្រាស់ជាសកម្មភាព"ចាប់ផ្តើម" ដើម្បីបង្ហាញអំពីប្រធានបទនៃការប្រែប្រួលអាកាសធាតុ និងបរិបទនៃVRA។ ដំណើរការនេះផ្តល់ឲ្យអ្នកសម្របសម្រួល និងអ្នកចូលរួម នូវពេលវេលាដើម្បីចែករំលែក និងពិភាក្សាបទពិសោធន៍របស់ខ្លួនដោយចំហអំពី"ការប្រែប្រួលអាកាសធាតុ" ដោយរាប់ចាប់ពីការប្រែប្រួលនៃប្រព័ន្ធអេកូឡូស៊ីក្នុងមជ្ឈដ្ឋានជុំវិញរបស់ពួកគេ រហូតដល់ផលប៉ះពាល់មកលើការចិញ្ចឹមជីវិត គ្រួសារ និងសង្គមរបស់ពួកគេ។

## គោលបំណងនៃឧបករណ៍នេះ

- ✓ បង្ហាញអំពីសញ្ញាណនៃការប្រែប្រួលអាកាសធាតុ និងបង្កើតការយល់ដឹងអំពីផលប៉ះពាល់ដែលទាក់ទងនឹងអាកាសធាតុ
- ✓ បង្ហាញនូវផលប៉ះពាល់ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងការប្រែប្រួលដទៃទៀត ដែលកើតឡើងនៅក្នុងមូលដ្ឋាន ដើម្បីកែលម្អការសម្របសម្រួល VRA
- ✓ ផ្តល់ព័ត៌មានជាមូលដ្ឋានសម្រាប់ការបង្កើតតារាងម៉ាទ្រិកវិភាគនិន្នាការជាប្រវត្តិសាស្ត្រនៃការប្រែប្រួលអាកាសធាតុ

## សម្ភារៈ

- ✓ វីដេអូអំពីការប្រែប្រួលអាកាសធាតុ - ២០ នាទី និងឧបករណ៍សម្រាប់បញ្ចាំង[7]
- ✓ ហ្វឺត ក្រដាសផ្ទាំងធំ និងបង់ស្អិត

រយៈពេលសម្របសម្រួល៖ ១ ម៉ោង

---

[6] ស្រង់ចេញពី៖ AIT-UNEP RRCAP, 2011a. An approach to Climate Change Adaptation Research: Events, Strategies, and drivers. Copyright © AIT-UNEP RRCAP 2011, Bangkok, Thailand

[7] សូមអាន 'Climate change awareness - Khmer videos' section in Chapter 2 for video resources.

## ផ្តោតលើការប្រែប្រួល - ការសម្របសម្រួល

**ជំហានទី ១**

ចាប់ផ្តើមដំណើរការនេះដោយពន្យល់ពីគោលបំណងនៃសកម្មភាពនេះ ដំណើរការ និងរបៀបប្រើប្រាស់លទ្ធផល។ បន្ទាប់មក ចាក់បញ្ចាំងវីដេអូដែលបានរៀបចំរួច។ បន្ទាប់ពីបញ្ចាំងវីដេអូរួច ស្នើអ្នកចូលរួមឲ្យផ្តល់យោបល់ ដូចជា តើវីដេអូនេះធ្វើឲ្យពួកគេមានអារម្មណ៍បែបណា (វិជ្ជមាន និងអវិជ្ជមាន) តើពួកគេអាចផ្សារភ្ជាប់សាច់រឿងក្នុងវីដេអូនេះ ជាមួយជីវិតពិតប្រចាំថ្ងៃរបស់ពួកគេដែរឬទេ?

**ជំហានទី ២**

ជំហានបន្ទាប់គឺត្រូវសម្របសម្រួលការពិភាក្សាក្នុងក្រុមគោលដៅ (FGD)។ ចូរកត់សំគាល់ថា ការប្រើពាក្យ "ប្រែប្រួលអាកាសធាតុ" តាំងពីដើមដំបូងក្នុងក្រុមពិភាក្សា មិនសំខាន់ទេ។ ពេលចាប់ផ្តើមដោយស្នើអ្នកចូលរួមឲ្យស្រមៃអំពីស្ថានភាពភូមិរបស់ពួកគេ និងប្រព័ន្ធអេកូឡូស៊ីនៅជុំវិញ បន្ទាប់មកនិយាយប្រាប់ជាចំហអំពីការប្រែប្រួលដែលបានកើតឡើងជាបន្តបន្ទាប់ ដូចជា ផ្លាស់ប្តូររនៃរដូវកាល ការប្រែប្រួលធនធានទឹក ដីជាតិដី លក្ខខណ្ឌបរិស្ថាន រហូតដល់ករណីគ្រោះថ្នាក់ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ឬជំងឺផ្សេងៗ។ ចូរកត់ត្រាការប្រែប្រួលសំខាន់ៗនៅលើក្រដាសផ្ទាំងធំនៅក្រោមជំពូក "ការប្រែប្រួលបរិស្ថាន"

> ការប្រែប្រួលបរិស្ថាន
>
> - ចម្លើយតប
> - ចម្លើយតប
> - ចម្លើយតប
> - ចម្លើយតប
> - ចម្លើយតប
> - ។ល។

**ជំហានទី ៣**

ស្នើឲ្យអ្នកចូលរួមគិតអំពី ការប្រែប្រួលដែលបានកត់សំគាល់ពីខាងដើម (ជំហានទី២) និងអធិប្បាយថាតើការប្រែប្រួលទាំងនេះបានបង្កផលប៉ះពាល់ ឬ កែប្រែយុទ្ធសាស្ត្រចិញ្ចឹមជីវិតរបស់ពួកគេបែបណា។ ចូរកត់ត្រាការប្រែប្រួលសំខាន់ៗនៅលើក្រដាសផ្ទាំងធំ នៅក្រោមជំពូក "ការប្រែប្រួលការចិញ្ចឹមជីវិត"

> ការប្រែប្រួលការចិញ្ចឹមជីវិត
>
> - ចម្លើយតប
> - ចម្លើយតប
> - ចម្លើយតប
> - ចម្លើយតប
> - ចម្លើយតប
> - ។ល។

ជំហានទី ៤

ដោយពិចារណាអំពីការប្រែប្រួល ដែលមានសរសេរនៅក្រោមជំពូកការប្រែប្រួលបរិស្ថាន និងការចិញ្ចឹមជីវិត ចូរស្នើអ្នកចូលរួមឲ្យអធិប្បាយថា តើ"ការប្រែប្រួល"ទាំងនេះ បង្កផលប៉ះពាល់បែបណា មកលើទំនាក់ទំនងសង្គមរបស់ពួកគេ និងការចូលរួមរបស់ពួកគេ នៅក្នុងសកម្មភាពអភិវឌ្ឍន៍សហគមន៍។ ចូរកត់ត្រាការប្រែប្រួលសំខាន់ៗ នៅលើក្រដាសផ្ទាំងធំ ក្រោមជំពូក "ការប្រែប្រួលសង្គម"

| ការប្រែប្រួលសង្គម |
|---|
| ▪ចម្លើយតប<br>▪ចម្លើយតប<br>▪ចម្លើយតប<br>▪ចម្លើយតប<br>▪ចម្លើយតប<br>▪ៗល។ |

ជំហានទី ៥

ចូរពិនិត្យជាមួយអ្នកចូលរួម នូវលទ្ធផលទាំងបី និងឆ្លុះបញ្ចាំង តាមរយៈការពិភាក្សា អំពីលទ្ធផលទាំងនេះ ដែលអាចចាត់ទុកថាជាលក្ខណៈគ្រោះថ្នាក់។ គូសបន្ទាត់ពីក្រោមលទ្ធផលទាំងបីលើក្រដាសផ្ទាំងធំខុសៗគ្នា។ បន្ទាប់មក ស្នើអ្នកចូលរួមឲ្យជ្រើសរើសពីក្នុងចំណោមលទ្ធផលដែលបានគូសបន្ទាត់ពីក្រោមទាំងនោះ នូវលទ្ធផលនានាដែលជាបញ្ហាព្រួយបារម្ភបំផុតសម្រាប់ពួកគេ។ ចូរកត់ត្រាបញ្ហាខ្លាំងជាងគេទាំងនោះលើក្រដាសផ្ទាំងធំមួយនៅក្រោមជំពូក "ការប្រែប្រួលលក្ខខណ្ឌគ្រោះថ្នាក់" (សូមអានឧទាហរណ៍)

| លក្ខខណ្ឌប្រែប្រួលដ៏គ្រោះថ្នាក់ |
|---|
| • រដូវប្រាំងមានរយៈពេលវែងជាងមុន<br>• ដំណាំខូចដោយសារការជន់លិចយូរ<br>• ការបាត់បង់ព្រៃឈើ<br>• អសន្តិសុខស្បៀង<br>• ខ្យល់ខ្លាំងជាងមុន<br>• អគ្គីភ័យ<br>• សត្វចិញ្ចឹមងាប់<br>• ប្រែប្រួលថេរៈវេលានៃរដូវវស្សា/ប្រាំង<br>• ជំនន់មានរយៈពេលយូរជាងមុន<br>• គ្រោះរាំងស្ងួត<br>• ភ្លៀងធ្លាក់ខ្លាំង<br>• ប្រាក់ចំណូលកាន់តែតិចពីមួយឆ្នាំទៅមួយឆ្នាំ<br>• បាត់បង់ប្រាក់ចំណូល<br>• កំណើនបំណុលប្រចាំគ្រួសារ<br>• កំណើនការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចដែលទាក់ទងនឹងសហគមន៍ |

ចូរប្រាប់អ្នកចូលរួមថា លទ្ធផលនេះនឹងយកទៅប្រើប្រាស់ ដើម្បីជួយបង្កើតតារាងវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ។

# ផ្នែកទី ២. ការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ

## សេចក្តីសង្ខេបអំពីឧបករណ៍

ការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ នាំទៅរកការបង្កើតបរិបទនៃ VRA ដោយលើកឡើងពីទស្សនៈរបស់សហគមន៍ អំពីការប្រែប្រួលអាកាសធាតុពីអតីតកាល។ ការវិភាគនេះ បំពេញបន្ថែមចំពោះឧបករណ៍ទម្រង់H ដោយអាចឲ្យអង្គការមិនមែនរដ្ឋាភិបាល(NGOs), អង្គការសហគមន៍មូលដ្ឋាន (CBOs), និងស្ថាប័នដទៃទៀត ធ្វើការវាយតម្លៃថា តើប្រជាពលរដ្ឋបានកត់សំគាល់អំពីការប្រែប្រួលនានានៃអាកាសធាតុឬទេ ទាក់ទងនឹងការប្រែប្រួលលក្ខខណ្ឌដ៏គ្រោះថ្នាក់។ ការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ ក៏ជួយអ្នកសម្របសម្រួលក្នុងការដាក់បញ្ចូលការពិភាក្សាទម្រង់ H នៅក្នុងបរិបទនៃលក្ខខណ្ឌប្រែប្រួលអាកាសធាតុដែលសំខាន់បំផុត និងព្រឹត្តិការណ៍ដែលពាក់ព័ន្ធផងដែរ។ លើសពីនេះ តាមរយៈការពិភាក្សាអំពីការប្រែប្រួលធាតុអាកាសនៅក្នុងរយៈពេលវែង សហគមន៍នានាបានដឹងដោយខ្លួនឯងអំពីថា តើការប្រែប្រួលអាកាសធាតុខុសគ្នាបែបណាពីការប្រែប្រួលធាតុអាកាស។

ដើម្បីទទួលផលបានច្រើនបំផុតពីការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ ជាការប្រសើរបំផុតគឺត្រូវសិក្សានិន្នាការនានាដែលផ្អែកលើក្រុមខុសៗគ្នា ដូចជា បុរស ស្ត្រី កុមារ មនុស្សចាស់ ក្រុមភាគតិចនិងជនជាតិដើម។ ការធ្វើបែបនេះផ្តល់ឱកាសដល់អ្នកចូលរួមទាំងអស់គ្នាក្នុងការចែករំលែកការសង្កេតឃើញរបស់ខ្លួនដោយសេរីអំពីការប្រែប្រួលជាបន្តបន្ទាប់ក្នុងពេលកន្លងមក និងពេលបច្ចុប្បន្ន និងដើម្បីកំណត់អត្តសញ្ញាណព្រឹត្តិការណ៍សំខាន់បំផុតនានា ឬ ការសង្កេតដែលមានសារៈសំខាន់ចំពោះក្រុមនីមួយៗ។

## គោលបំណងនៃឧបករណ៍នេះ

- ✓ គូសលក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស និងព្រឹត្តិការណ៍នានានៅក្នុងអំឡុងពេលកំណត់មួយ និងការយល់ឃើញរបស់អ្នកចូលរួមអំពីភាពងាយរងគ្រោះចំពោះព្រឹត្តិការណ៍ទាំងនេះ
- ✓ សិក្សាអំពី"ព្រឹត្តិការណ៍ប្រែប្រួលអាកាសធាតុសំខាន់ៗបំផុត" និងផលប៉ះពាល់ដែលព្រឹត្តិការណ៍ទាំងនោះបង្កមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍។

## សម្ភារៈ

- ✓ រៀបចំគំនូសតារាងអំពីប្រវត្តិនៃការប្រែប្រួលអាកាសធាតុ (សូមមើលគំរូ)
- ✓ លទ្ធផលចុងក្រោយពីឧបករណ៍ផ្តោតលើការប្រែប្រួល (ជំហានទី ៥)
- ✓ ហ្វីត ក្រដាសផ្ទាំងធំ និងបង់ស្អិត

រយៈពេលសម្របសម្រួល៖ ១,៥ ម៉ោង

# ការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ -ការសម្របសម្រួល

**ជំហានទី ១**

រៀបចំតារាងវិភាគនិន្នាការនៃដែលរំលឹកពីប្រវត្តិនៃការប្រែប្រួលអាកាសធាតុ។ គំរូមួយមានផ្តល់ជូនខាងក្រោម។ ចូរកត់សំគាល់ថា មានការកំណត់អំឡុងពេលជាបន្ថែមលើរបបនយោបាយ។ ការបង្ហាញពីពេលវេលាតាមរបៀបនេះអាចជួយអ្នកចូលរួមក្នុងការកំណត់អត្តសញ្ញាណ អំឡុងពេលពីអតីតកាល និងព្រឹត្តិការណ៍ដែលពាក់ព័ន្ធ។

**ជំហានទី ២**

ក្នុងពេលប្រើប្រាស់ព័ត៌មានដែលទទួលបានពីឧបករណ៍"ផ្តោតលើការប្រែប្រួល" ចូរស្នើអ្នកចូលរួមឲ្យគូសបញ្ជាក់ព្រឹត្តិការណ៍ដែលទាក់ទងនឹងអាកាសធាតុ ឬ ធាតុអាកាស និងផលប៉ះពាល់នានាដែលពួកគេមានការបារម្ភខ្លាំង។ បន្ទាប់មក បញ្ចូលព្រឹត្តិការណ៍ទាំងនោះទៅក្នុងតារាងវិភាគនិន្នាការនៃប្រវត្តិកន្លងមក។ អ្នកក៏អាចស្នើអ្នកចូលរួមឲ្យកំណត់សំណុំលក្ខណៈនៃលក្ខខណ្ឌគ្រោះថ្នាក់ ដោយបន្ថែម និងកែសម្រួលលក្ខខណ្ឌទាំងនេះក្នុងជួរឈរផងដែរ ដើម្បីបង្កើនភាពសំបូរបែបនៃដំណើរការស្វែងយល់។

| លក្ខខណ្ឌប្រែប្រួលដ៏គ្រោះថ្នាក់ |
|---|
| • រដូវប្រាំងមានរយៈពេលវែងជាងមុន<br>• ដំណាំខូចដោយសារការជន់លិចយូរ<br>• ការបាត់បង់ព្រៃឈើ<br>• អសន្តិសុខស្បៀង<br>• ខ្យល់ខ្លាំងជាងមុន<br>• អគ្គីភ័យ<br>• សត្វចិញ្ចឹមងាប់<br>• ប្រែប្រួលថេរៈវេលានៃរដូវវស្សា/ប្រាំង<br>• ជំនន់មានរយៈពេលយូរជាងមុន<br>• គ្រោះរាំងស្ងួត<br>• ភ្លៀងធ្លាក់ខ្លាំង<br>• ប្រាក់ចំណូលកាន់តែទាបពីមួយឆ្នាំទៅមួយឆ្នាំ<br>• បាត់បង់ប្រាក់ចំណូល<br>• កំណើនបំណុលប្រចាំគ្រួសារ<br>• កំណើនការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចដែលទាក់ទងនឹងសហគមន៍ |

| លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស | ១៩៨០-១៩៨៩ | ១៩៩០-១៩៩៩ |
|---|---|---|
| • រាំងស្ងួត (+៥សប្តាហ៍ ) | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • រដូវប្រាំងមានរយៈពេលវែងជាងមុន (+៣ សប្តាហ៍) | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ខូចដំណាំដោយការរាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ខូចដំណាំដោយទឹកជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ការធ្លាក់ភ្លៀងខ្លាំង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ទឹកជំនន់ខ្ពស់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ទឹកជំនន់រយៈពេលវែង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ការប្រែប្រួលអំឡុងពេលនៃរដូវវស្សា/ប្រាំង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |

ជំហានទី ៣

នៅក្នុងអំឡុងពេលនីមួយៗ និងយោងតាមលក្ខខណ្ឌគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ/ធាតុអាកាសដែលបានកំណត់ អ្នកចូលរួមត្រូវចាត់ថ្នាក់“ភាពងាយរងគ្រោះ”របស់ពួកគេលើមាត្រដ្ឋាន ១ ដល់ ៥ ដែល ១- មិនរងគ្រោះទាល់តែសោះ ៥- រងគ្រោះខ្លាំងណាស់។ ចូរទុកពេលសម្រាប់ពិភាក្សាក្នុងចំណោមក្រុមអ្នកចូលរួម ដើម្បីឯកភាពលើចំណាត់ថ្នាក់ តាមរយៈការមូលមតិ។ ចូរគូរវង្វង់យកចំណាត់ថ្នាក់ណាមួយដែលបានឯកភាពគ្នា។

ចូរគូរវង្វង់យកចម្លើយដូចបង្ហាញក្នុងតារាងខាងក្រោម។

| **លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស** | ១៩៨០-១៩៨៩ | ១៩៩០-១៩៩៩ |
|---|---|---|
| • រាំងស្ងួត (+៥សប្តាហ៍) | ១ **២** ៣ ៤ ៥ | ១ ២ **៣** ៤ ៥ |
| • រដូវប្រាំងមានរយៈពេលវែងជាងមុន (+៣ សប្តាហ៍) | ១ ២ ៣ **៤** ៥ | ១ ២ ៣ ៤ **៥** |
| • ខូចដំណាំដោយការរាំងស្ងួត | ១ ២ **៣** ៤ ៥ | ១ ២ ៣ ៤ **៥** |
| • ខូចដំណាំដោយទឹកជំនន់ | ១ ២ ៣ ៤ **៥** | ១ ២ **៣** ៤ ៥ |
| • ការធ្លាក់ភ្លៀងខ្លាំង | ១ ២ **៣** ៤ ៥ | ១ ២ **៣** ៤ ៥ |
| • ទឹកជំនន់ខ្ពស់ | **១** ២ ៣ ៤ ៥ | **១** ២ ៣ ៤ ៥ |
| • ទឹកជំនន់រយៈពេលវែង | ១ ២ ៣ **៤** ៥ | ១ ២ **៣** ៤ ៥ |
| • ការប្រែប្រួលអំឡុងពេលនៃរដូវវស្សា/ប្រាំង | ១ **២** ៣ ៤ ៥ | ១ ២ **៣** ៤ ៥ |

ចាត់ថ្នាក់ភាពងាយរងគ្រោះ ... សួរថា ... តើបញ្ហានោះធំប៉ុណ្ណា?

**គន្លឹះ**

ជំហានទី ៤

ចូរសិក្សាច្រើនថែមទៀតអំពីព្រឹត្តិការណ៍ធ្ងន់ធ្ងរនានា។ ដោយប្រើប្រាស់តារាងវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុកន្លងមក ចូរកំណត់អត្តសញ្ញាណអំឡុងពេលសំខាន់ៗជាទីចាប់អារម្មណ៍ ពោលគឺ អំឡុងពេលដែលត្រូវគូសយកពិន្ទុ ៤ ឬ ៥។ សួរអ្នកចូលរួមអំពីព្រឹត្តិការណ៍នានាដែលកើតឡើងនៅក្នុងអំឡុងពេលនោះ ជាពិសេសអំឡុងពេលដែលមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើការចិញ្ចឹមជីវិត និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ។ បើអាចធ្វើបាន ចូរព្យាយាមស្វែងរកព័ត៌មានអំពីបរិមាណ ដូចជា៖

- តើការជន់លិចមានរយៈពេលប៉ុន្មាន?
- តើរដូវប្រាំងមានរយៈពេលវែងប៉ុណ្ណា?
- តើដំណាំប៉ុន្មានហិកតាដែលខូចខាត និងតើខូចខាតប៉ុន្មានភាគរយ?
- តើព្រឹត្តិការណ៍នោះកើតឡើងញឹកញាប់កម្រិតណានៅក្នុងអំឡុងពេលនោះ?
- តើមានការបាត់បង់អាយុជីវិតមនុស្សប៉ុន្មាននាក់?

គំរូតារាងវិភាគនិន្នាការនៃប្រែប្រួលអាកាសធាតុ

| លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និង ធាតុអាកាស | ១៩៨០-៨៩ *(វដ្តកម្ពុជា)* | ១៩៩០-៩៩ *(អ៊ុនតាក់ និង សម្ព័ន្ធមិត្ត)* | ២០០០-០៩ *(ព្រះរាជាណាចក្រកម្ពុជា)* | ២០១០-បច្ចុប្បន្ន *(ព្រះរាជាណាចក្រកម្ពុជា)* | ជម្រើស (ឆ្នាំបច្ចុប្បន្ន) | យោបល់ |
|---|---|---|---|---|---|---|
| • រាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • រដូវប្រាំងមានរយៈពេលវែងជាងមុន (+៣ សប្តាហ៍) | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ខូចដំណាំដោយការរាំងស្ងួត | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ខូចដំណាំដោយទឹកជំនន់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការធ្លាក់ភ្លៀងខ្លាំង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ទឹកជំនន់ខ្ពស់ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ទឹកជំនន់រយៈពេលវែង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |
| • ការប្រែប្រួលអំឡុងពេលនៃរដូវវស្សា/ប្រាំង | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | |

# ផ្នែកទី ៣. ដំណើរការឧបករណ៍ទម្រង់ H

## សេចក្ដីសង្ខេបអំពីឧបករណ៍

ឧបករណ៍ទម្រង់ H មានចំនួនបួន (៤) (ទម្រង់H សំណួរ ១ (Q1), ទម្រង់ H សំណួរ ២ (Q2), ទម្រង់ H សំណួរ ៣ (Q3), និងទម្រង់ H សំណួរ ៤ (Q4) ដោយផ្អែកលើសំណួរគន្លឹះ។ អ្នកចូលរួម ត្រូវបែងចែកជាក្រុមទៅតាមប្រធានបទ អនុលោមតាមលក្ខណៈដូចគ្នា ឬ ខុសគ្នានៃភាពងាយរងគ្រោះ ដូចជា បុរស ស្ត្រី មនុស្សចាស់ រហូតដល់អ្នកផ្ដល់សេវាកម្មអភិវឌ្ឍន៍ ដើម្បីអនុវត្តឧបករណ៍ទម្រង់ H។ ការបែងចែកជាក្រុមនេះ ធ្វើឡើងដើម្បីប្រមូលព័ត៌មានជាក់លាក់ ពីក្រុមអ្នកងាយរងគ្រោះ និងដើម្បីកំណត់អត្តសញ្ញាណវិធានការឆ្លើយតបដែលផ្តោតលើការកាត់បន្ថយភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុ។

## គោលបំណងនៃឧបករណ៍នេះ

- ✓ ស្រង់យកព័ត៌មានអំពីទិដ្ឋភាពខុសៗគ្នានៃការប្រែប្រួលអាកាសធាតុ ដែលរួមទាំង ការវិភាគអំពីហានិភ័យ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងពេលបច្ចុប្បន្ន និងទៅអនាគត
- ✓ ស្វែងយល់អំពីធនធាន និងយុទ្ធសាស្ត្រនានា ដែលសហគមន៍ប្រើប្រាស់ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងអំពីលទ្ធផលនៃយុទ្ធសាស្ត្រនានា
- ✓ កំណត់អត្តសញ្ញាណយុទ្ធសាស្ត្រសម្រាប់បន្សាំ និងការគាំទ្រដែលចាំបាច់សម្រាប់ការកសាងសមត្ថភាពបន្សាំ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ

## សម្ភារៈ

- ✓ លទ្ធផលពីការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ ជាពិសេស លទ្ធផលដែលបានពីការចាត់ថ្នាក់ភាពងាយរងគ្រោះ រួមជាមួយ លក្ខខណ្ឌគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ និងធាតុអាកាស
- ✓ រៀបចំទម្រង់ H នៅលើក្រដាសផ្ទាំងធំ ដូចមានបង្ហាញនៅក្នុងការណែនាំអ្នកសម្របសម្រួល - ត្រូវការយ៉ាងហោចណាស់ ៤ សន្លឹក សម្រាប់ក្រុមនីមួយៗ សម្រាប់លក្ខខណ្ឌគ្រោះថ្នាក់នីមួយៗ ដែលជ្រើសរើសដើម្បីសិក្សា។ ប្រសិនបើធ្វើការអនុវត្តទម្រង់ H ជាលក្ខណៈបុគ្គល គេត្រូវការទម្រង់ H ចំនួន៤ (ក្រដាសទំហំ A៤ សម្រាប់លក្ខខណ្ឌគ្រោះថ្នាក់នីមួយៗ ដែលបានជ្រើសយកដើម្បីសិក្សា)
- ✓ ហ្វឺត ក្រដាសផ្ទាំងធំ និងបង់ស្អិត

រយៈពេលសម្រាប់ការសម្របសម្រួលគួរតែមាន ៣ ម៉ោង

សំគាល់៖ ចូរកំណត់អត្តសញ្ញាណក្រុមអ្នកចូលរួម មុននឹងសម្របសម្រួលការអនុវត្តឧបករណ៍ទម្រង់ H។ ដោយប្រាប់អ្នកចូលរួមទាំងអស់អំពីប្រការនេះ គេអាចសំចៃពេលបានច្រើន។

## ទម្រង់H សំណួរ១ - ការសម្របសម្រួល

**ជំហានទី ១**

ដើម្បីកំណត់សំណួរគោលសម្រាប់ដំណើរការទម្រង់ H គេត្រូវផ្តោតលើព្រឹត្តិការណ៍អាកាសធាតុនិងធាតុអាកាសមិនប្រក្រតី ដែលប៉ះពាល់ធ្ងន់ធ្ងរបំផុតមកលើការចិញ្ចឹមជីវិត ឬសុខុមាលភាពរបស់សហគមន៍ ដូចជាសន្តិសុខស្បៀង។ ជំហានទី១ ចាប់ផ្តើមដោយរម្លឹកអ្នកចូលរួម អំពីលទ្ធផលនៃឧបករណ៍វិភាគនិន្នាការនៃប្រវត្តិកន្លងមក ជាពិសេស៖

- "**លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស**" ដែលអ្នកចូលរួមបានកំណត់
- លក្ខខណ្ឌដែលអ្នកចូលរួមបានបង្ហាញថា ពួកគេមានភាពងាយរងគ្រោះ(ដូចជា លក្ខខណ្ឌដែលបានចាត់ថ្នាក់ក្នុងពិន្ទុ ៤ ឬ ៥ នៅក្នុងបណ្តាឆ្នាំក្រោយៗមក)

ឧទាហរណ៍

| លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស | – | ១៩៩០-៩៩ | ២០០០-០៩ | ២០១០-បច្ចុប្បន្ន |
|---|---|---|---|---|
| • រាំងស្ងួត (+៥សប្តាហ៍ ) | | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • រដូវប្រាំងមានរយៈពេលវែងជាងមុន (+៣ សប្តាហ៍) | | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ខូចដំណាំដោយការរាំងស្ងួត | | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ខូចដំណាំដោយទឹកជំនន់ | | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ការធ្លាក់ភ្លៀងខ្លាំង | | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ទឹកជំនន់ខ្ពស់ | | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ទឹកជំនន់រយៈពេលវែង | | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |
| • ការប្រែប្រួលអំឡុងពេលនៃរដូវវស្សា/ប្រាំង | | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ | ១ ២ ៣ ៤ ៥ |

**ជំហានទី ២**

ដើម្បីអាចគ្រប់គ្រង VRA បាន និងអាចផ្តោតលើកន្លែងនានាដែលកាត់បន្ថយភាពងាយរងគ្រោះចំពោះផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ ត្រូវតែផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនទើបជាការប្រសើរ គឺត្រូវធ្វើការជាមួយលក្ខខណ្ឌគ្រោះថ្នាក់ដ៏ខ្លាំងបំផុតចំនួនពីរ។ អ្នកចូលរួមអាចរើសយកលក្ខខណ្ឌទាំងនេះដោយបោះឆ្នោត/ចំនួននៃចម្លើយតប ឬ ការមូលមតិជារួម។

តាមរយៈឧទាហរណ៍ដែលផ្តល់ឲ្យ ជម្រើសល្អបំផុតគឺត្រូវដោះស្រាយ ១) គ្រោះរាំងស្ងួត និងការខូចខាតដែលកើតមានចំពោះដំណាំកសិកម្ម និង ២) ទឹកជំនន់ និងការខូចខាតដែលបានបង្កចំពោះដំណាំកសិកម្ម។

**ជំហានទី ៣**

ទម្រង់អក្សរ H តម្រូវឲ្យសួរសំណួរមួយ។ អ្នកសម្របសម្រួល ឬ អ្នកចូលរួម អាចយកព័ត៌មានដែលទទួលបានក្នុងជំហានទី២ និងបង្កើតទៅជាសំណួរមួយ។ ឧទាហរណ៍៖

- តើអ្នកធ្លាប់ជួបប្រទះបទពិសោធន៍អ្វីខ្លះ ដោយសារតែគ្រោះរាំងស្ងួត (+៥ សប្តាហ៍ យូរជាងរយៈពេលធម្មតានៃរដូវប្រាំង) និងតើវាបង្កការប៉ះពាល់បែបណាមកលើអ្នក?
- តើអ្នកធ្លាប់មានបទពិសោធន៍អ្វីខ្លះ ដោយសារតែទឹកជំនន់រយៈពេលវែង និងតើទឹកជំនន់នេះបង្កផលប៉ះពាល់បែបណាខ្លះដល់អ្នក?

ចូរចងចាំថា អ្នកកំពុងធ្វើការនៅក្នុងក្រុមដាច់គ្នា ដូចជា ស្ត្រី បុរស យុវជនតំណាងពីរដ្ឋាភិបាល។ល។

ដូច្នេះ ការឆ្លើយតបនឹងមានភាពខុសគ្នារវាងក្រុមខុសៗគ្នា

**គន្លឹះ**

**ជំហានទី ៤**

ចូរបញ្ចូលសំណួរដែលបានបង្កើតឡើងនេះទៅក្នុងទម្រង់អក្សរ H ដែលបានត្រៀមរួច។ ចូរដាក់សំណួរតែមួយ(១) ទៅក្នុងទម្រង់H។ ចំពោះសំណួរដទៃទៀតដែលត្រូវសិក្សា គេត្រូវការទម្រង់ H ថែមទៀត (សូមអានឧទាហរណ៍ខាងក្រោម)



**ជំហានទី ៥**

ដើម្បីសម្រួលដល់ការពិភាក្សាអំពី "ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពសហគមន៍" អ្នកសម្របសម្រួលត្រូវជួយអ្នកចូលរួមឲ្យគិតអំពីលក្ខខណ្ឌខុសៗគ្នា ដូចជា ផលប៉ះពាល់មកលើធនធានទាំងប្រាំក្រុមដែលទ្រទ្រង់ការចិញ្ចឹមជីវិត (មនុស្ស ធម្មជាតិ ហិរញ្ញវត្ថុ សង្គម និងរូបវន្ត) ឬ ធាតុផ្សំនៃសុខុមាលភាព (សន្តិសុខសម្ភារៈជាមូលដ្ឋានសម្រាប់ការរស់នៅ សុខភាពនិងទំនាក់ទំនងសង្គម)។ [8] សំណួរសម្រាប់អ្នកសម្របសម្រួលមានផ្តល់ជូនខាងក្រោម។

| ការចិញ្ចឹមជីវិត | សុខុមាលភាពរបស់សហគមន៍ |
|---|---|
| ▪ តើធនធានធម្មជាតិដែលអ្នកប្រើប្រាស់សម្រាប់ចិញ្ចឹមជីវិតរបស់អ្នក បានរងការប៉ះពាល់អ្វីខ្លះ និងប៉ះពាល់បែបណា? | ▪ តើសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកបានរងការប៉ះពាល់បែបណា? |
| ▪ តើមានការប៉ះពាល់បែបណាដល់សមត្ថភាពក្នុងការរកចំណូលរបស់អ្នក? | ▪ តើសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់គ្រួសាររបស់អ្នកបានរងការប៉ះពាល់បែបណា? |
| ▪ តើក្រុមនានានៅមូលដ្ឋានរងការប៉ះពាល់បែបណាដូចជាក្រុមស្ត្រីសន្សំប្រាក់និងក្រុមផ្តល់កម្ចី អង្គការកសិករ ក្រុមគាំពារសង្គម ក្រុមគាំពារសុខុមាលភាពមូលដ្ឋាន។ល។? | ▪ តើសុខភាពផ្ទាល់ខ្លួនរបស់អ្នកបានរងការប៉ះពាល់បែបណា? |
| ▪ តើហេដ្ឋារចនាសម្ព័ន្ធដែលជាបង្អែកសម្រាប់ការចិញ្ចឹមជីវិតរបស់អ្នកបានរងការប៉ះពាល់បែបណាខ្លះ? | ▪ តើលទ្ធភាពរបស់អ្នកក្នុងការទទួលបានទឹកស្អាតរងការប៉ះពាល់បែបណា? |
| ▪ តើសមត្ថភាពក្នុងការរួមចំណែកជាកម្លាំងពលកម្មនិងការអនុវត្តការងារផ្សេងៗមានផលប៉ះពាល់បែបណា? | ▪ តើទំនាក់ទំនងសង្គមរបស់អ្នកបានរងការប៉ះពាល់បែបណា? |
| ▪ តើមានការប៉ះពាល់បែបណាដល់សមត្ថភាព ដើម្បីធ្វើការ ឬប្រើប្រាស់ចំណេះដឹងនិងជំនាញរបស់អ្នកដើម្បីចិញ្ចឹមជីវិត? | ▪ តើសមត្ថភាពរបស់អ្នកក្នុងការជួយអ្នកដទៃ បានរងការប៉ះពាល់ដែរឬទេ? |

ចម្លើយទាំងអស់តបនឹងសំណួររបស់អ្នកសម្របសម្រួល និងគំនិតដទៃទៀតរបស់អ្នកចូលរួម ត្រូវតែបញ្ចូលទៅក្នុងជួរឈរខាងឆ្វេងនៅក្នុងទម្រង់ H។

| ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ | *តើអ្នកមានបទពិសោធន៍អ្វីខ្លះដែលអ្នកបានជួបប្រទះកន្លងមកអំពីគ្រោះរាំងស្ងួត (+៥សប្តាហ៍ វែងជាងរដូវប្រាំងធម្មតា) និងតើស្ថានភាពនោះប៉ះពាល់អ្នកបែបណា?*<br>១ ២ ៣ ៤ ៥ | ធនធានដែលមានស្រាប់ និងយុទ្ធសាស្ត្រដែលប្រើប្រាស់ ដែលបានកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និង |
|---|---|---|
| ▪ *ចម្លើយតប*<br>▪ *ចម្លើយតប*<br>▪ *ចម្លើយតប*<br>▪ *ចម្លើយតប* | | |

[8] Millennium Ecosystem Assessment (2005). Ecosystems and Well-being Synthesis report. Washington DC: Island Press. v+86 pp.

## គន្លឹះអំពីការកើតឡើងញឹកញាប់(ប្រេកង់) និងការបញ្ចូលទិន្នន័យជាក្រុម

ការកើតឡើងញឹកញាប់៖ នៅពេលធ្វើការវិភាគ VRA របស់អ្នក ប្រការសំខាន់គឺត្រូវគូសបញ្ជាក់អំពី“កម្រិតញឹកញាប់នៃការឆ្លើយតប” ទៅនឹងសំណួរដែលបានសួរ (សំណួរទី១, សំណួរទី២ និង សំណួរទី៣), ឬនៅពេលចាត់អាទិភាពសកម្មភាពឆ្លើយតបនឹងភាពងាយរងគ្រោះ(សំណួរទី៤)។ នេះជាដំណើរការងាយមួយដែលទាមទារឲ្យអ្នកសម្របសម្រួល ១) ធានាថាអ្នកចូលរួមទាំងអស់មានឱកាសដើម្បីឆ្លើយសំណួរ និង ២) សម្របសម្រួលឲ្យមានការពិនិត្យឡើងវិញត្រួសៗលើចម្លើយតបដែលទទួលបាន នៅពេលសួរអ្នកចូលរួម ថាតើពួកគេជួបបទពិសោធន៍អ្វីខ្លះដូចគ្នាឬទេ និងចង់បន្ថែមការឯកភាពរបស់ខ្លួនចំពោះចម្លើយតបដែលបានកត់ត្រាហើយនោះដែរឬទេ។

ទី១

គន្លឹះ៖ នៅពេលបានទទួលចម្លើយតបដូចគ្នា ទៅនឹងចម្លើយដែលបានកត់ត្រារួចហើយ គ្រាន់តែគូសសញ្ញាសំគាល់មួយនៅជាប់នឹងចម្លើយដែលបានកត់ត្រានោះជាការស្រេច។




ទី២

គន្លឹះ៖ នៅពេលដែលអ្នកចូលរួមចាប់អារម្មណ៍ថា ពួកគេលែងមានចម្លើយបន្ថែមទៀតហើយនោះ អ្នកត្រូវបញ្ចប់ដោយសម្រួលឲ្យមានការពិនិត្យចម្លើយទាំងនេះឡើងវិញ និងសួរអ្នកចូលរួមថា តើពួកគេចង់បន្ថែមអ្វីទៀតទៅលើចម្លើយដែលបានកត់ត្រាហើយដែរឬទេ ប្រសិនបើពួកគេនៅពុំទាន់បានធ្វើបែបនោះ។ ចូរដាក់សញ្ញាសំគាល់ នៅជាប់នឹងចម្លើយដែលបានកត់ត្រា ប្រសិនបើចាំបាច់។ ប្រយ័ត្ន! ជាញឹកញាប់ អ្នកចូលរួមអាចថាតាមគ្នា និងឯកភាពជាមួយអ្វីៗទាំងអស់ដែលបានកត់ត្រា។ ត្រូវឲ្យប្រាកដថា អ្នកដែលមានបំណងបន្ថែមការឯកភាពរបស់ខ្លួនជាមួយចម្លើយដែលបានសរសេររួចហើយថា ការធ្វើបែបនេះមានសារៈសំខាន់ណាស់សម្រាប់ពួកគេ។

ការបញ្ចូលជាក្រុមៈ ការបញ្ចូលជាមួយគ្នានូវចម្លើយស្រដៀងគ្នារបស់អ្នកចូលរួម អាចធ្វើឲ្យងាយស្រួល និងធ្វើឲ្យការវិភាគ VRA មិនសូវស្មុគស្មាញ។ នៅពេលដែលអស់ចម្លើយសម្រាប់សំណួរណាមួយហើយនោះ ដូចជា ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ គេគួរតែមានការពិភាក្សាជាក្រុមអំពីថាតើចាត់ជាក្រុមបែបណាដើម្បីអាចបញ្ចូលចម្លើយទាំងនោះទៅតាមប្រធានបទរួម។ នេះមិនមែនជាវិទ្យាសាស្ត្រពិតឡើយ ហើយគេអាចមានឧទាហរណ៍ដែលពុំច្បាស់លាស់ ឬស្រពេចស្រពិល។ រាល់ចម្លើយគួរតែចាត់ជាក្រុមតាមរបៀបដែលអាចបង្ហាញឲ្យឃើញព័ត៌មានដែលកើតមានជាញឹកញាប់។ ឧទាហរណ៍ ខ្លះៗមានបង្ហាញខាងក្រោមនេះ។

| សំណួរទី១ - ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ | | |
|---|---|---|
| **កង្វះស្បៀង** | **កសិផលមានកម្រិតទាប** | **សុខភាពសត្វ** |
| • ច្បារដំណាំមិនផ្តល់ផល | • ស្រូវខូចដោយសារខ្យល់ព្យុះ | • ជ្រូកមិនស៊ីចំណី |
| • គ្មានទឹកសម្រាប់ស្រោចដំណាំ | • ជំងឺលើដំណាំស្រូវ | • គោ និងក្របីមានជំងឺ |
| • គ្មានទឹកសម្រាប់សត្វ | • ផលស្រូវប្រមូលបានតិចតួច | • ការផ្ទុះជម្ងឺសត្វ |
| • ស្បៀងឡើងថ្លៃ | • សំណាបងាប់ | • គ្មានចំណីសម្រាប់សត្វ |
| • ផលស្រូវប្រចាំគ្រួសារមិនគ្រប់គ្រាន់សម្រាប់ហូបពេញមួយឆ្នាំ | • ស្រូវនិងដំណាំដទៃទៀតខូច | • សត្វឈឺ និងងាប់ |

កម្រិតញឹកញាប់ និងការចាត់បញ្ចូលជាមួយគ្នារវាងក្រុមនានាៈ អាស្រ័យលើទិន្នន័យដែលត្រូវការ ឬ ដែលចង់បាន គេអាចចាត់បញ្ចូលក្រុមនានាមួយចំនួនជាមួយគ្នា នូវចម្លើយនានាដែលមានការទាក់ទងគ្នាជិតស្និទ្ធ ដូចជា ស្ត្រី និងបុរស។ ឧទាហរណ៍មានផ្តល់ជូនខាងក្រោម។

| សំណួរទី១ - ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ | |
|---|---|
| **កសិផលទទួលបានតិចតួច (បុរស)** | **កសិកផលទទួលបានតិចតួច (ស្ត្រី)** |
| • ស្រូវខូចដោយសារខ្យល់ព្យុះ | • ស្រូវខូចដោយសារខ្យល់ព្យុះ |
| • ទិន្នផលស្រូវថយចុះ ✓ ✓ ✓ ✓ ✓ | • ទិន្នផលស្រូវថយចុះ ✓ ✓ ✓ |
| • ផលស្រូវប្រមូលបានតិចតួច ✓ ✓ ✓ ✓ | • ផលស្រូវប្រមូលបានតិចតួច |
| • សំណាបងាប់ | • សំណាបងាប់ ✓ ✓ |

**កម្រិតញឹកញាប់៖** ១+១ សម្រាប់ចម្លើយ សរសេរ= ២

= ១០

= ៦

**កម្រិតញឹកញាប់៖** ១+១ សម្រាប់ចម្លើយសរសេរ + ២ = ៤

**ជំហានទី ៦**

ដើម្បីសម្រួលដល់ការពិភាក្សាអំពី"ធនធានដែលមានស្រាប់ និងយុទ្ធសាស្ត្រដែលបានប្រើប្រាស់ សម្រាប់កាត់បន្ថយផលប៉ះពាល់មកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍" សម្រាប់គោលបំណងនៃការវិភាគ ជាការល្អគឺថា អ្នកសម្របសម្រួលត្រូវជួយអ្នកចូលរួមឲ្យរៀបចំចម្លើយរបស់ពួកគេ ដូចជា ផលប៉ះពាល់ធៀបនឹងធនធាន ឬយុទ្ធសាស្ត្រ។ សំណួរខ្លះដែលបានស្នើឡើង មានបង្ហាញជូនដូចខាងក្រោម។

## ការចិញ្ចឹមជីវិត

- ដោយសារតែ"គ្រោះរាំងស្ងួត" តើអ្នកបានប្រើប្រាស់ឬធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយឬចំណាយអ្វីខ្លះលើផលប៉ះពាល់ដែលបានកើតឡើងមកលើធនធានធម្មជាតិដែលជាបង្អែកសម្រាប់ចិញ្ចឹមជីវិតរបស់អ្នក?
- ដោយសារ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់ឬធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយ ឬ ចំណាយអ្វីខ្លះចំពោះផលប៉ះពាល់ដែលបានកើតឡើងដែលរារាំងអ្នកក្នុងការបំពេញការចំណាយរបស់ខ្លួន?
- ដោយសារតែ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់ឬធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយ ឬទូទាត់ចំពោះផលប៉ះពាល់ដែលវាបានបង្កការរារាំងអ្នកក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាពលរដ្ឋ?
- ដោយសារតែ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់/ធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយ ឬទូទាត់ចំពោះផលប៉ះពាល់ដែលវាបានបង្កមកលើហេដ្ឋារចនាសម្ព័ន្ធដែលជាបង្អែកសម្រាប់ការចិញ្ចឹមជីវិតរបស់អ្នក?
- ដោយសារតែ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់/ធ្វើអ្វីខ្លះ ដើម្បីកាត់បន្ថយឬទូទាត់ចំពោះផលប៉ះពាល់ដែលវាបានបង្កមកលើសមត្ថភាពរបស់អ្នក ក្នុងការធ្វើពលកម្ម ឬរួមចំណែកក្នុងពលកម្ម?
- ដោយសារ"គ្រោះរាំងស្ងួត"តើអ្នកប្រើប្រាស់/ធ្វើអ្វីដើម្បីកាត់បន្ថយ ឬទូទាត់ចំពោះផលប៉ះពាល់ដែលវាបានបង្កមកលើសមត្ថភាពអ្នកក្នុងការប្រើប្រាស់ចំណេះដឹង និងជំនាញដើម្បីប្រកបរបរចិញ្ចឹមជីវិត?

## សុខុមាលភាពរបស់សហគមន៍

- ដោយសារ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់/ធ្វើអ្វីខ្លះ ដើម្បីការពារសុវត្ថិភាពបុគ្គលផ្ទាល់ខ្លួនរបស់អ្នក?
- ដោយសារ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់/ធ្វើអ្វីខ្លះ ដើម្បីរក្សាសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់គ្រួសាររបស់អ្នក?
- ដោយសារ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់/ធ្វើអ្វីខ្លះ ដើម្បីការពារសុខភាពផ្ទាល់ខ្លួនរបស់អ្នក?
- ដោយសារ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់/ធ្វើអ្វីខ្លះ ដើម្បីការពារ ឬ រក្សាលទ្ធភាពក្នុងការប្រើប្រាស់ទឹកស្អាត?
- ដោយសារ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់/ធ្វើអ្វីខ្លះ ដើម្បីការពារ ឬ រក្សាទំនាក់ទំនងសង្គមរបស់អ្នក?
- ដោយសារ"គ្រោះរាំងស្ងួត" តើអ្នកប្រើប្រាស់/ធ្វើអ្វីខ្លះ ដើម្បីការពារ ឬ រក្សាសមត្ថភាពដើម្បីការពារគ្នាទៅវិញទៅមក?

ត្រូវកត់ចម្លើយតបនឹងសំណួររបស់អ្នកសម្របសម្រួល និងយោបល់របស់អ្នកចូលរួមដទៃទៀត នៅជួរឈរខាងស្តាំក្នុងទម្រង់ H។

| ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ | *តើអ្នកមានបទពិសោធន៍អ្វីខ្លះក្នុងការប្រឈមនឹងគ្រោះរាំងស្ងួត (+៥សប្តាហ៍ វែងជាងរដូវប្រាំងធម្មតា) និងតើស្ថានភាពនោះប៉ះពាល់អ្នកបែបណា?* | ធនធានដែលមានស្រាប់ និងយុទ្ធសាស្ត្រដែលប្រើប្រាស់ ដែលបានកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ |
|---|---|---|
| | ១ ២ ៣ ៤ ៥ | *ធនធាន (ប្រើប្រាស់)*<br>▪ *ការឆ្លើយតប និងលទ្ធផល*<br>▪ *ការឆ្លើយតប និងលទ្ធផល*<br>*យុទ្ធសាស្ត្រ (ធ្វើ)*<br>▪ *ការឆ្លើយតប និងលទ្ធផល*<br>▪ *ការឆ្លើយតប និងលទ្ធផល* |

ជាញឹកញាប់ ការឆ្លើយតបចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ពុំផ្តល់លទ្ធផលដូចការចង់បានឡើយ។ នៅពេលអ្នកចូលរួមផ្តល់ចម្លើយរបស់ខ្លួន ជាការល្អត្រូវសួរថា តើអ្វីខ្លះជាលទ្ធផលនៃសកម្មភាពរបស់ពកគេ និងកត់តោលទផលនោះ។

**ជំហានទី ៧**

ក្រោយបានបំពេញជួរឈរខាងឆ្វេង និងខាងស្តាំក្នុងទម្រង់ H រួចហើយ ត្រូវពិនិត្យត្រួសៗជាមួយអ្នកចូលរួម។ បន្ទាប់មក ស្នើពួកគេឲ្យចាត់ថ្នាក់ភាពងាយរងគ្រោះជារួមចំពោះលក្ខខណ្ឌគ្រោះថ្នាក់ ដូចបានពិភាក្សាលើមាត្រដ្ឋាន ១ ដល់ ៥។ នៅពេលមានការមូលមតិ ចូរគូរវង្វង់យកចម្លើយនៅលើទម្រង់ H។

| ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ | *តើអ្នកមានបទពិសោធន៍អ្វីខ្លះ ក្នុងការប្រឈមនឹងគ្រោះរាំងស្ងួត (+៥សប្តាហ៍ វែងជាងរដូវប្រាំងធម្មតា) និងតើស្ថានភាពនោះប៉ះពាល់អ្នកបែបណា?* | ធនធានដែលមានស្រាប់ និងយុទ្ធសាស្ត្រដែលប្រើប្រាស់ ដែលបានកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ |
|---|---|---|
| | ៣ (៤) ៥ | |

៤.០៧

| | | | | |
|---|---|---|---|---|
| | *២* | *៥* | *៩* | *១១* |
| ១ | ២ | ៣ | ៤ | ៥ |

*គណនា៖ (២x២)+(៣x៥)+(៤x៩)+(៥x១១) = ១១០ ÷ ២៧(#សម្លេង)*

**ជម្រើស៖** ការចាត់ថ្នាក់ភាពងាយរងគ្រោះ ក៏អាចធ្វើបានផងដែរជាលក្ខណៈបុគ្គល/ការបោះឆ្នោត។ ដើម្បីគណនាពិន្ទុសរុប ត្រូវបូកពិន្ទុចំណាត់ថ្នាក់ទាំងអស់ជាមួយគ្នា និងចែកជាមួយចំនួនអ្នកចូលរួមដែលបានដាក់ពិន្ទុនោះ។

**ជំហានទី ៨**

ផ្នែកចុងក្រោយបំផុតនៃទម្រង់ H ផ្តែកលើសំណួរងាយមួយផងដែរ "តើគួរធ្វើអ្វីខ្លះ ដើម្បីកែលម្អពិន្ទុភាពងាយរងគ្រោះ?" សូមជួយអ្នកចូលរួមឲ្យគិតអំពីសកម្មភាព និងគិតផងដែរអំពីទ្រព្យទាំងប្រាំ( ៥ )ក្រុមសម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិត និង/ឬអំពីធាតុផ្សំនៃសុខុមាលភាព។

| ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ | *តើអ្នកមានបទពិសោធន៍អ្វីខ្លះ ក្នុងការប្រឈមនឹងគ្រោះរាំងស្ងួត (+៥សប្តាហ៍ វែងជាងរដូវប្រាំងធម្មតា) និងតើស្ថានភាពនោះប៉ះពាល់អ្នកបែបណា?* | ធនធានដែលមានស្រាប់ និងយុទ្ធសាស្ត្រដែលប្រើប្រាស់ ដែលបានកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ |
|---|---|---|
| | ១ ២ ៣ (៤) ៥ | |

- *ចម្លើយតប*
- *ចម្លើយតប*
- *ចម្លើយតប*

# ទម្រង់ H សំណួរ ២ - ការសម្របសម្រួល

ជំហានទី ៩

សំណួរនៃទម្រង់ H ត្រូវបានកំណត់តាមរបៀបស្រដៀងគ្នានឹងក្នុង សំណួរទី១ដែរ។ ភាពខុសគ្នាគឺអ្នកចូលរួមត្រូវបានស្នើឲ្យគិតអំពីស្ថានភាពដែលបង្កឡើងនៅក្នុង សំណួរទី១, ប៉ុន្តែកម្រិតញឹកញាប់របស់វាគឺ'ពីរដងខ្ពស់ជាង'។ ឧទាហរណ៍ខ្លះៗមានផ្តល់ជូនដូចខាងក្រោម៖

- សំណួរទី១: តើបទពិសោធន៍អ្វីខ្លះដែលអ្នកជួបប្រទះដោយសារគ្រោះរាំងស្ងួត(+៥ សប្តាហ៍វែងជាងរដូវប្រាំងធម្មតា) និងតើស្ថានភាពនេះបង្កផលប៉ះពាល់បែបណាចំពោះអ្នក?
- សំណួរទី២: តើអ្នកនឹងអាចជួបការលំបាកកម្រិតណា ប្រសិនបើគ្រោះរាំងស្ងួត (+៥ សប្តាហ៍វែងជាងរដូវប្រាំងធម្មតា)កើតឡើង"ពីរដងញឹកញាប់ជាងមុន" និងតើក្នុងករណីនេះ វាបង្កផលប៉ះពាល់បែបណាចំពោះអ្នក?

- សំណួរទី១: តើបទពិសោធន៍អ្វីខ្លះដែលអ្នកជួបប្រទះ ដោយសារតែទឹកជំនន់អូសបន្លាយរយៈពេលវែង និងតើវាបង្កផលប៉ះពាល់បែបណាចំពោះអ្នក?
- សំណួរទី២: តើអ្នកអាចជួបប្រទះស្ថានភាពបែបណា ប្រសិនបើទឹកជំនន់រយៈពេលវែងបែបនេះកើតមាន"ពីរដងញឹកញាប់ជាងមុន" និងតើវាអាចធ្វើឲ្យប៉ះពាល់បែបណាចំពោះអ្នក?

អាស្រ័យលើសំណួរដែលបានលើកឡើងក្នុង សំណួរទី១, និងចំណាប់អារម្មណ៍ជាពិសេស និងព្រឹត្តិការណ៍ដែលកើតឡើង គឺជាជម្រើសមួយ អ្នកសម្របសម្រួលអាចលើកសំណួរពាក់ព័ន្ធមួយដែលបង្ហាញពី"កម្លាំងពីរដងខ្លាំងជាង" មុខសញ្ញាគ្រោះថ្នាក់សម្រាប់ សំណួរទី២។ ឧទាហរណ៍ខ្លះៗ មានផ្តល់ជូនដូចខាងក្រោម។

- សំណួរទី១: តើអ្នកប្រឈមអ្វីខ្លះបណ្តាលពីភ្លៀងធ្លាក់ខ្លាំង ដែលធ្វើឲ្យខូចដំណាំកសិកម្ម និងតើបញ្ហានេះបង្កផលប៉ះពាល់បែបណាចំពោះអ្នក?
- សំណួរទី២: តើអ្នកអាចប្រឈមអ្វីខ្លះ ប្រសិនបើ"ភ្លៀងធ្លាក់ខ្លាំង" ពីរដងខ្លាំងជាងធម្មតា ដែលគិតជាការខូចខាតដំណាំកសិកម្ម និងតើប្រការនេះនឹងបង្កផលប៉ះពាល់បែបណាចំពោះអ្នក?
- សំណួរទី១: តើអ្នកជួបប្រឈមអ្វីខ្លះបណ្តាលពីខ្យល់បក់ខ្លាំងដែលធ្វើឲ្យខូចដំណាំកសិកម្ម និងតើវាបង្កផលប៉ះពាល់បែបណាចំពោះអ្នក?
- សំណួរទី២: តើអ្នកនឹងអាចជួបប្រឈមអ្វីខ្លះ ប្រសិនបើ "ខ្យល់បក់ខ្លាំង" មានកម្លាំងពីរដងខ្លាំងជាងធៀបនឹងករណីធម្មតាដូចបច្ចុប្បន្ន ដែលគិតជាការខូចខាតដំណាំកសិកម្ម និងតើប្រការនេះនឹងបង្កផលប៉ះពាល់បែបណាចំពោះអ្នក?

**ជំហានទី ១០**

នៅពេលបានរៀបចំសំណួររួចហើយ គេត្រូវដាក់សំណួរទាំងនោះនៅក្នុងទម្រង់ H ដូចពីមុន។ ការសម្របសម្រួលទម្រង់ H គួរតែយកលំនាំតាមរបៀបសម្រាប់សំណួរទី ១។ សូមអានសេចក្តីរំលឹកអំពីដំណើរការនេះដូចខាងក្រោម។

> សេចក្តីរំលឹក
>
> ចំពោះ សំណួរទី១ - សំណួរ៖
>
> - អ្នកចូលរួមត្រូវផ្តល់ការឆ្លើយតបចំពោះ“ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និង សុខុមាលភាពរបស់សហគមន៍”
> - អ្នកចូលរួមត្រូវផ្តល់ការឆ្លើយតបចំពោះ“ធនធានមានស្រាប់និងយុទ្ធសាស្ត្រដែលបានប្រើប្រាស់ដែលកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍”
> - អ្នកចូលរួមត្រូវបានស្នើឲ្យចាត់ថ្នាក់ភាពងាយរងគ្រោះជារួមរបស់ខ្លួន ចំពោះលក្ខខណ្ឌគ្រោះថ្នាក់តាមមាត្រដ្ឋានពី ១ ដល់ ៥
> - អ្នកចូលរួមត្រូវផ្តល់ការឆ្លើយតបចំពោះ“តើគួរធ្វើអ្វីខ្លះដើម្បីកែលម្អពិន្ទុភាពងាយរងគ្រោះ?”

ទោះជាយ៉ាងណាក៏ដោយ មិនមែនកន្លែងទាំងអស់ក្នុងទម្រង់ H សុទ្ធតែត្រូវសរសេរនោះឡើយ ដោយសារសំណួរដែលលើកឡើង ត្រូវបានដាក់ទៅអនាគត (សូមអានរូបភាពខាងក្រោម)។



# ទម្រង់ H សំណួរ៣ - ការសម្របសម្រួល

**ជំហានទី ១១**

សម្រាប់សំណួរទី៣ មានតែជួរឈរមួយប៉ុណ្ណោះដែលត្រូវបំពេញ នៅក្នុងទម្រង់ H។ ត្រូវបានប្រមូលយកព័ត៌មាន ដើម្បីគូសបញ្ជាក់ពីឧបសគ្គដែលសហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀតប្រឈម នៅក្នុងការប៉ុនប៉ងរបស់ពួកគេ ដើម្បីពុះពារ ឬ ដើម្បីបន្សាំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ដូចក្នុងករណីសំណួរទី១ និងសំណួរទី២ ដែរ ដំណើរការនេះពឹងផ្អែកលើសំណួរមួយ ដែលដាក់នៅក្នុងទម្រង់H។ សំណួរទី៣ ត្រូវបានរៀបចំឡើង ដោយទាក់ទងផ្ទាល់ជាមួយសំណួរនានាដែលប្រើប្រាស់នៅក្នុង សំណួរទី១ និង សំណួរទី២។ សូមអានឧទាហរណ៍ខាងក្រោម។

- សំណួរទី១: តើអ្នកប្រឈមនឹងបញ្ហាអ្វីខ្លះ បណ្តាលពីគ្រោះរាំងស្ងួត (+៥សប្តាហ៍វែងជាងរដូវប្រាំងធម្មតា) និងតើប្រការនេះបង្កការប៉ះពាល់បែបណាចំពោះអ្នក?
- សំណួរទី២: តើអ្នកអាចជួបប្រឈមអ្វីខ្លះ ប្រសិនបើគ្រោះរាំងស្ងួត (+៥សប្តាហ៍វែងជាងរដូវប្រាំងធម្មតា) កើតមានពីរដងញឹកញាប់ជាងបច្ចុប្បន្ន?
- សំណួរទី៤: តើអ្វីខ្លះរារាំងអ្នកពីការបន្សាំចំពោះគ្រោះរាំងស្ងួត(+៥សប្តាហ៍វែងជាងរដូវប្រាំងធម្មតា)?

**ជំហានទី ១២**

ត្រូវដាក់សំណួរដែលរៀបចំឡើងនេះនៅក្នុងទម្រង់ H ដូចមានបង្ហាញខាងក្រោម។ អ្នកសម្របសម្រួលត្រូវជួយអ្នកចូលរួមឲ្យឆ្លើយនឹងសំណួរនេះ ដោយធានាថា អ្នកចូលរួមត្រូវពិចារណាផ្នែកទាំងប្រាំ(៥)សម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិត និង/ឬ ដែលជាធាតុផ្សំនៃសុខុមាលភាពរបស់សហគមន៍។ ត្រូវដាក់ចម្លើយទៅក្នុងជួរឈរកណ្តាល ដូចមានបង្ហាញខាងក្រោម។



**ជំហានទី ១៣**

ជំហានចុងក្រោយនៅក្នុង សំណួរទី៣ គឺត្រូវស្នើអ្នកចូលរួមឲ្យចាត់ថ្នាក់ភាពងាយរងគ្រោះជារួមរបស់ពួកគេនៅក្នុងបរិបទនៃអ្វីដែលកំពុងរារាំងពួកគេពីការបន្សាំ







ចំពោះលក្ខខណ្ឌគ្រោះថ្នាក់។ ត្រូវសរសេរចម្លើយក្នុងជួរឈរកណ្តាលដូចបង្ហាញខាងក្រោម។

<u>ជម្រើស</u>៖ ការចាត់ថ្នាក់ភាពងាយរងគ្រោះក៏អាចធ្វើឡើងជាលក្ខណៈបុគ្គលផងដែរ។ ដើម្បីទទួលបានពិន្ទុសរុប ត្រូវបូកបន្ថែមពិន្ទុពីចំណាត់ថ្នាក់ទាំងអស់ និងចែកជាមួយចំនួនអ្នកចូលរួមដែលបានដាក់ពិន្ទុ។

# ទម្រង់ H សំណួរ ៤ - ការសម្របសម្រួល

**ជំហានទី ១៤**

ជំហាននេះមានបំណងចាត់សកម្មភាពនានាជាអាទិភាព ដូចបានកំណត់ក្នុងសំណួរទី១នៃទម្រង់អក្សរ H សម្រាប់អង្គការសហគមន៍ និង/សេវាកម្មអភិវឌ្ឍន៍សម្រាប់ការអនុវត្តវិធានការឆ្លើយតបនៃការបន្សាំរបស់សហគមន៍។

ដើម្បីសម្រួលដល់ដំណើរការនេះ អ្នកសម្របសម្រួលត្រូវរៀបចំទម្រង់ H ថ្មីមួយ ដែលមានចម្លើយតបនឹងសំណួរ "តើគួរធ្វើអ្វីខ្លះដើម្បីកែលម្អពិន្ទុភាពងាយរងគ្រោះ?" ដែលទាក់ទងផ្ទាល់ទៅនឹងលក្ខខណ្ឌគ្រោះថ្នាក់ ដូចមានចែងក្នុងសំណួរទី១ (សូមអានឧទាហរណ៍ខាងក្រោម)។




**ជំហានទី ១៥**

ស្នើអ្នកចូលរួម ឲ្យចាត់ថ្នាក់ចម្លើយក្នុងតារាងសកម្មភាពដែលមានសារៈសំខាន់បំផុត រហូតដល់ចម្លើយដែលមានសារៈសំខាន់តិចតួចបំផុតក្នុងការអនុវត្ត។ ប្រសិនបើតារាងនេះវែងខ្លាំង ចូរដាក់ចម្លើយប្រហាក់ប្រហែលគ្នាជាក្រុមជាមួយគ្នាបន្ទាប់មកអនុវត្តចំណាត់ថ្នាក់។ ការធ្វើបែបនេះអាចប្រព្រឹត្តទៅដោយបោះឆ្នោត ឬ ការមូលមតិគ្នា ឬ តាមរយៈការប្រើប្រាស់ឧបករណ៍ចំណាត់ថ្នាក់ (សូមអានឯកសារចែកជូន S12.5, Solar, R. 2014[9])

---

[9] Solar, R. 2014. Building Climate Resilience: A Training Manual for Community Based Climate Change Adaptation. Regional Climate Change Adaptation Knowledge Platform for Asia, Partner Report Series No. 14. Regional Resource Centre for Asia and the Pacific (RRC.AP), Asian Institute of Technology, Thailand.

ជម្រើស៖ ប្រសិនបើមានពេលគ្រប់គ្រាន់ គេអាចអនុវត្តជំហានទី១៥ ឡើងវិញ ដោយប្រើប្រាស់ព័ត៌មានពីសំណួរទី២នៅក្នុងទម្រង់ H ដោយកែតម្រូវតាមរបៀបដូចគ្នានឹងសេចក្តីដែលចែងក្នុងជំហានទី១៤ដែរ (សូមអានឧទាហរណ៍ខាងក្រោម)។




នៅពេលដែលបានអនុវត្តលំហាត់ចាត់លំដាប់អាទិភាពរួចរាល់ហើយ អ្នកចូលរួមត្រូវចាត់ថ្នាក់កម្រិតទំនុកចិត្តរបស់ពួកគេប្រសិនបើសកម្មភាពសំខាន់ៗជាអាទិភាពត្រូវបានអនុវត្ត ភាពងាយរងគ្រោះរបស់ពួកគេចំពោះការប្រែប្រួលអាកាសធាតុ នឹងបានកែលម្អ (សូមអានឧទាហរណ៍ខាងក្រោម)។



# ផ្នែកទី ៤. ការបូកសរុប VRA

## គោលបំណង

- ✓ ធានាថា អ្នកចូលរួមទាំងអស់យល់ពីសារៈសំខាន់នៃកិច្ចប្រឹងប្រែងរបស់ពួកគេនៅទូទាំងសិក្ខាសាលា VRA
- ✓ ផ្តល់ព័ត៌មានដល់អ្នកចូលរួមអំពី"ជំហានបន្ទាប់" ពោលគឺ អ្វីដែលត្រូវធ្វើជាមួយទិន្នន័យដែលប្រមូលបាន ពេលណាដែលសហគមន៍មានឱកាសដើម្បីផ្ទៀងផ្ទាត់ការវិភាគទិន្នន័យ និងរាល់សកម្មភាពនៅពេលខាងមុខដោយអង្គការដែលជាអ្នកអនុវត្ត VRA

## ការបូកសរុបរបស់អ្នក

ក្រោយពេលដែលបានអនុវត្តលំហាត់ទម្រង់Hរួចហើយ ជាការល្អត្រូវតែមានការបូកសរុប និងសង្ខេបជូនអ្នកចូលរួម។ ដោយសារតែហេតុផលជាក់ស្តែង ប្រការនេះអាចធ្វើទៅមិនបាន ជាពិសេស ប្រសិនបើប្រើប្រាស់វិធីសាស្ត្រក្រុមគោលដៅ ដោយសារតែមិនមែនក្រុមគោលដៅទាំងអស់សុទ្ធតែអាចបញ្ចប់នៅពេលតែមួយឡើយ។ ទោះជាយ៉ាងណាក្តី ចូរប្រឹងប្រែងលៃលកយ៉ាងណាឲ្យក្រុមនានាអនុវត្តតាមពេលម៉ោងដែលបានកំណត់។ ដើម្បីបូកសរុបសិក្ខាសាលា VRA តារាងត្រួតពិនិត្យខាងក្រោមនេះផ្តល់ជាការណែនាំ៖

- ☑ ចូរថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ ដែលបានចាត់វិធានការដ៏មានសារៈសំខាន់ ឆ្ពោះទៅកសាងភាពធន់របស់សហគមន៍ ឬ វាយតម្លៃខ្ពស់ចំពោះការចំណាយពេលរបស់ពួកគេ ប្រសិនបើលំហាត់នេះធ្វើឡើងសម្រាប់គោលដៅនៃការស្រាវជ្រាវ។
- ☑ ស្នើអ្នកចូលរួមនៅក្នុងក្រុមគោលដៅនីមួយៗ បង្ហាញពីអ្វីដែលពួកគេចូលចិត្តបំផុតអំពីសិក្ខាសាលា VRA នេះ និងអ្វីខ្លះដែលពួកគេបានរៀនសូត្រពីសិក្ខាសាលានេះ
- ☑ ជម្រាបជូនអ្នកចូលរួមថា ក្រុមអ្នកអនុវត្ត VRA នឹង"រៀបចំទិន្នន័យ" (ការវិភាគ) និងវិលត្រឡប់មកសហគមន៍នេះវិញ ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យនេះ និងរបកគំហើញសំខាន់ៗ និងពេលវេលា
- ☑ ជម្រាបជូនអ្នកចូលរួមអំពីរបៀបប្រើប្រាស់ទិន្នន័យ និងរបកគំហើញទាំងនេះ
- ☑ ជម្រាបជូនអ្នកចូលរួមអំពីសកម្មភាពជាក់លាក់ជាបន្ត ដែលត្រូវការឲ្យពួកគេចូលរួម
- ☑ ថ្លែងអំណរគុណ និងចូលរួមក្នុងការចាប់អារម្មណ៍ពីស្មារតីនៃការសម្រេចផលរួមគ្នា

រយៈពេលសមស្របសម្រាប់ការសម្របសម្រួលគួរតែមាន៣០នាទី។

# ជំពូក ៤
# ការវិភាគលទ្ធផលពី VRA

## សេចក្ដីសង្ខេប

ជំពូកនេះមានគោលដៅផ្ដល់ឲ្យភ្នាក់ងារអនុវត្ត VRA នៅមូលដ្ឋាននូវឧបករណ៍ងាយៗ ដើម្បីជួយនៅក្នុងការវិភាគ VRA ក្នុងកម្រិតអប្បបរមា។ ឧបករណ៍ដែលមាននៅទីនេះ ដូចជា មធ្យមភាគ ក្រាហ្វិកខ្សែបន្ទាត់ និងក្រាហ្វិកដំបង រហូតដល់តារាងប្រៀបធៀប ដែលអាចប្រើប្រាស់រួមផ្សំជាមួយគ្នា ដើម្បីធ្វើការវិភាគងាយៗ ប៉ុន្តែមានប្រយោជន៍នូវទិន្នន័យដែលបានពី VRA។ នៅទូទាំងជំពូកនេះ មានការពិភាក្សាអំពីសំណួរនីមួយៗនៅក្នុងទម្រង់ H ដោយបូកសរុបតាមរយៈទិដ្ឋភាពរួមអំពីថាតើគួរមានការវិភាគអ្វីខ្លះ និងតើគួរធ្វើរបាយការណ៍បែបណាអំពីទិន្នន័យដែលបានពីការវិភាគនេះ។ ចំណុចនេះគួរតែរាប់បញ្ចូលផងដែរនូវទិន្នន័យញែកដាច់គ្នា រវាងក្រុមងាយរងគ្រោះ រហូតដល់រវាងភូមិ ឬ ឃុំនានា និងតាមលំដាប់ទៅលើផងដែរ។

គួរកត់សំគាល់ថា ជំពូកនេះមានបំណងជួយភ្នាក់ងារអនុវត្ត VRA នៅមូលដ្ឋាន កសាងជំនាញវិភាគរបស់ពួកគេ។ ជំពូកនេះគ្មានគោលដៅផ្ដល់គំរូអំពីក្រាហ្វិកនៃគ្រប់ទិន្នន័យដែលមាន និង/ឬ រូបនានាដែលអាចរៀបចំជារបាយការណ៍ ឬ ដែលគួរតែរៀបចំជារបាយការណ៍ VRA នោះឡើយ។

## គោលបំណងនៃជំពូកនេះ

- ✓ ផ្ដល់ការយល់ដឹងជាមូលដ្ឋានអំពីរបៀបប្រើប្រាស់ឧបករណ៍វិភាគ ដើម្បីវាយតម្លៃ និងរាយការណ៍អំពីលទ្ធផលនៃ VRA
- ✓ ផ្ដល់ការណែនាំសម្រាប់ការវិភាគទិន្នន័យពី VRA ដែលរួមទាំង ទិន្នន័យញែកដាច់គ្នា និងការធ្វើរបាយការណ៍តាមស្តង់ដារសម្រាប់សំណួរនីមួយៗនៅក្នុងទម្រង់ H

# ឧបករណ៍វិភាគ

ដើម្បីរៀបចំទិន្នន័យ VRA សម្រាប់ការវិភាគ យើងប្រើប្រាស់ឧបករណ៍ងាយៗចំនួនបី (៣)៖

- ✓ តួលេខ'មធ្យមភាគ' ដើម្បីបង្ហាញពីកម្រិតនៃភាពងាយរងគ្រោះ ឬ ពិន្ទុអំពីទំនុកចិត្ត ចំពោះសំណួរនានាដែលលើកឡើងនៅក្នុងទម្រង់ H
- ✓ 'ក្រាហ្វិកខ្សែនិន្នាការ' ដើម្បីបង្ហាញនិន្នាការនៃភាពងាយរងគ្រោះទៅតាមពេលវេលា ធៀបនឹងលក្ខខណ្ឌគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ និងធាតុអាកាស
- ✓ 'ក្រាហ្វិកដំបង' ដើម្បីបង្ហាញភាពញឹកញាប់នៃចម្លើយទូទៅ និង/ឬ ដែលទាក់ទងជិតស្និទ្ធនៅក្នុងទម្រង់ H

**មធ្យមភាគ**

ការកំណត់រក'មធ្យមភាគ' គឺជាវិធីមួយ ដើម្បីប្រមូលយកពិន្ទុសរុបជាមធ្យម និងនៅក្នុងបរិបទនៃ VRAនេះ វាគឺជាការយល់ឃើញរបស់អ្នកចូលរួម អំពីភាពងាយរងគ្រោះចំពោះស្ថានភាពណាមួយ។ ឧទាហរណ៍សម្រាប់ សំណួរទី១ និង សំណួរទី២ ពិន្ទុអំពីភាពងាយរងគ្រោះជាមធ្យម ត្រូវបានគណនា ដើម្បីបង្ហាញកម្រិតនៃភាពងាយរងគ្រោះចំពោះសំណួរដែលបានលើកឡើងសម្រាប់អ្នកភូមិ និង/ឬ ក្រុមជាក់លាក់នៃអ្នកចូលរួម ដូចជា ស្ត្រី។ កិច្ចការនេះអាចធ្វើបាន ដោយបូកពិន្ទុដែលបុគ្គលម្នាក់ៗផ្តល់ឲ្យ និងបន្ទាប់មកចែកជាមួយចំនួនចម្លើយដែលបានផ្តល់ឲ្យ។

ចំពោះ សំណួរទី៣ 'អ្វីដែលរារាំងអ្នកពីការបន្សាំ' អ្នកចូលរួមនឹងត្រូវស្នើឲ្យពិនិត្យមើលឧបសគ្គទាំងអស់ដែលបានកត់សំគាល់ និងចាត់ថ្នាក់ភាពងាយរងគ្រោះរបស់ពួកគេចំពោះប្រការនេះ។ ការគណនាពិន្ទុមធ្យមនៃភាពងាយរងគ្រោះ ចំពោះចម្លើយតបនឹងសំណួរទី៣ ពោលគឺ ចម្លើយរបស់ក្រុមនេះ ត្រូវធ្វើឡើងដោយបន្ថែមពិន្ទុ ដែលធ្វើឡើងដោយអ្នកចូលរួម និងចែកជាមួយចំនួនបុគ្គលដែលបានផ្តល់ពិន្ទុ។ ដំណើរការដូចគ្នានេះត្រូវយកមកអនុវត្តសម្រាប់ សំណួរទី៤ផងដែរ។

មានគោលការណ៍ងាយៗចំនួនពីរដែលត្រូវអនុវត្តតាម នៅពេលគណនាពិន្ទុមធ្យម៖

១. នៅពេលចែកពិន្ទុសរុបជាមួយចំនួនចម្លើយ ចៀសវាងការចែកជាមួយចំនួនមនុស្សនៅក្នុងក្រុមនោះ។ អ្នកចូលរួមខ្លះអាចមិនផ្តល់ពិន្ទុ ដូច្នេះ តួលេខមធ្យមពុំត្រឹមត្រូវទេ។

២. ត្រូវឲ្យមានភាពជាក់លាក់អំពីថាតើអ្នកកំពុងគណនាតួលេខមធ្យមនៃអ្វី។ ឧទាហរណ៍ អ្នកមិនអាចបូកបញ្ចូលពិន្ទុដែលទាក់ទងនឹងសំណួរមួយ និងបន្ថែមសំណួរនេះទៅក្នុងពិន្ទុដែលទាក់ទងនឹងសំណួរខុស(មិនទាក់ទង)គ្នាបន្ទាប់មកចែកនឹងពីរឡើយ។ ការធ្វើបែបនេះមិនផ្តល់ឲ្យអ្នកនូវពិន្ទុសរុបអំពីភាពងាយរងគ្រោះឡើយ។

## ក្រាហ្វិកខ្សែនិន្នាការ

✓ ក្រាហ្វិកនៃលក្ខខណ្ឌដែលទាក់ទងនឹងអាកាសធាតុ និងធាតុអាកាស និងព្រឹត្តិការណ៍នានា នៅក្នុងអំឡុងពេលណាមួយដែលបានកំណត់ និងការយល់ឃើញរបស់អ្នកចូលរួម អំពីភាពងាយរងគ្រោះចំពោះព្រឹត្តិការណ៍ទាំងនេះ។

ក្រាហ្វិកខ្សែនិន្នាការ ប្រើប្រាស់ផ្នែក ‘X’ (ជួរដេក) និង ‘Y’ (ជួរឈរ)នានានៃក្រាហ្វិកស្តង់ដារ។ ក្រាហ្វិកខ្សែនឹងត្រូវប្រើប្រាស់ ដើម្បីបង្ហាញលទ្ធផលនៃការវិភាគនិន្នាការប្រវត្តិនៃការប្រែប្រួលអាកាសធាតុ។ ចំណុចនេះរាប់បញ្ចូលធាតុផ្សំចំនួនបី (៣)៖ ១)ចំណាត់ថ្នាក់ភាពងាយរងគ្រោះ(ពិន្ទុ)៖ ដាក់លើអ័ក្រ ‘Y’ ២) ខ្សែបញ្ជាក់អំពីពេលវេលា - ដាក់នៅលើខ្សែ ‘X’, និង ៣) ជ្រើសយកលក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស ស្រង់យកដោយផ្ទាល់ពីតារាងវិភាគនិន្នាការ។ គួរកត់សំគាល់ថា លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស អាចមានបង្ហាញជាក្រាហ្វិកខ្សែនិន្នាការតែមួយ ហើយមានតែក្រាហ្វិកខ្សែនិន្នាការប៉ុណ្ណោះដែលត្រូវការជាចាំបាច់សម្រាប់សិក្ខាសាលា VRA ដែលបានអនុវត្ត (សូមអានឧទាហរណ៍នៅក្នុងរូបទី ៣)។

ក្រាហ្វិកខ្សែនិន្នាការមានលក្ខណៈងាយស្រួលយល់។ ខ្សែបន្ទាត់ភាគច្រើនចាក់ឡើងលើ ខ្សែដទៃទៀតចាក់ចុះក្រោម និងខ្សែខ្លះមានស្ថិរភាព ដែលនេះជាការបង្ហាញពីនិន្នាការនេះ។

ចូរព្យាយាមជៀសវាងមាន អថេរច្រើនពេកនៅលើក្រាហ្វិកមួយដែលទាក់ទងនឹងគ្រោះរាំងស្ងួត និងអាចតំណាងព្រឹត្តិការណ៍ដែលទាក់ទងនឹងទឹកជំនន់ និងអំពីគ្រោះរាំងស្ងួតលើក្រាហ្វិកដាច់គ្នា។



រូបទី ៣. គំរូ"ក្រាហ្វិកខ្សែនិន្នាការ" ដែលបង្ហាញពីនិន្នាការនៃភាពងាយរងគ្រោះទៅតាមពេលវេលាចំពោះ លក្ខខណ្ឌគ្រោះថ្នាក់ខុសៗគ្នាដែលទាក់ទងនឹងអាកាសធាតុ និងធាតុអាកាស

ក្រាហ្វិកដំបងអំពីកម្រិតញឹកញាប់

- ✓ ចូរស្រង់យកព័ត៌មានជាក់លាក់ទៅតាមផលប៉ះពាល់ដែលកត់ត្រានៅក្នុង សំណួរទី១ និង សំណួរទី២ និងកម្រិតញឹកញាប់ បញ្ចូលទៅក្នុងទម្រង់ H ដើម្បីបង្ហាញពីសារៈសំខាន់នៅទូទាំងតំបន់គោលដៅនានា
- ✓ ស្រង់បញ្ចូលទៅក្នុងទម្រង់ H នូវព័ត៌មានដែលទាក់ទងនឹង "អ្វីរាំងរាំងអ្នកពីការបន្សាំ" (សំណួរទី៣) និងកម្រិតញឹកញាប់នៃចម្លើយតប ដើម្បីបង្ហាញពីសារៈសំខាន់នៅទូទាំងតំបន់គោលដៅនានា

<u>កំណត់សំគាល់សំខាន់ៗ៖</u> មិនត្រូវប្រើប្រាស់ក្រាហ្វិកដំបងដើម្បីតាងលទ្ធផលតាមក្រុមដែលផ្តល់ជាតួលេខមធ្យមឡើយ។ ជាញឹកញាប់បំផុត ក្រាហ្វិកដំបងត្រូវបានប្រើប្រាស់សម្រាប់ទិន្នន័យបែបអង្កេត។ ឧទាហរណ៍ ប្រសិនបើដំណើរការទម្រង់ H ត្រូវបានបំពេញតាមបុគ្គលម្នាក់ៗដាច់ពីគ្នា ឬប្រសិនបើមានការកត់ត្រាចំនួនចម្លើយជាក្រុម។ ក្នុងករណីទាំងនោះ ចម្លើយដូចគ្នាត្រូវបានរាប់ និងកត់ត្រាជា "កម្រិតញឹកញាប់នៃចម្លើយ"។ (សូមអានទំព័រ ៤៥ និង ៤៦ សម្រាប់ជាការរម្លឹក)

ក្រាហ្វិកដំបងប្រើប្រាស់"កម្រិតញឹកញាប់នៃចម្លើយ"ចំពោះសំណួរជាក់លាក់។ ចម្លើយនានាអាចមានភាពខុសគ្នា ដូច្នេះ ចម្លើយនីមួយៗត្រូវតែមានធាតុផ្សំរបស់វាតាងនៅក្នុងក្រាហ្វិក ដូចជា កង្វះអាហារូបត្ថម្ភ និងចំពោះចម្លើយប្រហែលគ្នា គេត្រូវដាក់វាជាក្រុមជាមួយគ្នា និងត្រូវផ្តល់ឈ្មោះជាលក្ខណៈទូទៅជាងមុនដើម្បីអាចតំណាងឲ្យធាតុផ្សំនៅក្នុងក្រាហ្វិកនោះ ដូចជា ភាពក្រីក្រ។ ក្នុងករណីទាំងពីរ ចម្លើយនីមួយៗដែលបានទទួល ត្រូវរាប់ថា "១" ដោយមិនគិតពីឈ្មោះនៃធាតុផ្សំរបស់វាឡើយ។

ក្រាហ្វិកដំបង ប្រើប្រាស់ 'អ័ក្ស X' (ខ្សែដេក) និង 'អ័ក្ស Y' (ខ្សែឈរ) នៃក្រាហ្វិកស្តង់ដារ។ 'X' បង្ហាញពីកម្រិតញឹកញាប់ ដូចជា ចំនួនលើកនៃចម្លើយដូចគ្នា ដែលបានទទួល និងនៅតាម 'អ័ក្ស Y' មានបង្ហាញពីចម្លើយ (សូមអានឧទាហរណ៍នៅក្នុងរូបទី ៤ និង ៥)។



រូបទី ៤. កម្រិតញឹកញាប់នៃចម្លើយរបស់អ្នកភូមិស្រយេ អំពីផលប៉ះពាល់នៃគ្រោះរាំងស្ងួតអូសបន្លាយរយៈពេលវែង (+៣ សប្តាហ៍)។




រូបទី ៥. កម្រិតញឹកញាប់នៃចម្លើយរបស់អ្នកភូមិស្រយេ អំពីផលប៉ះពាល់នៃគ្រោះរាំងស្ងួតអូសបន្លាយរយៈពេលវែង (+៣ សប្តាហ៍) ប្រសិនបើវាកើតឡើងជាច្រើនលើក

គោលការណ៍ណែនាំអំពីការប្រើប្រាស់ក្រាហ្វិកដំបងអំពីកម្រិតញឹកញាប់

- ✓ ត្រូវដាក់ឈ្មោះក្រាហ្វិករបស់អ្នកឲ្យបានច្បាស់លាស់ និងពេញលេញ និងមិនត្រូវដាក់ស្លាកឈ្មោះបន្ថែមនៅលើក្រាហ្វិកនេះឡើយ ក្នុងករណីមិនចាំបាច់។ រូបទី ៤ និង ៥ ជាឧទាហរណ៍ល្អមួយ។ អ្វីដែលបង្ហាញនៅទីនេះគឺភូមិ និងទិន្នន័យអំពីស្ថានភាពនៅក្នុងភូមិនេះ។
- ✓ ជាញឹកញាប់បំផុត ចំនួនចម្លើយដែលក្រុមមួយផ្តល់ឲ្យ គួរតែស្មើគ្នានៅក្នុងក្រាហ្វិកខុសៗគ្នាដែលតំណាងឲ្យសំណួរ VRA លើកលែងតែអ្នកចូលរួមខ្លះមិនផ្តល់ចម្លើយ។
- ✓ ប្រសិនបើអ្នកត្រូវរាយការណ៍អំពីចម្លើយប្រហែលគ្នារបស់"ភូមិ" និង/ឬ"ក្រុម"នៅក្នុងក្រាហ្វិកតែមួយជាមួយគ្នា ទិន្នន័យនោះត្រូវតែអំពីប្រធានបទដូចគ្នា និងឈ្មោះភូមិ ឬ ក្រុម ត្រូវតែសរសេរនៅក្នុងឈ្មោះក្រាហ្វិក។ ត្រូវជៀសវាងគណនាតួលេខមធ្យម ហើយចម្លើយនីមួយៗ ត្រូវរាប់ថា "១" ដោយមិនគិតអំពីចំនួនភូមិ ឬ ក្រុមឡើយ។
- ✓ ជាញឹកញាប់"កម្រិតញឹកញាប់នៃចម្លើយ"កាន់តែខ្ពស់បង្ហាញពីសារៈសំខាន់កាន់តែខ្លាំងនៃចម្លើយ និងជួនកាល ការចាត់ថ្នាក់ក៏មានសារៈសំខាន់ផងដែរ។

បង្កើត<u>ក្រាហ្វិកខ្សែនិន្នាការ</u> និង<u>ក្រាហ្វិកអំពីកម្រិតញឹកញាប់</u> នៃចម្លើយនៅក្នុង MICROSOFT EXCEL សូមអានកម្រិតញឹកញាប់នៃចម្លើយនៅក្នុងសេចក្តីណែនាំក្នុង Microsoft Excel ក្នុងឧបសម្ព័ន្ធ ២។

# គោលការណ៍គ្រឹះនៃការវិភាគ

តារាងវិភាគនិន្នាការជាប្រវត្តិសាស្ត្រ

- ✓ តើភាពងាយរងគ្រោះណាខ្លះដែលកំពុងកើនឡើង ឬ ថយចុះ ធៀបនឹងលក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស

- ✓ តើលក្ខខណ្ឌគ្រោះថ្នាក់ណាខ្លះនៃអាកាសធាតុ និងធាតុអាកាស ទំនងជាកើតឡើងកាន់តែញឹកញាប់ជាងមុន

- ✓ តើក្រុមប្រជាពលរដ្ឋណាខ្លះដែលកំពុងមានភាពគ្រោះកាន់តែខ្លាំងឡើង ដោយសារតែព្រឹត្តិការណ៍គ្រោះថ្នាក់ណាមួយជាក់លាក់នៃអាកាសធាតុ និងធាតុអាកាស

**!** ដូចមានបង្ហាញច្បាស់ក្នុងរូបទី៣ រយៈពេល ២០ ឆ្នាំកន្លងមកនេះ ភាពងាយរងគ្រោះរបស់ប្រជា-ពលរដ្ឋចំពោះការខូចខាតដំណាំ ដែលបង្កដោយទឹកជំនន់កាន់តែកើនឡើង។ អ្វីដែលមិនច្បាស់គឺថា លទ្ធផលនៃព្រឹត្តិការណ៍/លក្ខខណ្ឌដែលកើតឡើងកាន់តែញឹកញាប់ ឬមូលហេតុផ្សេងទៀត។ នេះជាមូលហេតុដែលការសិក្សាទិន្នន័យនៅក្នុងតារាងនេះមានសារៈសំខាន់ណាស់សម្រាប់បង្ហាញចេញជារូបភាពនេះឡើង ជាពិសេស យោបល់ពីអ្នកចូលរួមទាំងអស់។ ជាគោលការណ៍ទូទៅ ការដាក់ពិន្ទុ ១ មានន័យថា លក្ខខណ្ឌដែលបានបង្ហាញ មិនបានកើតឡើងឡើយ នៅក្នុងអំឡុងពេលនោះ ពិន្ទុខ្ពស់ជាងនេះ បង្ហាញអំពីទំហំនៃលក្ខខណ្ឌ និងកម្រិតធ្ងន់ធ្ងរនៃការប៉ះពាល់។

ទម្រង់H សំណួរ១

- ✓ តើការចិញ្ចឹមជីវិត ឬសុខុមាលភាពរបស់ប្រជាពលរដ្ឋបានរងការប៉ះពាល់កាន់តែធ្ងន់ធ្ងរ ដោយសារលក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាសដែរឬទេ តើអ្វីខ្លះដែលសំខាន់ជាងគេដែលត្រូវដោះស្រាយ និងតើក្រុមប្រជាពលរដ្ឋណាខ្លះដែលងាយរងគ្រោះបំផុត

- ✓ តើមានធនធាន និងយុទ្ធសាស្ត្រណាខ្លះដែលកំពុងប្រើប្រាស់ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃបញ្ហាណាមួយ (សំណួរ១) និងលទ្ធផលទាំងនេះ

- ✓ តើអ្នកចូលរួមនៅក្នុង VRA មានតម្រូវការសមត្ថភាពបន្ស៊ាំអ្វីខ្លះ (ភូមិ និង/ឬ ក្រុមជាក់លាក់) ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេចំពោះបញ្ហាណាមួយ (សំណួរ ១)
ដើម្បីវាយតម្លៃការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដែលកំពុងរងការប៉ះពាល់

! ដោយសារលក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស កិច្ចការនេះត្រូវចាប់ផ្តើមពីការកត់សំគាល់តារាងចម្លើយដែលទទួលបាននៅក្នុងជួរឈរ "ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិតនិងសុខុមាលភាពរបស់សហគមន៍" នៃទម្រង់ H សំណួរ ១។ ប្រសិនបើទិន្នន័យនេះទទួលបានតាមរយៈចម្លើយពីការពិភាក្សារួមគ្នាក្នុងក្រុមគោលដៅ ក្នុងករណីនោះ គេមិនអាចបង្កើតក្រាហ្វិកដំបងមួយ ដែលបង្ហាញពីសារៈសំខាន់ តាមរយៈកម្រិតញឹកញាប់នៃចម្លើយបានឡើយ។ ផ្ទុយទៅវិញ គេអាចបង្កើតតារាងងាយមួយដែលរាយការណ៍ពីលទ្ធផលទាំងនោះដោយផ្ទាល់។ ប្រសិនបើទិន្នន័យនោះទទួលបានតាមរយៈចម្លើយដាច់ដោយឡែកពីគ្នា គេអាចបង្កើតជាក្រាហ្វិកមួយបាន និងអាចបង្ហាញពីកម្រិតសំខាន់នៅក្នុងក្រាហ្វិកនោះ។

ដើម្បីវាយតម្លៃថាតើក្រុមណាខ្លះ ដូចជា បុរស ស្ត្រី មនុស្សចាស់។ល។ ងាយរងគ្រោះបំផុតចំពោះលក្ខខណ្ឌគ្រោះថ្នាក់/សំណួរណាមួយ គេអាចបង្កើតក្រាហ្វិកងាយមួយសម្រាប់ប្រៀបធៀប។ ប្រការនេះអាចធ្វើបានតែក្នុងករណីដែលអ្នកមានទិន្នន័យញែកដាច់គ្នាតាមក្រុមទាំងនោះប៉ុណ្ណោះ (សម្រាប់ការអង្កេតជាលក្ខណៈបុគ្គល) ឬ ក្នុងករណីដែល VRA បានធ្វើឡើងជាមួយក្រុមគោលដៅដែលបានកំណត់ជាក់លាក់ (សូមអានឧទាហរណ៍នៅក្នុងតារាងទី ២)។

តារាងទី ២. ទិន្នន័យញែកដាច់គ្នា និងភាពងាយរងគ្រោះជារួម ដែលឆ្លុះបញ្ចាំងអំពីភាពងាយរងគ្រោះរបស់ភូមិស្រយេ ចំពោះភាពអូសបន្លាយនៃគ្រោះរាំងស្ងួត (+៣ សប្តាហ៍)

| ក្រុមគោលដៅ | **សំណួរទី១** ពិន្ទុភាពងាយរងគ្រោះ | **សំណួរទី២** ពិន្ទុភាពងាយរងគ្រោះ | **សំណួរទី៣** ពិន្ទុភាពងាយរងគ្រោះ | ភាពងាយរងគ្រោះជាមធ្យម |
|---|---|---|---|---|
| ស្ត្រី | ៣.១ | ៣.៥ | ៤.០ | ៣.៥៣ |
| បុរស | ២.២ | ៣.០ | ៣.៥ | ២.៩០ |
| មនុស្សចាស់ | ៣.៤ | ៣.៥ | ៣.៥ | ៣.៤៦ |
| កុមារ | ៣.៣ | ៣.៦ | ៤.២ | ៣.៧០ |
| | | **ពិន្ទុអំពីភាពងាយរងគ្រោះជារួម (មធ្យម)** | | ៣.៣៩ |

*ចូរកត់សំគាល់ថា សំណួរទី៤ មិនពាក់ព័ន្ធឡើយ

ដូចមានបង្ហាញក្នុងតារាងនេះ ភូមិមួយមិនអាចផ្តល់ពិន្ទុអំពីភាពងាយរងគ្រោះបានឡើយ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើប្រៀបធៀបរវាងភូមិនានា ដូចជា នៅថ្នាក់ឃុំ ជាការល្អត្រូវប្រាកដថា ត្រូវរាយការណ៍អំពីស្ថានភាពនៃភាពខុសគ្នាសំខាន់ៗណាមួយក្រោមទម្រង់ជា ភាពងាយរងគ្រោះដែលកំពុងប្រៀបធៀបនោះ (សូមអានឧទាហរណ៍ក្នុងតារាង៣)។

តារាង ៣. ការប្រៀបធៀបរវាងភូមិនានានៅក្នុងឃុំ ដីវ៉ាយ ដែលទាក់ទងនឹងភាពងាយរងគ្រោះចំពោះគ្រោះរាំងស្ងួតអូសបន្លាយ (+៣ សប្តាហ៍)។

| ភូមិគោលដៅ | សំណួរទី១ ពិន្ទុភាពងាយរងគ្រោះ | សំណួរទី២ ពិន្ទុភាពងាយរងគ្រោះ | សំណួរទី៣ ពិន្ទុភាពងាយរងគ្រោះ | ភាពងាយរងគ្រោះជាមធ្យម |
|---|---|---|---|---|
| ស្រយេ | ៣.០ | ៣.១ | ៤.០ | ៣.៣៦ |
| មេមង់ | ១.២ | ២.០ | ៣.៥ | ២.៣៣ |
| អ៊ីណាង | ២.៤ | ៣.៥ | ២.៥ | ២.៨០ |
| ពូជ្រៃ | ១.៣ | ២.៦ | ២.២ | ២.០៣ |
| | | ពិន្ទុអំពីភាពងាយរងគ្រោះជារួម (មធ្យម) | | ២.៦៣ |

*ចូរកត់សំគាល់ថា សំណួរទី៤ មិនពាក់ព័ន្ធឡើយ

!

ធនធាន និងយុទ្ធសាស្ត្រដែលប្រើប្រាស់ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃបញ្ហាណាមួយ (សំណួរ ១) និងលទ្ធផលនៃយុទ្ធសាស្ត្រទាំងនេះ អាចឃើញនៅក្នុងទម្រង់ H សំណួរទី១ ក្នុងជួរឈរដែលសរសេរថា "ធនធាន និងយុទ្ធសាស្ត្រប្រើប្រាស់ដែលកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍"។ ប្រការសំខាន់គឺត្រូវគូសបញ្ជាក់យុទ្ធសាស្ត្រទាំងនោះដាច់ពីគ្នា ដែលមានឥទ្ធិពលមកលើលទ្ធផល ពោលគឺកាត់បន្ថយផលប៉ះពាល់នៃបញ្ហាដែលបានចែងក្នុងសំណួរ១ និងយុទ្ធសាស្ត្រដែលមិនបានកាត់បន្ថយ ឬ ធ្វើឲ្យស្ថានភាពកាន់តែធ្ងន់ធ្ងរនូវផលប៉ះពាល់ និងមូលហេតុ។ ប្រសិនបើទិន្នន័យប្រមូលបានពីក្រុមដាច់គ្នា ដូចជា បុរស ស្ត្រី មនុស្សចាស់ គេក៏អាចប្រៀបធៀបធនធាន និងយុទ្ធសាស្ត្រផងដែរ។ ភាពខុសគ្នា ដែលអាចកត់សំគាល់បាន បង្ហាញពីភាពខុសគ្នានៃលទ្ធភាពទទួលបានធនធាន ចំណេះដឹង ជំនាញ រវាងក្រុមនានា។ ប្រការនេះអាចឆ្លុះបញ្ចាំងតាមរយៈភាពខុសគ្នារវាងពិន្ទុអំពីភាពងាយរងគ្រោះផងដែរ។
ប្រសិនបើមានព័ត៌មានអំពីកម្រិតញឹកញាប់ដែរនោះ អំពីធនធាន និងយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយផលប៉ះពាល់នៃបញ្ហាណាមួយ គេអាចបញ្ចូលព័ត៌មាននេះទៅក្នុងក្រាហ្វិកមួយ និងពិភាក្សា (ចំពោះព័ត៌មានបន្ថែម សូមអានទម្រង់ H សំណួរ២)

!

ប្រការសំខាន់បំផុតចំពោះការវិភាគទម្រង់ H សំណួរ ១ គឺតម្រូវការសមត្ថភាពបន្សាំ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ។ ចូរពិនិត្យទិន្នន័យដែលផ្តល់ឲ្យនៅក្រោមជួរឈរ "ធនធាននិងយុទ្ធសាស្ត្រដែលប្រើប្រាស់ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាល-ភាពរបស់សហគមន៍"។ ចូរវាយតម្លៃអំពីធនធាន និងយុទ្ធសាស្ត្រអ្វីខ្លះដែលត្រូវពង្រឹង និង/ឬជៀសវាង ដើម្បីធានាឲ្យមានលទ្ធផលវិជ្ជមានកាន់តែច្រើនជាងមុន។ ចូរបន្តដោយពិនិត្យចម្លើយក្នុងជួរឈរកណ្តាលនៅខាងក្រោម "តើគួរធ្វើអ្វីខ្លះ ដើម្បីកែលម្អពិន្ទុភាពងាយរងគ្រោះ" និងវាយតម្លៃ ថាតើចម្លើយនេះជួយដោះស្រាយការពង្រឹងធនធាន និងយុទ្ធសាស្ត្របច្ចុប្បន្ន ដើម្បីបញ្ចុះផលប៉ះពាល់ឬទេ។ បើពុំនោះទេ គួរកត់សំគាល់ចំណុចនេះនៅក្នុងការវិភាគ និងចាត់ទុកថាជាសកម្ម-ភាពគន្លឹះដែលត្រូវអនុវត្ត។

គួរពិនិត្យ និងរាយការណ៍អំពីទិន្នន័យជួរឈរកណ្ដាល ប៉ុន្តែគួរតែធ្វើទៅតាមអាទិភាពដែលអ្នកចូលរួមបានកំណត់ ពោលគឺ អ្វីដែលផ្ដល់នៅក្នុងទម្រង់ H សំណួរ ៤។ គួរធ្វើសេចក្ដីរាយការណ៍អំពីអាទិភាពនានាផងដែរក្នុងនាមជាសកម្មភាពច្បាស់លាស់។ ប្រសិនបើទិន្នន័យប្រមូលបានពីក្រុមដាច់ពីគ្នា ដូចជា បុរស ស្ត្រី មនុស្សចាស់ គេគួរតែធ្វើការប្រៀបធៀប"សកម្មភាពអាទិភាព"។

## ទម្រង់ H សំណួរទី ២

✓ វាយតម្លៃផលប៉ះពាល់ និងភាពងាយរងគ្រោះ ប្រសិនបើលក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស ដូចក្នុងសំណួរ ១ កើតឡើងពីរដងញឹកញាប់ជាងមុន ឬ ក្នុងកម្លាំងពីរដងខ្លាំងជាង។

ទិន្នន័យពីទម្រង់ H សំណួរទី ១ ត្រូវបានប្រើប្រាស់ ជាការប្រៀបធៀបជាមួយទិន្នន័យដែលផ្ដល់ក្នុងសំណួរទី ២ ដែលទាក់ទងនឹងផលប៉ះពាល់ ពិន្ទុអំពីភាពងាយរងគ្រោះ និងយោបល់នានា ដើម្បីកាត់បន្ថយផលប៉ះពាល់ តាមរយៈការកសាងសមត្ថភាពបន្សុំ។ ដើម្បីធ្វើការវិភាគបែបប្រៀបធៀប៖

- សំណួរ ១ និង ២ ត្រូវតែមានការទាក់ទងដោយផ្ទាល់ជាមួយគ្នាទីវិញទៅមក
- ទិន្នន័យប្រៀបធៀប ត្រូវតែទាក់ទងរវាងគ្នា ដូចជា ចម្លើយរបស់ក្រុមស្ត្រី បុរស មនុស្សចាស់
- ពិន្ទុភាពងាយរងគ្រោះជារួមអាចប្រៀបធៀបបានដោយផ្ទាល់

**!**

ការវាយតម្លៃនេះគួរតែគូសបញ្ជាក់ពីភាពខុសគ្នា នៃផលប៉ះពាល់ នៅក្នុងក្រុមនីមួយៗ (ចម្លើយតបនឹងផលប៉ះពាល់ក្នុង សំណួរទី១ ធៀបនឹងចម្លើយតបនឹងផលប៉ះពាល់ក្នុង សំណួរទី២), និងប្រសិនបើអាចធ្វើបាន គួរប្រៀបធៀបរវាងក្រុមងាយរងគ្រោះទាំងអស់ ដូចជា រវាងក្រុមបុរស និងស្ត្រី។ លើសពីនេះ ពិន្ទុអំពីភាពងាយរងគ្រោះក៏អាចប្រៀបធៀបគ្នាបានផងដែរ។ តាមរយៈដំណើរការដូចគ្នានេះ ចូរកត់សំគាល់អំពីភាពខុសគ្នានានា នៃចម្លើយដែលផ្ដល់ ដើម្បីកាត់បន្ថយពិន្ទុភាពងាយរងគ្រោះ/ កាត់បន្ថយផលប៉ះពាល់នៃលក្ខខណ្ឌគ្រោះថ្នាក់។ ជារួមការប្រៀបធៀប គឺត្រូវផ្ដល់រូបភាពមួយអំពីហានិភ័យទៅអនាគត ប្រសិនបើគ្មានការកសាងសមត្ថភាពបន្សុំ។

ទម្រង់ H សំណួរទី ៣

- ✓ គូសបញ្ជាក់អំពីឧបសគ្គនានាដែលសហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀតប្រឈមនៅក្នុងការប៉ុនប៉ងរបស់ពួកគេ ដើម្បីព្យាករ ឬ បន្សាំនឹងផលប៉ះពាល់ពីលក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស ដូចលើកឡើងក្នុងសំណួរ ១

- ✓ បង្ហាញភាពខុសគ្នានៃឧបសគ្គ និងភាពងាយរងគ្រោះ រវាងក្រុមគោលដៅខុសៗគ្នា ដូចជា រវាងក្រុមបុរស ស្ត្រី និងក្រុមមនុស្សចាស់

- ✓ វាយតម្លៃ ថាតើឧបសគ្គដែលបានគូសបញ្ជាក់ ត្រូវបានពិចារណានៅក្នុងការឆ្លើយតបនានានិង/ឬក្នុងសកម្មភាពដែលស្នើឡើងនៅក្នុងសំណួរ ១ ឬទេ ដើម្បីកាត់បន្ថយពិន្ទុភាពងាយរងគ្រោះ/ផលប៉ះពាល់នៃលក្ខខណ្ឌគ្រោះថ្នាក់

! ដើម្បីគូសបញ្ជាក់ពីឧបសគ្គ ជាការប្រសើរគឺត្រូវចាត់បញ្ចូលចម្លើយប្រហែលគ្នាទៅក្នុងក្រុមជាមួយគ្នា និងរៀបចំប្រយោគច្បាស់លាស់សម្រាប់ក្រុមនីមួយៗ។ ការវិភាគងាយបំផុតដែលត្រូវធ្វើគឺ ត្រូវកត់សំគាល់ពីអ្វីដែលត្រូវការ (សំណួរ ៣ ចម្លើយដែលផ្តល់នៅក្នុងជួរឈរកណ្តាល) ធៀបនឹងធនធាននិងសមត្ថភាពបន្សាំអ្វីខ្លះដែលមាន (សំណួរ ១ ចម្លើយដែលផ្តល់នៅក្នុងជួរឈរ "ធនធាននិងយុទ្ធសាស្ត្រដែលប្រើប្រាស់ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍")។ គេអាចបង្កើតតារាងមួយ ដើម្បីជួយនៅក្នុងការវិភាគនេះ និង/ឬ រាយការណ៍អំពីទិន្នន័យនេះ (សូមអានឧទាហរណ៍ នៅក្នុងតារាង ៤)។ គេអាចធ្វើការវិភាគមួយរវាងក្រុមខុសៗគ្នា នៅថ្នាក់ភូមិ និង/ឬ ថ្នាក់ឃុំ និងនៅថ្នាក់លើៗបន្ថែមទៀត។

តារាង ៤. ការប្រៀបធៀបឧបសគ្គជារួម ធៀបនឹងសមត្ថភាពបន្សាំ ដើម្បីដោះស្រាយគ្រោះរាំងស្ងួតអូសបន្លាយរយៈពេលវែង(+៣ សប្តាហ៍) សម្រាប់ស្ត្រី នៅក្នុងភូមិស្រយេ ឃុំដីវ៉ាយ

| ឧបសគ្គ | សមត្ថភាពបន្សាំ |
|---|---|
| ▪ មានជម្រើសតិចតួច សម្រាប់បង្កើតប្រភពផ្សេងនៃប្រាក់ចំណូល ដោយសារតែខ្វះប្រាក់<br>▪ ខ្វះលទ្ធភាពទទួលបានព័ត៌មាន និងការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាកសិកម្មឆ្លាត<br>▪ ខ្វះលទ្ធភាពទទួលបានមីក្រូឥណទានដែលមានការប្រាក់ទាប<br>▪ ខ្វះលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធទឹកសម្រាប់ធ្វើស្រែ | ▪ ដីកសិកម្មដែលមានជីជាតិ<br>▪ អង្គការសហគមន៍មូលដ្ឋានបានបង្កើតក្រុមជួយខ្លួនឯង<br>▪ ប្រភពធនធានទឹកដែលអាចទុកចិត្តបានស្ថិតនៅចម្ងាយ ៣គ.ម |

! តាមរយៈការប្រៀបធៀប"ឧបសគ្គ" ធៀបនឹង សមត្ថភាពបន្សាំបច្ចុប្បន្នដែលមានក្នុងតារាង គេអាចបង្កើតតារាងពិស្តារមួយអំពីតម្រូវការសមត្ថភាពបន្សាំ។

ដើម្បីបង្ហាញភាពខុសគ្នានៃឧបសគ្គក្នុងចំណោមក្រុមខុសៗគ្នា គេអាចបង្កើតតារាងងាយមួយ និងរាយការណ៍អំពីតារាងនោះ។ គួរកត់សំគាល់ថា លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស ដូចដែលបានលើកឡើង គួរតែទាក់ទងដោយផ្ទាល់ជាមួយគ្នា នៅរវាងក្រុមនានា (សូមអានឧទាហរណ៍ក្នុងតារាងទី ៥)។

តារាងទី ៥ ការប្រៀបធៀបឧបសគ្គជារួម រវាងក្រុមនានា ដើម្បីដោះស្រាយផលប៉ះពាល់នៃគ្រោះរាំងស្ងួតអូសបន្លាយរយៈពេលវែង (+៣ សប្តាហ៍) សម្រាប់ភូមិស្រយេ ឃុំជីវ៉ាយ

| **ឧបសគ្គ ក្រុមស្ត្រី** (ពិន្ទុភាពងាយរងគ្រោះ ៤.១) | **ឧបសគ្គ ក្រុមបុរស** (ពិន្ទុភាពងាយរងគ្រោះ ៣.៥) | **ឧបសគ្គ ក្រុមមនុស្សចាស់** (ពិន្ទុភាពងាយរងគ្រោះ ៤.៥) |
|---|---|---|
| ▪ មានជម្រើសមួយចំនួនតូចសម្រាប់បង្កើតប្រភពផ្សេងនៃប្រាក់ចំណូល ដោយសារខ្វះប្រាក់<br>▪ ខ្វះលទ្ធភាពទទួលបានព័ត៌មាននិងការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាកសិកម្មឆ្លាត<br>▪ ខ្វះលទ្ធភាពទទួលបានមីក្រូឥណទានដែលមានការប្រាក់ទាប<br>▪ ខ្វះលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធទឹកសម្រាប់ធ្វើស្រែ | ▪ មានជម្រើសមួយចំនួនតូចសម្រាប់បង្កើតប្រភពផ្សេងនៃប្រាក់ចំណូល ដោយសារខ្វះប្រាក់<br>▪ ខ្វះលទ្ធភាពទទួលបានព័ត៌មាននិងការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាកសិកម្មឆ្លាត<br>▪ ខ្វះលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធទឹកសម្រាប់ធ្វើស្រែ | ▪ មិនអាចបង្កើតប្រភពផ្សេងនៃប្រាក់ចំណូលឡើយ ដោយសារបញ្ហារូបវន្ត និង/ឬ ជម្រើសសមស្រប<br>▪ ខ្វះលទ្ធភាពទទួលបានមីក្រូឥណទានដែលមានការប្រាក់ទាប |

ប្រសិនបើមានព័ត៌មានអំពីកម្រិតញឹកញាប់នៃឧបសគ្គ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃបញ្ហានោះ ព័ត៌មានផ្តល់ក្នុងឧទាហរណ៍ តារាងទី ៥ គេអាចចាត់បញ្ចូលជាក្រុម និងដាក់ឈ្មោះខ្លីមួយ បន្ទាប់មកបញ្ចូលទៅក្នុងក្រាហ្វិកដំបង (សូមអានឧទាហរណ៍ក្នុងរូបទី ៦)។




រូបទី ៦ ការប្រៀបធៀបឧបសគ្គរវាងក្រុមនានា ក្នុងការដោះស្រាយផលប៉ះពាល់នៃគ្រោះរាំងស្ងួតអូសបន្លាយរយៈពេលវែង (+៣ សប្តាហ៍) សម្រាប់ភូមិស្រយេ ឃុំជីរ៉ាយ

**!** ស្រដៀងគ្នានឹងការវិភាគទម្រង់ H សំណួរ ១ ផងដែរ ចូរវាយតម្លៃថាតើសំណួរទី៣ អំពីការឆ្លើយតបនឹងឧបសគ្គនានា ដែលត្រូវបានដោះស្រាយ នៅក្នុងការឆ្លើយតបដូចមានចុះក្នុងតារាងនៅក្រោម "តើគួរធ្វើអ្វីខ្លះ ដើម្បីកែលម្អពិន្ទុភាពងាយរងគ្រោះ"ឬទេ។ បើគ្មានទេ គួរកត់សំគាល់ចំណុចនេះនៅក្នុងការវិភាគនេះ និងត្រូវចាត់ទុកជាសកម្មភាពគន្លឹះដែលត្រូវអនុវត្ត (សូមអានរូបខាង



ទម្រង់ H សំណួរទី ៤

- ✓ ផ្តល់តារាងមួយអំពីសកម្មភាពកាត់បន្ថយភាពងាយរងគ្រោះ ដែលបានកំណត់ឃើញនៅក្នុងទម្រង់ H សំណួរទី ១
- ✓ ចូរផ្តល់ពិន្ទុ"កម្រិតទំនុកចិត្ត" ដែលទាក់ទងនឹងការកាត់បន្ថយភាពងាយរងគ្រោះ ប្រសិនបើមានការអនុវត្តសកម្មភាពអាទិភាព

ការវិភាគទម្រង់H សំណួរទី៤ គ្រាន់តែជាការរៀបចំរបាយការណ៍ទិន្នន័យតាមទម្រង់មួយប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំរបាយការណ៍ ក៏រួមបញ្ចូល សេចក្តីពិស្តារអំពីវិធានការកសាងសមត្ថភាពអ្វីខ្លះដែលចាត់ជាអាទិភាពផងដែរ ធៀបនឹងតម្រូវការ ដូចដែលក្រុមនានាចុះក្នុងតារាងដែលនៅពុំទាន់បានចាត់ជាអាទិភាព។

ការប្រៀបធៀបមួយអំពីពិន្ទុ "កម្រិតទំនុកចិត្ត" ក៏អាចធ្វើបានផងដែរ។ ហេតុផលនៃភាពខុសគ្នាអាចជាប្រភពទិន្នន័យខុសៗគ្នា ដូចជា ការវិភាគទម្រង់ H សំណួរ ១ និង ៣។

# ជំពូក ៥
# សរសេររបាយការណ៍ VRA

## សេចក្តីពន្យល់សង្ខេប

ខាងក្រោមនេះជាគំរូណែនាំចំនួនពីរសម្រាប់សរសេររបាយការណ៍របកគំហើញខ្លីអំពី VRA និងរបាយការណ៍របកគំហើញប្រៀបធៀប VRA ដែលប្រៀបធៀបទិន្នន័យពីការអនុវត្ត VRA ដែលបានធ្វើឡើងនៅក្នុងបរិបទដូចគ្នា ប៉ុន្តែក្នុងពេលខុសគ្នា ដូចជា ខុសពេលគ្នា ៣ឆ្នាំ។ មានផ្នែកសំខាន់ៗចំនួនប្រាំ (៥) សម្រាប់របាយការណ៍ VRA នីមួយៗ៖ សេចក្តីផ្តើម វិធីសាស្ត្រ របកគំហើញ VRA សំណើសកម្មភាពបន្សុំ និងមេរៀនដែលទទួលបាន ព្រមទាំងសេចក្តីសន្និដ្ឋាន។ គំរូរបាយការណ៍នេះបង្ហាញព័ត៌មានក្នុងកម្រិតអប្បបរមាដែលចាំបាច់សម្រាប់បំពេញរបាយការណ៍ VRA។ នៅក្នុងផ្នែកនីមួយៗ មានផ្តល់សេចក្តីណែនាំ ដូចជា ប្រវែងសម្រាប់ជំពូក និង/ឬ ជំពូករងនីមួយៗ។ ក្រៅពីនេះមានការផ្តល់សេចក្តីណែនាំជា"ចំណុចៗ"ផងដែរ។ សេចក្តីណែនាំទាំងនេះ មានផ្តល់ទៅតាមលំដាប់លំដោយនៃព័ត៌មានដែលគួរតែបញ្ចូលនៅក្នុងរបាយការណ៍។ ការធ្វើបែបនេះដើម្បីឲ្យប្រាកដថា របាយការណ៍នានាត្រូវបានសរសេរសង្ខេប មានខ្លឹមសារពេញលេញ និងមានប្រវែងងាយស្រួលសម្រាប់អ្នកអាន។

## គោលបំណងនៃជំពូកនេះ៖

- ✓ ណែនាំដល់អ្នកអនុវត្ត VRA នៅក្នុងការសរសេររបកគំហើញ VRA តាមទម្រង់សមស្រប និងខ្លី និងសម្រាប់របាយការណ៍របកគំហើញប្រៀបធៀប VRA
- ✓ ជម្រាបជូនអ្នកសរសេររបាយការណ៍អំពីលក្ខខណ្ឌអប្បបរមាសម្រាប់ការសរសេររបាយការណ៍ VRA

## កំណត់សំគាល់សំខាន់ៗ៖

អាស្រ័យលើអ្នកដែលត្រូវទទួលរបាយការណ៍នោះ ឬ តើនឹងប្រើប្រាស់របាយកាណ៍នោះបែបណា គេអាចត្រូវការព័ត៌មាន ឬ ផ្នែកបន្ថែមផងដែរ។

## គំរូរបាយការណ៍អំពីរបកគំហើញនៃ VRA

| | |
|---|---|
| ឈ្មោះគម្រោង | |
| ទីតាំងគម្រោង | |
| អ្នកស្នើគម្រោង | |
| តំណាងដែលមានសិទ្ធិ | |
| ស្ថាប័នសហប្រតិបត្តិការ | |
| កាលបរិច្ឆេទវាយតម្លៃ VRA | |

| មាតិកាក្នុងផ្នែកនេះ | ត្រូវការតារាង និងរូប |
|---|---|
| ១.០ សេចក្តីផ្តើម (២-៣ វាក្យខណ្ឌ) | |
| ក. ទិដ្ឋភាពរួមនៃអង្គការរបស់អ្នក ដែលរួមទាំង ឈ្មោះ បេសកកម្មចំបងៗ និង ប្រវត្តិខ្លីៗអំពីបទពិសោធន៍របស់អង្គការអ្នកអំពីការបន្សាំរបស់សហគមន៍<br>ខ. ប្រសិនបើមានស្ថាប័នផ្តល់ជំនួយគាំទ្រការធ្វើ VRA ត្រូវចែងបញ្ជាក់បន្ត ដោយមូលហេតុនៃការជ្រើសរើសស្ថាប័នអនុវត្ត VRA ក្នុងការអនុវត្ត VRA នេះ តើនឹងប្រើប្រាស់ព័ត៌មាននេះដើម្បីធ្វើអ្វី។ | |
| ២.០ វិធីសាស្ត្រ (១ ទំព័រ) | |
| គ. បញ្ជាក់ពីពេលវេលាដែលបានធ្វើ VRA និងទីកន្លែង (ភូមិ ឃុំ ស្រុក ខេត្ត ប្រទេស) និងចំនួនអ្នកចូលរួមពាក់ព័ន្ធ។<br>ឃ. រៀបរាប់អំពីដំណើរការដែលបានធ្វើ ក្នុងការជ្រើសរើសកន្លែង/ភូមិគោលដៅ និងការងាររៀបចំណាមួយ ដូចជា ព័ត៌មានសាវតាដែលទទួលបាន ការពិគ្រោះយោបល់ រហូតដល់ជំហាននានានៅតាមទីតាំង ដើម្បីចូលរួមក្នុងដំណើរការVRA នេះប្រកបដោយខ្លឹមសារ។ | |
| មាតិកាក្នុងផ្នែកនេះ | ត្រូវការតារាងនិងរូប |
| ២.០ វិធីសាស្ត្រ *(ត)* | |
| ង. សូមបញ្ជាក់ ប្រសិនបើ VRA ត្រូវបានអនុវត្តតាមរយៈវិធីអង្កេតជាលក្ខណៈ | ទិន្នន័យចាំបាច់ |

| | |
|---|---|
| បុគ្គល ឬ/និង តាមរយៈវិធីពិភាក្សាក្រុមគោលដៅ។ ចំពោះការអង្កេតជាលក្ខណៈបុគ្គល ចូរបញ្ជាក់អំពីជំពូក (ស្ថានភាព) នៃអ្នកចូលរួម (សង្ខេបខ្លីៗ) និងចំនួនអ្នកឆ្លើយតាមជំពូកនីមួយៗ។ | សម្រាប់ 'ង' អាចដាក់ទៅក្នុងតារាង |
| ច. ចំពោះវិធីពិភាក្សាក្រុមគោលដៅ ចូរផ្តល់សេចក្តីសង្ខេបអំពីក្រុមនោះ។ ឧទាហរណ៍ ចំនួនអ្នកឆ្លើយជាបុរស អាយុ ២០-៤០ឆ្នាំ ចំនួនស្ត្រីជាអ្នកឆ្លើយ អាយុ ៣៥-៤៥ឆ្នាំ សមាគមកសិករ រហូតដល់តំណាងពីរដ្ឋាភិបាលដែលរួមទាំងសមាជិកក្រុមប្រឹក្សាឃុំ និងស្រុក។ល។ ចូរសរសេរខ្លីៗប៉ុណ្ណោះ។ ត្រូវរួមបញ្ចូល ចំនួនសរុបនៃអ្នកចូលរួមក្នុងក្រុមនីមួយៗ។ | |
| ៣.០ របកគំហើញ VRA (៣-៥ ទំព័រ) *(ដែលរាយការណ៍ដោយក្រុមគោលដៅ និង/ឬ ជំពូកនៃអ្នកចូលរួមសម្រាប់ការអង្កេតនីមួយៗ)* | |
| **ឆ.** (៣.១) និន្នាការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់៖ ដោយប្រើប្រាស់លទ្ធផលពីការវិភាគនិន្នាការប្រវត្តិនៃការប្រែប្រួលអាកាសធាតុ ចូរសរសេរទិដ្ឋភាពរួមខ្លីៗអំពីព្រឹត្តិការណ៍គ្រោះថ្នាក់សំខាន់ៗដែលទាក់ទងនឹងអាកាសធាតុ និងធាតុអាកាស។ ចុះកាលបរិច្ឆេទ ប្រសិនបើអាចធ្វើបាន និងសេចក្តីពិស្តារអំពីផលប៉ះពាល់នៃព្រឹត្តិការណ៍ទាំងនេះ។ ប្រើប្រាស់លទ្ធផលពីការវិភាគនិន្នាការ ដើម្បីអធិប្បាយអំពីនិន្នាការនៃភាពងាយរងគ្រោះចំពោះលក្ខខណ្ឌគ្រោះថ្នាក់ខុសៗគ្នានៃអាកាសធាតុ និងធាតុអាកាស ដោយមានការដាក់ពិន្ទុភាពងាយរងគ្រោះ។<br>(៣.១.១) រៀបរាប់បន្តដោយការផ្តល់ព័ត៌មានពិស្តារបន្ថែមអំពីព្រឹត្តិការណ៍ប្រែប្រួលអាកាសធាតុនានា ដោយយកចេញសំណួរទី ១ ក្នុងទម្រង់ H ដែលទាក់ទងនឹងផលប៉ះពាល់អវិជ្ជមាននៃព្រឹត្តិការណ៍នានាប៉ុណ្ណោះ។ បន្ទាប់មក ត្រូវរៀបរាប់បន្តដោយយកទិន្នន័យពីការយល់ឃើញឆ្លើយតបនឹងសំណួរទី ២ ដែលទាក់ទងនឹងផលប៉ះពាល់អវិជ្ជមានប៉ុណ្ណោះ។ ចូរផ្តល់ពិន្ទុអំពីភាពងាយរងគ្រោះ។ | រូបនិងតារាង៖លទ្ធផលនៃការវិភាគនិន្នាការ (ដាក់តារាងជាឧបសម្ព័ន្ធ)<br><br>រូប៖ និន្នាការភាពងាយរងគ្រោះ នៃការប្រែប្រួលអាកាសធាតុ (ពិន្ទុភាពងាយរងគ្រោះ ធៀបនឹងលក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស។ |

| មាតិកាក្នុងផ្នែកនេះ | ត្រូវការតារាង និងរូប |
|---|---|
| ៣.០ របកគំហើញ VRA *(បន្ត)* | |
| **ជ.** (៣.២) សមត្ថភាពដោះស្រាយ និងបន្សាំ (*ដែលបានធ្វើតាមលក្ខខណ្ឌគ្រោះថ្នាក់ ដូចមានគូសបញ្ជាក់ក្នុងទម្រង់ H សំណួរ សំណួរទី១: ធនធាន និងយុទ្ធសាស្ត្រដែលបានប្រើប្រាស់ ដែលកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍*)<br>▪ រៀបរាប់សមត្ថភាពដោះស្រាយនិងបន្សាំដែលមានលក្ខណៈជាក់លាក់ទៅនឹងស្ថានភាពគ្រោះថ្នាក់ដែលបានកើតមានឡើង ឧទាហរណ៍ដូចជា ជាតុសំខាន់ៗទាំងប្រាំសម្រាប់ការចិញ្ចឹមជីវិត(មនុស្ស ហិរញ្ញវត្ថុ រូបវន្ត សង្គម និងធម្មជាតិ) តាមការចាំបាច់។ ចូររួមបញ្ចូលទាំងធនធាន និងយុទ្ធសាស្ត្រដែលបានកៀរគរដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងលទ្ធផលនៃសកម្មភាពដែលបានផ្តល់។ និង/ ឬ...<br>▪ រៀបរាប់អំពីសមត្ថភាពដោះស្រាយនិងបន្សាំ ទៅតាមលក្ខខណ្ឌគ្រោះថ្នាក់ជាក់លាក់ដែលបានកំណត់ទៅតាមប្រភេទ ដូចជា ជាតុសំខាន់ៗនៃសុខុមាលភាព(សន្តិសុខ សម្ភារៈចាំបាច់សម្រាប់ជីវិត សុខភាព និងទំនាក់ទំនងសង្គម) តាមការចាំបាច់។ ចូររួមបញ្ចូលធនធាន និងយុទ្ធសាស្ត្រដែលបានកៀរគរសម្រាប់កាត់បន្ថយលក្ខខណ្ឌគ្រោះថ្នាក់មកលើសុខុមាលភាព(តាមជំពូក) និងលទ្ធផលនៃសកម្មភាពដែលបានផ្តល់។ | ជម្រើស៖ ការចុះជាតារាងអាចធ្វើបានជាមួយសេចក្តីពន្យល់បន្ថែមជារួមដែលគូសបញ្ជាក់អំពីចំណុចសំខាន់ៗ |

| យុទ្ធសាស្ត្រដោះស្រាយ | យុទ្ធសាស្ត្របន្សាំ |
|---|---|
| ▪ រយៈពេលខ្លី និងបន្ទាន់<br>▪ ផ្តោតលើការរក្សាជីវិតឲ្យនៅគង់វង់<br>▪ មិនមែនជាដំណើរការជាប់លាប់<br>▪ កើតឡើងដោយសារវិបត្តិ ជាប្រតិកម្មតប<br>▪ ច្រើនតែធ្វើឲ្យរេចរឹលមូលដ្ឋានធនធាន<br>▪ កើតឡើងដោយសារខ្វះជម្រើសជំនួស | ▪ ផ្តោតលើសន្តិសុខនៃការចិញ្ចឹមជីវិតរយៈពេលវែង<br>▪ ជាដំណើរការជាប់ជាបន្ត<br>▪ លទ្ធផលត្រូវបានរក្សាឲ្យមាននិរន្តរភាព<br>▪ ប្រើប្រាស់ធនធានដោយប្រសិទ្ធភាព និងនិរន្តរភាព<br>▪ ពាក់ព័ន្ធនឹងការរៀបចំផែនការ<br>▪ រួមបញ្ចូលយុទ្ធសាស្ត្រ និងចំណេះដឹងថ្មី និងចាស់<br>▪ ផ្តោតលើការស្វែងរកជម្រើសនានា |

| មាតិកាក្នុងផ្នែកនេះ | ត្រូវការតារាងនិងរូប |
|---|---|
| ៣.០ របកគំហើញ VRA *(ត)* | |
| ឈ. (៣.៣)ឧបសគ្គចំពោះការបន្សាំ *(ផ្នែកនេះបានផ្អែកលើព័ត៌មានក្នុងទម្រង់ H សំណួរទី៣។ ដូចគ្នានេះដែរ ជាការល្អ ត្រូវរៀបចំរបាយការណ៍ដូចដែលបានធ្វើនៅក្នុង ៣.២ អំពីរបាយការណ៍របកគំហើញ VRA។ ចូរផ្តល់ពិន្ទុភាពងាយរងគ្រោះ ជាមួយសេចក្តីពន្យល់រួមអំពីបរិបទនៃភាពងាយរងគ្រោះ។*<br><br>*(ជម្រើស៖ ប្រសិនបើ NGO ដែលអនុវត្ត VRA ចង់ចូលរួមនៅក្នុងគណៈកម្មការអភិវឌ្ឍន៍ឃុំ ជាការឆ្លើយតបនឹងសកម្មភាពកាត់បន្ថយភាពងាយរងគ្រោះ ជាការល្អ គឺត្រូវចាត់បញ្ចូលការឆ្លើយតបទៅតាមជំពូក ឲ្យស្របជាមួយវិស័យនៃការយកចិត្តទុកដាក់ចំបងៗនៃផែនការអភិវឌ្ឍន៍ឃុំដែលពាក់ព័ន្ធ។)* | |
| ញ. (៣.៤) ការកាត់បន្ថយភាពងាយរងគ្រោះ *(ដោយផ្អែកលើទម្រង់ H សំណួរទី១ វិធានការឆ្លើយតប/សកម្មភាពកាត់បន្ថយភាពងាយរងគ្រោះ និងការចាត់ថ្នាក់វិធានការឆ្លើយតបនានាដែលបានពីទម្រង់H សំណួរទី៤)*<br>▪ ស្រង់សកម្មភាពអាទិភាពដោយដាក់តាមលំដាប់ (ចាប់ផ្តើមពីអាទិភាពខ្ពស់ បន្តមកអាទិភាពទាប)។ ចូរចាត់វិធានការឆ្លើយតបទៅផ្នែកនីមួយៗ ស្របតាមធាតុទាំងប្រាំសម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិត និងធាតុផ្សំនៃសុខុមាលភាពរបស់សហគមន៍ ទៅតាមករណីសមស្របពេលគឺ មិនមែនគ្រប់ជំពូកទាំងអស់សុទ្ធតែមានវិធាន-ការឆ្លើយតបនោះឡើយ<br>▪ ចូរផ្តល់សេចក្តីពន្យល់ខ្លី និងហេតុផលជារួមសម្រាប់សកម្មភាពដែលចែងនៅក្នុងវិធានការឆ្លើយតបតាមជំពូកនីមួយៗ<br>▪ ចូរផ្តល់ពិន្ទុក្នុងទម្រង់ H សំណួរ សំណួរទី៤ និងផ្តល់ហេតុផលខ្លីនៅក្នុង បរិបទដែលថាតើអ្នកចូលរួមមានទំនុកចិត្តប៉ុណ្ណាថាសកម្មភាពដែលមាននៅក្នុងតារាង នឹងកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋចំពោះការប្រែប្រួលអាកាសធាតុ។ | ជម្រើស៖ សកម្មភាពជាអាទិភាពអាចចុះនៅក្នុងតារាងមួយ |

| មាតិកាក្នុងផ្នែកនេះ | ត្រូវការតារាងនិងរូប |
|---|---|
| ៤.០ សំណើសកម្មភាពបន្សាំ ( ១-២ ទំព័រ ) | |
| ក្រោយពីបានវិភាគព្រឹត្តិការណ៍អាកាសធាតុចំបងៗ និងផលប៉ះពាល់សំខាន់ៗមកលើការចិញ្ចឹមជីវិតនិងសុខុមាលភាពរបស់សហគមន៍ ធនធាន និងយុទ្ធ-សាស្ត្រដែលពួកគេប្រើប្រាស់ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ និងឧបសគ្គចំពោះការកាត់បន្ថយភាពងាយរងគ្រោះដែលពួកគេប្រឈម (ឬមួយជាសហ-គមន៍ និង/ឬជាក្រុមគោលដៅ) ចូររៀបចំសកម្មភាពបន្សាំ ដោយផ្អែកលើ៖<br>▪ សកម្មភាពអាទិភាពដោយសហគមន៍មូលដ្ឋាន និង/ឬក្រុមគោលដៅ<br>▪ សមត្ថភាពសហគមន៍មូលដ្ឋាន/ក្រុមគោលដៅ និងលទ្ធភាពរបស់ NGO ដែលជាអ្នកអនុវត្ត ដើម្បីបង្កើតសមត្ថភាពនានា<br>▪ ប្រភពធនធាន និងចំនួន ដែលអាចមាន<br>ដ. ចូរធ្វើបញ្ជីសកម្មភាពអាទិភាពដែលបានឯកភាព ដោយចាត់ជាជំពូកតាមទម្រង់ប្រហែលគ្នានឹងអ្វីដែលបានធ្វើក្នុង ៣.៤។ សម្រាប់សកម្មភាពនីមួយៗ ចូរផ្តល់សេចក្តីអធិប្បាយខ្លីៗអំពីរបៀបដែលអនុវត្តសកម្មភាពទាំងនោះ ដូចជា តួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារខុសៗគ្នាដែលពាក់ព័ន្ធ ការបណ្តុះបណ្តាល រចនាសម្ព័ន្ធដែលត្រូវការ។ល។ ចូរកំហិតសម្រាប់៉សកម្មភាព៉នីមួយៗត្រឹម ២-៣ វាក្យខណ្ឌប៉ុណ្ណោះ។<br>ឋ. ចូរផ្តល់សេចក្តីសង្ខេបខ្លីមួយអំពីថាតើសកម្មភាពដែលបានចុះក្នុងតារាងមានភាពខុសគ្នាបែបណាពីសកម្មភាពគម្រោងអភិវឌ្ឍន៍ធម្មតា និងថាតើសកម្មភាពនានានឹងរួមចំណែកបែបណាទៅក្នុងការកសាងភាពធន់នឹងអាកាសធាតុ។ | |
| ៥.០ មេរៀនទទួលបាន និងសេចក្តីសន្និដ្ឋាន ( ១/២-១ ទំព័រ ) | |
| កម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅសហគមន៍នៅកម្ពុជា(CCBAP)គឺជាកម្មវិធីរៀនសូត្រមួយ។ ប្រសិនបើអ្នកមានមេរៀនដែលអ្នកបានរៀនសូត្រតាមរយៈដំណើរការVRA ចូរចែករម្លែកមេរៀនទាំងនោះក៏ដូចជា ផ្តល់អនុសាសន៍ផងដែរ។ | |

គំរូរបាយការណ៍របកគំហើញប្រៀបធៀប VRA (របាយការណ៍VRA លើកទី ២/ បន្តបន្ទាប់)

| | |
|---|---|
| ឈ្មោះគម្រោង | |
| ទីតាំងគម្រោង | |
| អ្នកលើកស្នើគម្រោង | |
| តំណាងដែលមានសិទ្ធិ | |
| ស្ថាប័នសហប្រតិបត្តិការ | |
| កាលបរិច្ឆេទធ្វើ VRA លើកដំបូង | |
| កាលបរិច្ឆេទធ្វើVRA លើកចុងក្រោយ | |

| មាតិកាក្នុងផ្នែកនេះ | ត្រូវការរូបនិងតារាង |
|---|---|
| ១.០ សេចក្តីផ្តើម (២-៣ វាក្យខ័ណ្ឌ) | |
| ក. បង្ហាញពីស្ថាប័នរបស់អ្នក ដែលរួមទាំងឈ្មោះ បេសកម្មចំបងៗ និងប្រវត្តិសង្ខេបបទពិសោធន៍របស់ស្ថាប័នអ្នកអំពីការបន្សាំរបស់សហគមន៍<br>ខ. ប្រសិនបើបានទទួលការគាំទ្រពីស្ថាប័នម្ចាស់ជំនួយសម្រាប់អនុវត្ត VRA ចំណុចនេះត្រូវតែបញ្ជាក់ បន្តដោយមូលហេតុដែលស្ថាប័នអនុវត្ត VRA សម្រេចយកការអនុវត្ត VRA និងតើព័ត៌មាននេះនឹងត្រូវប្រើប្រាស់សម្រាប់ធ្វើអ្វីខ្លះ។<br>*(ចូរចងចាំ៖ នេះជារបាយការណ៍របកគំហើញ VRA ប្រៀបធៀបពោលគឺ បង្ហាញពីមូលហេតុដែលត្រូវធ្វើ VRA ឡើងវិញ។ ហើយអាចមានមូលហេតុផ្សេង ដូចជារៀបចំអន្តរាគមន៍គម្រោងជំហានទី ២។)* | |
| ២.០ វិធីសាស្ត្រ (១ ទំព័រ) | |
| គ. ចូរបញ្ជាក់ពីពេលវេលាដែលបានអនុវត្ត VRA លើកដំបូង និងលើកចុងក្រោយបង្អស់ និងទីកន្លែង (ភូមិ ឃុំ ស្រុក ខេត្ត ប្រទេស) និងចំនួនអ្នកចូលរួម។ | |
| **មាតិកាក្នុងផ្នែកនេះ** | **ត្រូវការតារាងនិងរូប** |
| ២.០ វិធីសាស្ត្រ *(ត)* | |
| ឃ. ចូរបញ្ជាក់រាល់ការងាររៀបចំដែលបានធ្វើ ដើម្បីត្រៀមសម្រាប់សិក្ខាសាលា VRA ចុងក្រោយបំផុត ដូចជាព័ត៌មានសាវតាដែលរកបាន ការ | |

| | |
|---|---|
| ពិគ្រោះយោបល់ ជំហាននានាដែលបានអនុវត្តនៅតាមមូលដ្ឋាន ដើម្បីត្រៀមអ្នកចូលរួម សម្រាប់ចូលរួមប្រកបដោយខ្លឹមសារក្នុងដំណើរការ VRA នោះ។ | |
| ង. ចូរបញ្ជាក់ថា តើសិក្ខាសាលាVRA ចុងក្រោយបានធ្វើខុសគ្នាពីលើក" ដំបូង"ឬទេ ខុសគ្នាបែបណា និងហេតុអ្វី។ បន្តដោយ ការបង្ហាញពីថាតើ VRA នេះបានធ្វើឡើងតាមរយៈវិធីអង្កេតបុគ្គល និង/ឬ តាមរយៈវិធីពិភាក្សាក្រុមគោលដៅ។ ចំពោះការអង្កេតបុគ្គល ចូរបញ្ជាក់ពីចំនួនជំពូកអ្នកចូលរួម (អធិប្បាយសង្ខេប) និងចំនួនអ្នកឆ្លើយនៅក្នុងការអង្កេតបែបណាមួយនោះ។ | ទិន្នន័យសម្រាប់ "ង" អាចដាក់នៅក្នុងតារាង |
| ច. ចំពោះវិធីពិភាក្សាក្រុមគោលដៅ ចូរផ្តល់សេចក្តីអធិប្បាយខ្លីអំពីក្រុមនេះ។ ឧទាហរណ៍ អ្នកឆ្លើយជាបុរស អាយុ ២០-៤០ឆ្នាំ អ្នកឆ្លើយជាស្ត្រី អាយុ ៣៥-៤៥ឆ្នាំ សមាគមកសិករ រហូតដល់តំណាងរដ្ឋាភិបាល ដែលរួមទាំងសមាជិកក្រុមប្រឹក្សាឃុំ និងស្រុក។ល។ ដោយសង្ខេប។ ត្រូវរួមបញ្ចូលចំនួនសរុបនៃអ្នកចូលរួមក្នុងក្រុមនីមួយៗផងដែរ។ | |
| ឆ. ចូរបញ្ជាក់ខ្លីៗថាតើទិន្នន័យនឹងត្រូវវិភាគ/ប្រៀបធៀបបែបណា ក៏ដូចជាភាពទន់ខ្សោយណាមួយក្នុងទិន្នន័យប្រៀបធៀបដែលបានផ្តល់។ ឧទាហរណ៍ សំណាក កង្វះទិន្នន័យ រហូតដល់ឧបសគ្គខាងវិធីសាស្ត្រ។ល។ | |

កំណត់សំគាល់៖ ពាក្យថា "ដំបូង" និង"ចុងក្រោយ" ត្រូវបានប្រើប្រាស់។ ពាក្យនេះសំដៅលើសិក្ខាសាលា VRA ដែលបានធ្វើឡើងនៅក្នុងកន្លែងគោលដៅ និងបរិបទដូចគ្នា និងទិន្នន័យជាក់លាក់ដែលត្រូវប្រៀបធៀប ត្រូវបានឲ្យឈ្មោះក្នុងឯកសារណែនាំនេះថា "ដំបូង" និង"ចុងក្រោយ"។

| មាតិកាក្នុងផ្នែកនេះ | ត្រូវការតារាង និងរូប |
|---|---|
| ៣.០ របកគំហើញប្រៀបធៀប VRA (៣-៥ ទំព័រ) *(ត្រូវរាយការណ៍ទៅតាមក្រុមគោលដៅ និង/ឬ ជំពូកនៃអ្នកចូលរួមសម្រាប់ការអង្កេតបុគ្គល)* | |
| ជ. (៣.១) និន្នាការ និងផលប៉ះពាល់បរិស្ថាន<br>ព័ត៌មានអំពីនិន្នាការ នៃការប្រែប្រួលអាកាសធាតុ មិនទំនងជាប្រែប្រួលឡើយរវាងសិក្ខាសាលាVRA "ដំបូង" និង"ចុងក្រោយ"។ ដូច្នេះ ចូរផ្តល់តែសេចក្តីសង្ខេបខ្លីមួយអំពីអ្វីដែលមានចែងនៅក្នុងរបាយការណ៍របកគំហើញ VRA ដំបូង។ ប្រសិនបើមានការប្រែប្រួលច្រើននៃលក្ខខណ្ឌគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ និងធាតុអាកាស រវាងអំឡុងពេលនៃសិក្ខាសាលាVRA ចូរផ្តល់សេចក្តីសង្ខេបអំពីព្រឹត្តិការណ៍ទាំងនោះ។<br>(៣.១.១) បន្តដោយការផ្តល់ទិន្នន័យប្រៀបធៀបដែលទាក់ទងនឹង | រូបនិងតារាង៖ លទ្ធផលនៃការវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ (ដាក់បញ្ចូលតារាងក្នុងឧបសម្ព័ន្ធ)<br><br>រូប៖ និន្នាការភាពងាយរងគ្រោះចំពោះការប្រែ |

| | |
|---|---|
| ទម្រង់H-សំណួរទី១។ ចូររាយការណ៍អំពីភាពខុសគ្នារវាងទិន្នន័យ VRA ដំបូង និងចុងក្រោយ ដែលប្រមូលបាន ទាក់ទងនឹង៖ ១) ផលប៉ះពាល់ ២) ធនធាន និងយុទ្ធសាស្ត្រដែលបានប្រើប្រាស់ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន នូវលក្ខខណ្ឌគ្រោះថ្នាក់ និង ៣) ការដាក់ពិន្ទុ VRA ។ ចូរផ្តល់ហេតុផលដោយសង្ខេបអំពីភាពខុសគ្នា ដែលទាក់ទងនឹងលក្ខខណ្ឌគ្រោះថ្នាក់ដែលបានជួបប្រទះ នៅក្នុងអំឡុងពេលរវាងការវាយតម្លៃទាំងនេះ (ប្រសិនបើអាច) និង/ឬ ដែលទាក់ទងនឹងអន្តរាគមន៍គម្រោងសំខាន់ៗ សម្រាប់ #២ និង # ៣ ដែលបានចុះក្នុងកំណត់ត្រា។<br>ជម្រើស៖ ទាក់ទងនឹងទិន្នន័យអំពីការយល់ឃើញក្នុងទម្រង់ H-សំណួរទី២ លើកលែងតែមានភាពខុសគ្នាខ្លាំងនៅក្នុងទិន្នន័យដែលបានរាយការណ៍រវាងសិក្ខាសាលា VRA ដំបូង និងចុងក្រោយ បើពុំនោះទេ ពុំចាំបាច់មានរាយការណ៍ទេ។ ទោះជាយ៉ាងណាក៏ដោយ ត្រូវរាយការណ៍ពី ភាពខុសគ្នានៃពិន្ទុ VRA នៅក្នុងទម្រង់ H-សំណួរទី២ និងផ្តល់ហេតុផលអំពី ភាពខុសគ្នា ប្រសិនបើមាន។ | ប្រែួលអាកាសធាតុ (ពិន្ទុភាពងាយរងគ្រោះធៀបនឹងលក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុនិងធាតុអាកាសដែលបានកត់ត្រា) |

| មាតិកាក្នុងផ្នែកនេះ | ត្រូវការតារាង និងរូប |
|---|---|
| ៣.០ របកគំហើញ VRA *(ត)* | |
| ឈ. (៣.២) ការកសាងសមត្ថភាពទប់ទល់ និងបន្សាំ *(ការប្រៀបធៀបទិន្នន័យក្នុងទម្រង់ H- សំណួរទី១៖ ធនធាន និងយុទ្ធសាស្ត្រ ដែលបានប្រើប្រាស់ ដែលកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍)*<br>▪ ចូរប្រៀបធៀបទិន្នន័យដែលមាន រវាងសិក្ខាសាលា VRA ដំបូង និងចុងក្រោយ ដោយបង្ហាញពីភាពខុសគ្នារវាងលទ្ធផល VRA ទាំងពីរលើកនេះ។ ប្រការនេះនឹងបង្ហាញពីសមត្ថភាពអ្វីខ្លះដែលបានកសាង តាមរយៈអន្តរា-គមន៍គម្រោង ឬ បាត់បង់ នៅក្នុងអំឡុងពេលនេះ។ ចូរអនុវត្តតាម លំដាប់លំដោយនៃការសរសេរ ដូចមាននៅក្នុងរបាយការណ៍របក គំហើញ VRA ដំបូង។ | ជម្រើស៖ គេអាចបញ្ចូលទិន្នន័យជាតារាងជាមួយការបន្ថែមជាលាយលក្សអក្សរនូវទិដ្ឋភាពរួម ដែលគួសបញ្ជាក់ចំណុចដែលសំខាន់បំផុត |
| ញ. (៣.៣) ឧបសគ្គចំពោះការបន្សាំ *(ផ្អែកនេះបានផ្អែកលើព័ត៌មានក្នុងទម្រង់ H- សំណួរទី៣។ ដូចគ្នានេះដែរ ជាការល្អត្រូវចាត់ចែងរបាយ-ការណ៍ដូចដែលបានអនុវត្តក្នុង ៣.២ អំពីរបាយការណ៍របកគំហើញ* | |

| | |
|---|---|
| VRA *ដំបូង។*<br>▪ ការប្រៀបធៀបទិន្នន័យដែលផ្តល់ រវាងសិក្ខាសាលាVRA ដំបូង និង ចុងក្រោយ ចូរបង្ហាញពីភាពខុសគ្នារវាងសិក្ខាសាលាទាំងពីរ។ ប្រ-ការនេះនឹងបង្ហាញភាពប្រែប្រួលនៃឧបសគ្គចំពោះការបន្សាំ ដែលកើតចេញពីអន្តរាគមន៍គម្រោង ឬ មូលហេតុដទៃទៀត។ ចូរពន្យល់ពីមូលហេតុដែលនាំឲ្យមានភាពខុសគ្នានេះ។<br>▪ ចូរផ្តល់ពិន្ទុអំពីភាពងាយរងគ្រោះ ជាមួយសេចក្តីពន្យល់ពីទិដ្ឋភាពរួមនៃបរិបទចុងក្រោយនៃភាពងាយរងគ្រោះ និងវិភាគទានពីអន្តរា-គមន៍គម្រោង ទាក់ទងនឹងការកែលម្អពិន្ទុភាពងាយរងគ្រោះ ឬ មូលហេតុដែលពិន្ទុភាពងាយរងគ្រោះបានស្ថិតនៅដដែល ឬ កាន់តែអាក្រក់ នៅពេលធៀបនឹងទិន្នន័យពីសិក្ខាសាលា VRA ដំបូង។<br>▪ បង្ហាញថាតើនៅតែមានឧបសគ្គអ្វីខ្លះចំពោះការបន្សាំ និងសូមបញ្ជាក់ពីមូលហេតុ។ | ជម្រើស៖ ចូរផ្តល់ព័ត៌មានជាតារាង |

| មាតិកាក្នុងផ្នែកនេះ | ត្រូវការតារាងនិងរូប |
|---|---|
| ៣.០ របកគំហើញ VRA *(ត)* | |
| ដ. (៣.៤) ការកាត់បន្ថយភាពងាយរងគ្រោះ *(ដោយផ្អែកលើការឆ្លើយតប/សកម្មភាពកាត់បន្ថយភាពងាយរងគ្រោះ នៅក្នុងទម្រង់ H- សំណួរទី១ និង ចំណាត់ថ្នាក់ការឆ្លើយតបទាំងនេះដែលបានពីទម្រង់ H- សំណួរទី៤)*<br>▪ ចូរផ្តល់ទិដ្ឋភាពរួមនៃ"សកម្មភាពជាអាទិភាព" ដែលមានចែងនៅក្នុងទម្រង់ H- សំណួរទី៤ នៅក្នុងសិក្ខាសាលា VRA ដំបូង និងចែងបញ្ជាក់ថាតើសកម្មភាពណាខ្លះ ដែលជាសកម្មភាពអន្តរាគមន៍របស់គម្រោងបាន និងពុំបានដោះស្រាយ។ ចូរកត់សំគាល់តាមលំដាប់អាទិភាព សកម្មភាពដែលលើកស្នើ (ពីទម្រង់H-សំណួរទី៤ ដែលបានពីសិក្ខាសាលាVRA ចុងក្រោយ)។ ចូរចាត់ចម្លើយតបជាជំពូក ទៅតាមជាតុទាំងប្រាំសម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិត និង/ឬ ជាតុផ្សំនៃសុខុមាលភាពរបស់សហគមន៍ទៅតាមករណីសមស្រប ពោលគឺ មិនមែនគ្រប់ជំពូកសុទ្ធតែមានចម្លើយតបឡើយ។<br>▪ ចូរផ្តល់សេចក្តីសង្ខេប និងហេតុផលជារួមសម្រាប់សកម្មភាពដែលស្នើឡើងសម្រាប់ចម្លើយតបក្នុងជំពូកនីមួយៗ។ | ជម្រើស៖ សកម្មភាពអាទិភាពអាចដាក់បញ្ចូលក្នុងតារាងមួយ |

| | |
|---|---|
| ▪ ចូរផ្តល់ពិន្ទុក្នុង H សំណួរទី៤ លើកចុងក្រោយ និងហេតុផលសង្ខេបនៅក្នុងបរិបទ ថាតើអ្នកចូលរួមមានទំនុកចិត្តកម្រិតណាដែលថាសកម្មភាព ជាអាទិភាពដែលបានបង្ហាញ នឹងកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេចំពោះការប្រែប្រួលអាកាសធាតុ។ | |
| មាតិកាក្នុងផ្នែកនេះ | ត្រូវការតារាងនិងរូប |
| ៤.0 សំណើសកម្មភាពបន្សុំ ( ១-២ ទំព័រ ) | |
| ក្រោយពីបានវិភាគព្រឹត្តិការណ៍អាកាសធាតុចំបងៗ និងផលប៉ះពាល់សំខាន់ៗមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍ ធនធាន និងយុទ្ធសាស្ត្រ ដែលពួកគេប្រើប្រាស់ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ និងឧបសគ្គចំពោះការកាត់បន្ថយភាពងាយរងគ្រោះ ដែលពួកគេប្រឈម (ជាសហគមន៍ និង/ឬដោយក្រុមគោលដៅ) ចូររៀបចំសកម្មភាពបន្សុំ ដោយផ្អែកលើ៖<br>▪ សកម្មភាពអាទិភាព ដោយសហគមន៍ និង/ឬ ក្រុមគោលដៅ<br>▪ សមត្ថភាពសហគមន៍មូលដ្ឋាន/ក្រុមគោលដៅ និងលទ្ធភាពរបស់ NGO ដែលជាអ្នកអនុវត្ត ក្នុងការកសាងសមត្ថភាពនានា<br>▪ ប្រភព និងចំនួនមូលនិធិដែលអាចមាន<br>ដ. ចូរធ្វើបញ្ជីសកម្មភាពអាទិភាពដែលបានឯកភាព ដោយចាត់ជាជំពូកតាមទម្រង់ប្រហែលគ្នានឹងអ្វីដែលបានធ្វើក្នុង ៣.៤។ សម្រាប់សកម្មភាពនីមួយៗ ចូរផ្តល់សេចក្តីអធិប្បាយខ្លីៗអំពីរបៀបដែលអនុវត្តសកម្មភាពទាំងនោះ ដូចជា តួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារខុសៗគ្នាដែលពាក់ព័ន្ធ ការបណ្តុះបណ្តាល រចនាសម្ព័ន្ធដែលត្រូវការ។ល។ ចូរកំហិតសម្រាប់"សកម្មភាព"នីមួយៗត្រឹម ២-៣ វាក្យខណ្ឌប៉ុណ្ណោះ។<br>ដ. ចូរផ្តល់សេចក្តីសង្ខេបខ្លីមួយអំពីថាតើសកម្មភាពដែលបានចុះក្នុងតារាងមានភាពខុសគ្នាបែបណាពីសកម្មភាពគម្រោងអភិវឌ្ឍន៍ធម្មតា និងថាតើសកម្មភាពនានានឹងរួមចំណែកបែបណាទៅក្នុងការកសាងភាពធន់នឹងអាកាសធាតុឬទេ។ | |
| ៥.0 មេរៀនទទួលបាន និងសេចក្តីសន្និដ្ឋាន ( ១/២-១ទំព័រ ) | |
| កម្មវិធីបន្សុំការប្រែប្រួលអាកាសធាតុនៅសហគមន៍នៅកម្ពុជា(CCBAP)គឺជាកម្មវិធីរៀនសូត្រមួយ។ ប្រសិនបើអ្នកមានមេរៀនដែលអ្នកបានរៀនសូត្រតាមរយៈដំណើរការប្រៀបធៀបVRA ចូរចែករម្លែកមេរៀនទាំងនោះក៏ដូចជាផ្តល់អនុសាសន៍ផងដែរ។ | |

# ឧបសម្ព័ន្ធ ១ វាក្យស័ព្ទ និងលំហាត់ពិនិត្យសញ្ញាណនានា សម្រាប់ក្រុមអ្នកសម្របសម្រួល VRA

លំហាត់នេះគួរតែបានអនុវត្តដោយអ្នកសម្របសម្រួល VRA ទាំងអស់ មុននឹងអនុវត្ត VRA នៅតាមមូលដ្ឋាន សូម្បីតែអ្នកដែលមានបទពិសោធន៍ច្រើនហើយក៏ដោយ។ ចំពោះក្រុមអ្នកសម្របសម្រួល VRA ដែលមានបទពិសោធន៍កម្រិតកំណត់អំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ពួកគេគួរតែ ១) អនុវត្តលំហាត់នេះជាក្រុមមួយរួមគ្នា និងពិភាក្សាព្រមទាំងវិភាគវាក្យស័ព្ទ និងសញ្ញាណនានាជាជំហានៗ ឬ ២) ស្វែងរកភ្នាក់ងារអនុវត្តនៅមូលដ្ឋានដែលមានបទពិសោធន៍ខាងការបន្សាំរបស់សហគមន៍ ដើម្បីជួយសម្រួលការអនុវត្តលំហាត់នេះ។

គោលបំណង

- ✓ ពិនិត្យ/ផ្ទៀងផ្ទាត់ឡើងវិញអំពីការយល់ដឹងរបស់អ្នកចូលរួមលើសញ្ញាណនានា និងវាក្យស័ព្ទដែលមាននៅក្នុងជំពូក ១
- ✓ ផ្តល់ដំណើរការវាយតម្លៃដើម្បីវាស់ការសិក្សារបស់ក្រុម VRA

សម្ភារៈ

- ✓ សន្លឹកលំហាត់ - ១ សម្រាប់ក្រុមនីមួយៗ (អ្នកចូលរួម ៤-៥ នាក់)
- ✓ កន្ត្រៃ - ១ សម្រាប់ក្រុមនីមួយៗ

ពេលវេលា៖ ១៥-២០នាទី

**ចម្លើយសម្រាប់លំហាត់នេះ**

១&៧, ២&១៧, ៣&១១, ៤&១០, ៥&១៣, ៦&២២, ៨&១២, ៩&១៨, ១៦&១៤, ១៩&២០, ២៣&២៦, ២៤&២៥

ការសម្របសម្រួល

ជំហានទី ១

ណែនាំលំហាត់ និងដំណើរការនេះ និងធ្វើការសង្កត់ធ្ងន់អំពីសារៈសំខាន់នៃសមាជិកក្រុមអ្នកសម្របសម្រួល ដែលត្រូវមានការយល់ដឹងដូចគ្នាចំពោះប្រយោគងាយៗអំពី"ការប្រែប្រួលអាកាសធាតុ" ដែលត្រូវប្រើប្រាស់ក្នុងដំណើរការសិក្សាម៉ូឌុលនេះ។

ជំហានទី ២

បែងចែកសមាជិកក្រុម VRA ទៅជាក្រុមដែលមានសមាជិក ៤ ឬ ៥នាក់ ឬ ជាក្រុមតែមួយ ប្រសិនបើមានគ្នាតិច។ ចូរផ្ដល់ឲ្យក្រុមនីមួយៗនូវសន្លឹកលំហាត់ និងឲ្យពួកគេកាត់ចេញជារាងចតុកោណតាមគំនូសដែលមានស្រេច ឲ្យចេញជាបំណែកតូចៗដាច់ពីគ្នា (ចតុកោណមិនតាមលំដាប់លំដោយណាមួយឡើយ)។ សូមទុកពេល ១៥ នាទីសម្រាប់ក្រុមធ្វើការ)។

ជំហានទី ៣

ស្នើអ្នកចូលរួមឲ្យផ្ទឹម"វាក្យស័ព្ទ និង/ឬ សញ្ញាណ" ដែលបានចែង (នៅក្នុងជំពូក ១) ជាមួយប្រយោគដែលត្រូវគ្នា។ ក្នុងពេលនេះ អ្នកសម្របសម្រួល/គ្រូបង្ហាត់ គួរពិនិត្យការងាររបស់ក្រុមនេះ ក្នុងពេលដំណើរការនេះ ដើម្បីឲ្យប្រាកដថា អ្នកចូលរួមមានការយល់ច្បាស់អំពី"វាក្យស័ព្ទ" និង/ឬ សញ្ញាណនានា។ ចូរផ្ដល់ការបំភ្លឺ ក្នុងករណីចាំបាច់ ប៉ុន្តែជៀសវាងការផ្ដល់ចម្លើយ។ ចូរចងចាំ នៅពេលដែលសមាជិកក្រុមអ្នកសម្របសម្រួល VRA មានការយល់ខុសដូចគ្នា។

ជំហានទី ៤

ក្រោយរយៈពេលដែលផ្ដល់ឲ្យ(១៥នាទី)អ្នកសម្របសម្រួល/គ្រូបង្ហាត់គួរស្នើសមាជិកក្រុម VRA ឲ្យឈប់ និងបង្ហាញចម្លើយរបស់ខ្លួនសម្រាប់លំហាត់នោះ។ ស្នើក្រុមឲ្យផ្ដល់ពិន្ទុ (មិនសុទ្ធតែចាំបាច់ឡើយ)។ បន្ទាប់ពីនេះ ពិនិត្យ "វាក្យស័ព្ទ" និង/ឬ សញ្ញាណនានា ដែលបានបង្ហាញថាជាការលំបាកទូទៅសម្រាប់អ្នកចូលរួម ពោលគឺ ច្រើនតែមានកំហុស។

# សន្លឹកលំហាត់

| | |
|---|---|
| 1 ការបន្សាំ និងការកសាងភាពធន់ | 2 យើងត្រូវបង្កើនការយល់ដឹងក្នុងសហគមន៍យើង និងត្រូវត្រៀមខ្លួនសម្រាប់រដូវប្រាំង |
| 3 រដូវវស្សាទំនងជាកាន់តែក្រមកដល់ ជារៀងរាល់ឆ្នាំ ហើយនៅពេលមានភ្លៀង ព្យុះភ្លៀងកើតមានយ៉ាងខ្លាំង | 4 ព្រឹត្តិការណ៍ដ៏គ្រោះថ្នាក់ |
| 5 ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | 6 សហគមន៍ច្រើនតែដឹងពីរបៀបដោះស្រាយបញ្ហារបស់ខ្លួន ហើយអ្វីដែលពួកគាត់នៅខ្វះខាតគឺសម្ភារៈចាំបាច់ |
| 7 យើងតម្លើងឧបករណ៍ត្រងទឹកភ្លៀងតាមផ្ទះ ឥឡូវនេះ យើងត្រូវចាត់ចែងសហគមន៍ ដើម្បីគ្រប់គ្រងឧបករណ៍ទាំងនោះ | 8 ភាពធន់ |
| 9 ភាពងាយរងគ្រោះចំពោះអាកាសធាតុ | 10 ដោយសារតែគ្រោះរាំងស្ងួតក្នុងឆ្នាំនេះ ភ្លើងព្រៃបានបំផ្លាញផ្ទះចំនួនបួនខ្នង នៅក្នុងភូមិជិតខាង |
| 11 ការប្រែប្រួលអាកាសធាតុ | 12 កសិករបានរកឃើញថា ជាការល្អត្រូវចាត់ចែងខ្លួនឯងឲ្យទៅជាក្រុមសិក្សា ដើម្បីចែករំលែកចំណេះដឹងបច្ចេកទេស |
| 13 ការប្រែប្រួលវិជ្ជមាន និងអវិជ្ជមាននៃធនធានទឹក កសិកម្ម និងសន្តិសុខស្បៀង ប្រព័ន្ធអេកូឡូស៊ីដែនដីគោក និងជីវៈចម្រុះ | 14 កសិករបានចាប់ផ្តើមប្រើប្រាស់សំណាញ់ដើម្បីការពារដំណាំរបស់ខ្លួន និងឫស្សីដើម្បីការពារដីរបស់ពួកគេនៅក្នុងរដូវវស្សា |

| | |
|---|---|
| 15 សហគមន៍ច្រើនតែដឹងពីរបៀបដោះស្រាយបញ្ហារបស់ខ្លួន ហើយអ្វីដែលពួកគាត់នៅខ្វះខាតគឺសម្ភារៈចាំបាច់ | 16 ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| 17 ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | 18 កសិករដែលធ្វើស្រែនៅតំបន់ទំនាបក្នុងប្រទេសថៃបានបាត់បង់ដំណាំភាគច្រើនរបស់ខ្លួនជាថ្មីម្តងទៀតដោយសារទឹកភ្លៀងក្នុងរដូវវស្សា |
| 19 នេះជាថ្ងៃត្រជាក់បំផុតក្នុងកំណត់ត្រាសម្រាប់វៀតណាម ប៉ុន្តែសីតុណ្ហភាពនៅទូទាំងអាស៊ីពុំដែលចុះត្រជាក់បែបនេះទេ | 20 ធាតុអាកាស និងអាកាសធាតុ |
| 21 សីតុណ្ហភាពមធ្យមនៃផ្ទៃផែនដីក្នុងប្រទេសចិនបានកើនឡើង១,១ អង្សារសេ | 22 សមត្ថភាពបន្សាំ |
| 23 ផលផ្ទះកញ្ចក់ និងឧស្ម័នផ្ទះកញ្ចក់ | 24 សីតុណ្ហភាពមធ្យមនៃផ្ទៃផែនដីក្នុងប្រទេសចិនបានកើនឡើង១,១ អង្សារសេ |
| 25 ការឡើងកំដៅផែនដី | 26 ដំណើរការ និងផលិតផលមួយ ដែលរក្សាសីតុណ្ហភាពនៃផែនដីឲ្យមានតុល្យភាព |

# ឧបសម្ព័ន្ធ ២ ក្រាហ្វិកខ្សែនិន្នាការ និងក្រាហ្វិកជំបង អំពីការប្រមូលព័ត៌មានពីការពិភាក្សាក្រុម ក្នុង MICROSOFT EXCEL

## ក្រហ្វិកខ្សែនិន្នាការ

ក្រាហ្វិកខ្សែនិន្នាការ ត្រូវបានប្រើប្រាស់សម្រាប់បង្ហាញព័ត៌មានដែលទាក់ទងនឹងឧបករណ៍វិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ ដូចជា លក្ខខណ្ឌគ្រោះថ្នាក់ដែលទាក់ទងនឹងអាកាសធាតុ និងធាតុអាកាស និងព្រឹត្តិការណ៍នៅក្នុងអំឡុងពេលកំណត់មួយ ព្រមទាំងការយល់ឃើញរបស់អ្នកចូលរួម អំពីភាពងាយរងគ្រោះ ចំពោះព្រឹត្តិការណ៍ទាំងនោះ។ ដំណើរការនៃការប្រើប្រាស់ Microsoft Office – Excel 2010 version ចែកចេញជាបីជំហានសំខាន់ៗ។

**ជំហានទី ១**

ស្រង់យកទិន្នន័យចាំបាច់ពីតារាងវិភាគនិន្នាការនៃការប្រែប្រួលអាកាសធាតុ។ ការរៀបចំនៅក្នុងសន្លឹកអិចសែល គឺពេលវេលា លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាសដែលបានកំណត់ និងចំណាត់ថ្នាក់ភាពងាយរងគ្រោះដែលត្រូវគ្នានោះ។ ឧទាហរណ៍ ដែលផ្តល់គឺ៖ ១) តាមការមូលមតិក្នុងក្រុម និង ២) តាមការបោះឆ្នោតរៀងៗខ្លួន នៅក្នុងក្រុម។ ទិន្នន័យពីការមូលមតិក្នុងក្រុមនឹងត្រូវប្រើប្រាស់ជាឧទាហរណ៍នៅក្នុងការបង្រៀននេះ។

| លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស | ១៩៨០-១៩៨៩ *(រដ្ឋកម្ពុជា)* | ១៩៩០-១៩៩៩ *(អ៊ុនតាក់និងសម្ព័ន្ធមិត្ត)* | ២០០០-២០០៩ *(ព្រះរាជាណាចក្រកម្ពុជា)* | ២០១០-បច្ចុប្បន្ន *(ព្រះរាជាណាចក្រកម្ពុជា)* |
|---|---|---|---|---|
| • រដូវប្រាំងមានរយៈវែងជាងមុន (+៣ សប្តាហ៍) | **(១)** ២ ៣ ៤ ៥ | **(១)** ២ ៣ ៤ ៥ | ១ ២ **(៣)** ៤ ៥ | ១ ២ ៣ **(៤)** ៥ |
| • ខូចដំណាំដោយការរាំងស្ងួត | ១ **(២)** ៣ ៤ ៥ | ១ ២ **(៣)** ៤ ៥ | ១ ២ ៣ **(៤)** ៥ | ១ ២ ៣ ៤ **(៥)** |
| • ខូចដំណាំដោយទឹកជំនន់ | **(១)** ២ ៣ ៤ ៥ | ១ ២ **(៣)** ៤ ៥ | ១ **(២)** ៣ ៤ ៥ | ១ ២ **(៣)** ៤ ៥ |
| • ការប្រែប្រួលអំឡុងពេលនៃរដូវវស្សា/ប្រាំង | **(១)** ២ ៣ ៤ ៥ | **(១)** ២ ៣ ៤ ៥ | ១ ២ **(៣)** ៤ ៥ | ១ ២ ៣ ៤ **(៥)** |

ឧទាហរណ៍អំពីការមូលមតិក្នុងក្រុម

| លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស | ១៩៨០-១៩៨៩ (រដ្ឋកម្ពុជា) | ១៩៩០-១៩៩៩ (អ៊ុនតាក់និងសម្ព័ន្ធភាព) | ២០០០-២០០៩ (ព្រះរាជាណាចក្រកម្ពុជា) | ២០១០-បច្ចុប្បន្ន (ព្រះរាជាណាចក្រកម្ពុជា) |
|---|---|---|---|---|
| • រដូវប្រាំងមានរយៈពេលវែងជាងមុន (+៣ សប្តាហ៍) | ១ ២ ៣ ៤ ៥ (១.៥០) | ១ ២ ៣ ៤ ៥ (២.៦២) | ១ ២ ៣ ៤ ៥ (៣.១១) | ១ ២ ៣ ៤ ៥ (៣.០០) |
| • ដំណាំខូចដោយការរាំងស្ងួត | ១ ២ ៣ ៤ ៥ (១.០០) | ១ ២ ៣ ៤ ៥ (២.០០) | ១ ២ ៣ ៤ ៥ (៣.៤៥) | ១ ២ ៣ ៤ ៥ (៤.៨៤) |
| • ខូចដំណាំដោយទឹកជំនន់ | ១ ២ ៣ ៤ ៥ (១.៦២) | ១ ២ ៣ ៤ ៥ (១.២២) | ១ ២ ៣ ៤ ៥ (៣.៦២) | ១ ២ ៣ ៤ ៥ (៤.០២) |
| • ការប្រែប្រួលអំឡុងពេលនៃរដូវវស្សា/ប្រាំង | ១ ២ ៣ ៤ ៥ (១.៦២) | ១ ២ ៣ ៤ ៥ (១.៤២) | ១ ២ ៣ ៤ ៥ (២.៤២) | ១ ២ ៣ ៤ ៥ (៣.៦២) |

ឧទាហរណ៍អំពីការនោះឆ្នោតនៅក្នុងក្រុមមួយ

**ជំហានទី ២**

ចូរចាត់ចែងទិន្នន័យរបស់អ្នកនៅក្នុងតារាងអិចសែល ១) លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស ២) អំឡុងពេល និង ៣) ការដាក់ពិន្ទុភាពងាយរងគ្រោះរបស់អ្នកចូលរួម។

រូបភាពនៃសន្លឹកអិចសែល

| | A | B | C | D | E |
|---|---|---|---|---|---|
| 1 | | 1980-1989 | 1990-1999 | 2000-2009 | 2010-បច្ចុប្បន្ន |
| 2 | រដូវប្រាំងមានរយៈពេលវែងជាងមុន (+៣ សប្តាហ៍) | 1 | 1 | | |
| 3 | ខូចដំណាំដោយការរាំងស្ងួត | 2 | 3 | 4 | 5 |
| 4 | ខូចដំណាំដោយទឹកជំនន់ | 1 | 3 | 2 | 3 |
| 5 | ការប្រែប្រួលអំឡុងពេលនៃ រដូវវស្សា/ប្រាំង | 1 | 1 | 3 | 5 |

អំឡុងពេល

លក្ខខណ្ឌគ្រោះថ្នាក់នៃអាកាសធាតុ និងធាតុអាកាស

ការដាក់ពិន្ទុភាពងាយរងគ្រោះរបស់អ្នកចូលរួម

**ជំហានទី ៣**

ដើម្បីបង្កើតក្រាហ្វិកខ្សែនិន្នាការ គេត្រូវអនុវត្តជំហានដូចតទៅ៖

I. ចុចជួរ 1-5 និងជួរឈរ A-E ក្នុងពេលជាមួយគ្នា

II. ចុច 'INSERT' នៅក្នុងចម្រៀកមុខងារ និងបន្ទាប់មក ចុច 'LINE' នៅក្នុងចម្រៀករងនៃ'តារាង'និងបន្ទាប់មក ចុចម្តងទៀតលើបន្ទះ '2-D LINE'។ ក្រាហ្វិកខ្សែបន្ទាត់និន្នាការនឹងលេចឡើង។

III. ដើម្បីដាក់ស្លាកសំគាល់ 'ភាពងាយរងគ្រោះ' នៅក្នុងក្រាហ្វិកខ្សែបន្ទាត់និន្នាការ សូមចុចលើក្រាហ្វិកនេះ បន្ទាប់មកចុចលើ 'LAYOUT' នៅក្នុងបន្ទះមុខងារ ហើយជ្រើសយក 'AXIS TITLES', បន្ទាប់មក 'PRIMARY VERTICAL AXIS TITLES', ជ្រើសយក HORIZONTAL TITLE, និងបន្ទាប់មកវាយបញ្ចូល 'ចំណាត់ថ្នាក់ភាពងាយរងគ្រោះ' និងចុច 'ENTER'។

IV. ដើម្បីបន្ថែមឈ្មោះក្រាហ្វិកខ្សែនិន្នាការ សូមចុចលើក្រាហ្វិក បន្ទាប់មកចុច 'LAYOUT' នៅក្នុងបន្ទះមុខងារ បន្ទាប់មកចុច CHART TITLE, ជ្រើសយក 'TITLE ABOVE CHART' និងវាយបញ្ចូលឈ្មោះក្រាហ្វិក បន្ទាប់មកចុច 'ENTER'។

រូបភាពសន្លឹកអិចសែលនៅលើអេក្រង់ – ការជ្រើសយកក្រាហ្វិកខ្សែបន្ទាត់



រូបភាពសន្លឹកអិចសែលនៅលើអេក្រង់ – គំរូក្រាហ្វិកខ្សែបន្ទាត់និន្នាការនៃការប្រែប្រួលអាកាសធាតុ



## ក្រាហ្វិកដំបងអំពីកម្រិតញឹកញាប់នៃចម្លើយ

ក្រាហ្វិកដំបងអំពីកម្រិតញឹកញាប់នៃចម្លើយ អាចយកទៅប្រើប្រាស់តាមរបៀបមួយចំនួន និង សម្រាប់ VRA, ក្រាហ្វិកនេះច្រើនប្រើប្រាស់សម្រាប់បង្ហាញព័ត៌មានដែលទាក់ទងនឹង៖

- ✓ ព័ត៌មានក្នុងទម្រង់ H ដែលទាក់ទងជាក់លាក់នឹងផលប៉ះពាល់ដែលកត់ត្រាក្នុង សំណួរទី១ និង សំណួរទី២ និងកម្រិតញឹកញាប់នៃចម្លើយ ដើម្បីបង្ហាញសារៈសំខាន់នៅទូទាំងកន្លែងជាគោលដៅ
- ✓ ព័ត៌មានក្នុងទម្រង់H ដែលទាក់ទងនឹង "អ្វីដែលរារាំងអ្នកពីការបន្សុំ" (សំណួរទី៣) និងកម្រិតញឹកញាប់នៃចម្លើយ ក្នុងការបង្ហាញពីសារៈសំខាន់នៅទូទាំងកន្លែងជាគោលដៅ
- ✓ ការប្រៀបធៀបរវាងទិន្នន័យដូចគ្នា ប៉ុន្តែបានមកនៅក្នុងអំឡុងពេលខុសគ្នា

នៅក្នុងដំណើរការនៃការប្រើប្រាស់Microsoft Office – Excel 2010 មានប្រាំជំហានដែលត្រូវអនុវត្ត៖

**ជំហានទី ១**

ចម្លងយកទិន្នន័យចាំបាច់ពីសន្លឹកទិន្នន័យសំណួរក្នុងទម្រង់ H។ សម្រាប់ជាឧទាហរណ៍នៅក្នុងការបង្រៀននេះ ទិន្នន័យពីទម្រង់H- សំណួរទី១ ទាក់ទងនឹង"ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍" នឹងត្រូវប្រើប្រាស់។

**ជំហានទី ២**

ទិន្នន័យចាំបាច់គឺ ១) "ផលប៉ះពាល់អវិជ្ជមាន"ដែលបានចែងនៅក្នុងទម្រង់ H- សំណួរទី ១ និង ២) ចំនួនចម្លើយតបនឹងផលប៉ះពាល់នីមួយៗដែលអ្នកចូលរួមក្នុង VRA បានកំណត់។ ឧទាហរណ៍មួយត្រូវបានបង្ហាញខាងក្រោម។



ចូរចាត់ថែងទិន្នន័យរបស់អ្នកនៅក្នុងសន្លឹកអិចសែល ១) "ផលប៉ះពាល់អវិជ្ជមាន" ដែលបានថែងនៅក្នុងទម្រង់ H សំណួរទី ១ និង ២) ចំនួនចម្លើយតបនឹងផលប៉ះពាល់នីមួយៗ ដែលកំណត់ដោយអ្នកចូលរួមក្នុង VRA នេះ។

រូបភាពនៃសន្លឹកអិចសែល

| | A | B |
|---|---|---|
| 1 | គ្មានទឹកសម្រាប់ស្រោចដំណាំ | 4 |
| 2 | កំណើនការខូចខាតដោយទឹកជំនន់ | 1 |
| 3 | ការផ្ទុះជំងឺសត្វ | 1 |
| 4 | ទិន្នផលស្រូវថយចុះ | 6 |

"ផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍"

ចំនួនចម្លើយរបស់អ្នកចូលរួម

**ជំហានទី ៣**

ដើម្បីបង្កើតក្រាហ្វិកអំពីកម្រិតញឹកញាប់នៃចម្លើយ ត្រូវអនុវត្តតាមជំហានដូចតទៅ៖

I. រំលេចជួរដេក ១-៤ និងជួរឈរ A-B ក្នុងពេលជាមួយគ្នា។

II. ចុចលើបន្ទះ 'INSERT' នៅក្នុងចម្រៀកមុខងារ បន្ទាប់មកចុចលើ 'BAR' នៅក្នុងចម្រៀករង 'CHARTS' និង បន្ទាប់មកចុចម្តងទៀតលើក '2-D CLUSTERED BAR'។ ក្រាហ្វិកដំបងនឹងលេចឡើង។

III. ដើម្បីបង្កើត"កម្រិតញឹកញាប់នៃចម្លើយ" នៅចុងដំបងនីមួយៗដែលមានបង្ហាញ សូមចុចលើក្រាហ្វិក បន្ទាប់មកចុច 'LAYOUT' នៅក្នុងចម្រៀកមុខងារ, ចុច 'DATA LABELS' នៅក្នុងចម្រៀងរងស្លាកសញ្ញា និងទីបំផុតជ្រើសយក 'OUTSIDE END' ពីតារាងដែលធ្លាក់ចុះមកក្រោម។ លុបស្លាក 'series 1' ដោយចុចលើឈ្មោះនៅក្នុងក្រាហ្វិក និងលុប។

IV. ដើម្បីបង្កើតស្លាក"កម្រិតញឹកញាប់នៃចម្លើយ" នៅក្នុងដំបងនៃក្រាហ្វិកនេះ សូមចុចលើក្រាហ្វិក បន្ទាប់មកចុច បន្ទះ'LAYOUT' នៅក្នុងចម្រៀកមុខងារ, ជ្រើសយក 'AXIS TITLES', បន្ទាប់មក 'HORIZONTAL AXIS TITLE', និងជ្រើសយក TITLE BELOW AXIS, និងវាយបញ្ចូល "កម្រិតញឹកញាប់នៃចម្លើយ"។

V. ដើម្បីបន្ថែមឈ្មោះមួយទៅក្នុងក្រាហ្វិកដំបងរបស់អ្នក បន្ទាប់មកចុចលើក្រាហ្វិក បន្ទាប់មកចុចបន្ទះ 'LAYOUT' នៅក្នុងចម្រៀកមុខងារ បន្ទាប់មកចុច CHART TITLE, ជ្រើសយក 'TITLE ABOVE CHART' និងវាយបញ្ចូលឈ្មោះដែលចង់បាន។

រូបភាពអិចសែលលើអេក្រង់ - គំរូនៃក្រាហ្វិកអំពីកម្រិតញឹកញាប់នៃចម្លើយ




**ជំហានទី ៤**

ដើម្បីបង្កើតក្រាហ្វិកប្រៀបធៀបអំពីកម្រិតញឹកញាប់នៃចម្លើយ ដូចជា ទិន្នន័យដើមគ្រា ធៀបនឹងទិន្នន័យនៅចុងគម្រោង សូមចាត់ចែងទិន្នន័យរបស់អ្នកនៅក្នុងសន្លឹកអិចសែល ១) "ផលប៉ះពាល់អវិជ្ជមាន"ដែលចែង នៅក្នុងទម្រង់ H សំណួរទី ១ និង ២) ចំនួនចម្លើយតបនឹងផលប៉ះពាល់នីមួយដែលចែងដោយអ្នកចូលរួមក្នុង VRA សម្រាប់ទិន្នន័យដើមគ្រា និងទិន្នន័យនៅចុងគម្រោង។

រូបភាពនៃសន្លឹកអិចសែល

| | A | B | C |
|---|---|---|---|
| 1 | គ្មានទឹកសម្រាប់ស្រោចដំណាំ | 4 | 2 |
| 2 | [illegible] | [illegible] | [illegible] |

"ផលប៉ះពាល់អវិជ្ជមានលើការចិញ្ចឹមជីវិត និងសុខុមាលភាពរបស់សហគមន៍"ដែលបានចែង

ចំនួនចម្លើយរបស់អ្នកចូលរួម - ទិន្នន័យដើមគ្រា

ចំនួនចម្លើយរបស់អ្នកចូលរួម - ទិន្នន័យនៅចុងគម្រោង

**ជំហានទី ៥** ដើម្បីបង្កើតក្រាហ្វិកប្រៀបធៀបអំពីកម្រិតញឹកញាប់នៃចម្លើយ សូមអនុវត្តជំហានដូចតទៅ៖

I. រំលេចជួរដេក ១-៤ និង ជួរឈរ A-C ក្នុងពេលជាមួយគ្នា។

II. ចុចលើបន្ទះ 'INSERT' នៅក្នុងចម្រៀកមុខងារ និងបន្ទាប់មកចុចលើ 'BAR' នៅក្នុងចម្រៀងរង និងចុចម្តងទៀតលើ '2-D CLUSTERED BAR'។ ក្រាហ្វិកដំបងនឹងលេចឡើង។

III. ដើម្បីបង្កើត"កម្រិតញឹកញាប់នៃចម្លើយ"នៅចុងដំបងនីមួយៗដែលបង្ហាញ សូមចុចលើក្រាហ្វិកនេះ ចុចបន្ទះ 'LAYOUT' នៅក្នុងចម្រៀកមុខងារ បន្ទាប់មកចុច 'DATA LABELS' នៅក្នុងចម្រៀករងស្លាកសញ្ញា និងទីបំផុត ជ្រើសយក 'OUTSIDE END' ពីតារាងធ្លាក់ចុះ។

IV. ដើម្បីអនុវត្ត "ភាពញឹកញាប់នៃចម្លើយ" ការដាក់ស្លាកសញ្ញាលើក្រាហ្វិកដំបង សូមចុចលើក្រាហ្វិក បន្ទាប់មកចុចបន្ទះ'LAYOUT' នៅក្នុងចម្រៀកមុខងារ, ជ្រើសយក 'AXIS TITLES', បន្ទាប់មក 'HORIZONTAL AXIS TITLE', និងជ្រើសយក 'TITLE BELOW AXIS', ហើយវាយបញ្ចូល "កម្រិតញឹកញាប់នៃចម្លើយ"។

V. ដើម្បីដាក់ឈ្មោះ 'series', ដូចជា ទិន្នន័យដើមគ្រា និងទិន្នន័យនៅចុងគម្រោង សូមចុចម្រាមខាងស្តាំនៅលើស្លាកសញ្ញា 'series' ក្នុងក្រាហ្វិក និងជ្រើសយក 'SELECT DATA'។ ប្រអប់ដូចខាងក្រោមនឹងលេចឡើង៖




ចុចលើ 'Series1' និងបន្ទាប់មកចុចគន្លឹះ 'EDIT' នៅក្នុងប្រអប់សន្ទនា។ ប្រអប់សន្ទនា 'EDIT SERIES'ដូចតទៅនឹងលេចឡើង។




សូមវាយឈ្មោះ តាមការចង់បាន ដូចជាទិន្នន័យដើមគ្រា បន្ទាប់មក ចុចគន្លឹះ 'OK'។

ដើម្បីដូរឈ្មោះ 'Series2', អនុវត្តតាមដំណើរដូចខាងលើ បន្ទាប់មកចុចគន្លឹះ 'OK' នៅក្នុងប្រអប់សន្ទនា 'Select Data Source'។

VI. ដើម្បីបន្ថែមឈ្មោះទៅក្នុងក្រាហ្វិកដំបងប្រៀបធៀប សូមចុចលើក្រាហ្វិកនេះ បន្ទាប់មកចុចបន្ទះ 'LAYOUT' នៅក្នុងចម្រៀកមុខងារ បន្ទាប់មកចុច 'CHART TITLE', សូមជ្រើសយក 'TITLE ABOVE CHART' និងវាយបញ្ចូលឈ្មោះតាមការចង់បាន។

រូបអិចសែលលើអេក្រង់ - គំរូក្រាហ្វិកដំបងប្រៀបធៀប អំពីកម្រិតញឹកញាប់នៃចម្លើយ





SWEDEN

Australian Aid

gef

SGP The GEF Small Grants Programme

UNDP

Empowered lives.
Resilient nations.